

# ឯកសារពិគ្រោះយោបល់សម្រាប់ ការអភិវឌ្ឍគណបក្សនយោបាយ ភាគ៣

## ការរៀបចំ និងការងាររបស់ក្រុមអ្នកនយោបាយក្នុងសភា

# ADVISORY PAPERS ON POLITICAL PARTY DEVELOPMENT, Volume III

## THE ORGANISATION AND WORK OF POLITICAL GROUPS IN PARLIAMENTS

Konrad
Adenauer
Stiftung

Konrad
Adenauer
Stiftung

Freedom, justice and solidarity are the basic pricipales underlying the work of the Konrad-Adenauer-Stiftung (KAS). KAS is a political foundation, closely associated with the Christian Democratic Union of Germany (CDU). As co-founder of the CDU and the first Chancellor of the Federal Republic of Germany, Konrad Adenauer (1876-1967) united Christian social, conservative and liberal traditions. His name is synonymos with the democratic reconstruction of Germany, the firm alignment of foreign policy with the trans atlantic community of values, the vision of the unified Europe and an orientation towards the social market economy. In our European and international cooperation with more than 70 offices abroad and projects in over 120 countries, we make a unique contribution to the promotion of democracy, the rule of law and a social market economy.

# ឯកសារពិគ្រោះយោបល់សម្រាប់ការអភិវឌ្ឍគណបក្សនយោបាយ

## ភាគ៣

## ការរៀបចំ និងការងាររបស់ក្រុមអ្នកនយោបាយក្នុងសភា

Konrad
Adenauer
Stiftung

សេរីភាព យុត្តិធម៌ និងសាមគ្គី ជាគោលការណ៍ក្នុងការកំណត់សកម្មភាពរបស់មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ (Konrad-Adenauer-Stiftung) គឺជាមូលនិធិនយោបាយមួយ ដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមួយគណបក្សប្រជាធិបតេយ្យគ្រឹស្ត (Christian Democratic Union) របស់ប្រទេសអាល្លឺម៉ង់។ លោក ខុនរ៉ាដ អាដិនណៅអ៊ែរ (១៨៧៦-១៩៦៧) គឺជាសហស្ថាបនិកនៃគណបក្ស CDU និងជាអធិការបតីដំបូងគេបង្អស់ នៃសាធារណៈរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលបានបង្រួបបង្រួមពួកសង្គមគ្រឹស្តនិយម ពួកអភិរក្សនិយម និងពួកសេរីនិយមទាំងឡាយ។ កិត្តិនាមរបស់លោក មានន័យដូចគ្នាទៅនឹងការកសាងលទ្ធិប្រជាធិបតេយ្យឡើងវិញរបស់អាល្លឺម៉ង់ ការយល់ស្របគ្នាលើគោលនយោបាយការបរទេស ទៅនឹងគុណតម្លៃនៃសហគមន៍មហាសមុទ្រអាត្លង់ទិក ចក្ខុវិស័យនៃការបង្រួប បង្រួមអឺរ៉ុប និងការតម្រង់ទិសឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសង្គម។ KAS បានរួមចំណែកយ៉ាងសំខាន់ក្នុងការលើស្ទួយលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងសេដ្ឋកិច្ចទីផ្សារសង្គម នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអឺរ៉ុប និងអន្តរជាតិ តាមរយៈការិយាល័យរបស់ខ្លួននៅបរទេសច្រើនជាង ៧០ការិយាល័យ និងមានគម្រោងនានា នៅក្នុងប្រទេសជាង ១២០ប្រទេស។

ការិយាល័យនៅកម្ពុជា ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៤។ មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ នៅកម្ពុជា បាននឹងកំពុងបំពេញការងាររបស់ខ្លួនក្នុងវិស័យដូចតទៅ៖ កំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ ការពង្រឹងគណបក្សនយោបាយ និងសភា កំណែ ទម្រង់ច្បាប់ ការអភិវឌ្ឍប្រព័ន្ធឃោសនា ការអប់រំនយោបាយ និងសេដ្ឋកិច្ចទីផ្សារ សង្គម ក៏ដូចជាការពិគ្រោះយោបល់ផ្នែកគោលនយោបាយការបរទេសផងដែរ។

# មាតិកា

អារម្ភកថា ..................... ៥

១. សេចក្តីផ្តើម៖ ប្រភពដើម និងគោលការណ៍របស់ក្រុមអ្នកនយោបាយ ..................... ៩

ក. ប្រវត្តិសង្ខេបរបស់ក្រុមអ្នកនយោបាយ ..................... ៩

ខ. ភាពពាក់ព័ន្ធនៃក្រុមអ្នកនយោបាយសព្វថ្ងៃ ..................... ១១

២. តើត្រូវបង្កើតក្រុមអ្នកនយោបាយដោយរបៀបណា? ជំហានជាមូលដ្ឋាន ..................... ១៥

ក. សេចក្តីថ្លែងការណ៍នយោបាយ ..................... ១៥

ខ. សមាជិកភាព ..................... ១៥

គ. អង្គការលេខផ្ទៃក្នុងរបស់ក្រុមអ្នកនយោបាយ ..................... ១៨

ឃ. វិធាននៃនីតិវិធីកិច្ចប្រជុំក្រុមអ្នកនយោបាយ ..................... ២៤

ង. សង្គតិភាពក្រុមអ្នកនយោបាយ និងវិន័យក្រុម ..................... ២៥

ច. មូលនិធិ ..................... ២៩

៣. ការងាររបស់ក្រុមអ្នកនយោបាយ ........ ៣២
ក. ទំនាក់ទំនងជាមួយនឹងស្ថាប័នគណបក្សនយោបាយ ........ ៣២
ខ. ការរៀបចំសកម្មភាពគណបក្សនៅក្នុងអង្គនីតិបញ្ញត្តិ ........ ៣៤
គ. ការបង្កើតគោលនយោបាយលម្អិត ........ ៣៩
ឃ. ការគ្រប់គ្រងរដ្ឋាភិបាល ........ ៤២
ង. ការតំណាងគណបក្សនយោបាយ៖ ទំនាក់ទំនងរបស់គណបក្ស ........ ៤៣

ឧបសម្ពន្ធ ........ ៤៥
ឧបសម្ពន្ធ១៖ សម្រង់ច្បាប់ស្ដីពីសមាជិកសភាពសហព័ន្ធអាល្លឺម៉ង់ ........ ៤៧
ឧបសម្ពន្ធ២៖ សម្រង់បទបញ្ជាផ្ទៃក្នុងរបស់សភាសហព័ន្ធអាល្លឺម៉ង់ ........ ៥៥
ឧបសម្ពន្ធ៣៖ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមអ្នកតំណាងរាស្ត្រ CDU/CSU ក្នុងសភាសហព័ន្ធអាល្លឺម៉ង់ ........ ៥៧

# អារម្ភកថា

ជាឧបករណ៍ដ៏ចាំបាច់នៅក្នុងការបែងចែងកម្លាំងនៅក្នុងរដ្ឋសភា ក្រុមអ្នកនយោ-បាយអនុវត្តមុខងារជាតំណាង ការធ្វើសមាហរណកម្ម ភាពស្របច្បាប់ ការជ្រើសរើសបុគ្គលិក និងការប្រាស្រ័យទាក់ទង។ នៅខាងក្នុង ពួកគេអនុវត្តមុខងារសេវាកម្មសម្រាប់សមាជិកនីមួយៗរបស់សភា និងជាមួយគ្នានោះធានាពីសមត្ថភាពការងាររបស់សភា។ ពួកគេការពារលំហូរការងារសភាកុំឱ្យមានបន្ទុកភាពស្មុគស្មាញច្រើនហួស និងរាល់ការងារតបតនឹងភាពគ្រោះថ្នាក់នៃការជាប់គាំងនយោបាយ ដែលបណ្តាលមកពីភាពផ្សេងគ្នានៃផលប្រយោជន៍នយោបាយ និងទស្សនៈនយោបាយ។ ការរៀបចំរបស់ពួកគេនៅក្នុងគណៈកម្មាធិការការងារបង្កើតបាននូវបន្ទាត់ទំនាក់ទំនង ដែលធ្វើឱ្យមានការរៀបចំដោយប្រុងប្រយ័ត្ននៃការងារគណៈកម្មាធិការសភា និងធ្វើឱ្យមានសេចក្តីសម្រេចចិត្តសភាដោយការផ្តល់យោបល់ពីគណបក្ស និងសមាជិកម្នាក់ៗរបស់សភា។

មុខងារពិតប្រាកដនៃក្រុមអ្នកនយោបាយ គឺមិនមែនបង្កើតឱ្យមានការជួបទល់មុខគ្នារវាងសភា និងរដ្ឋាភិបាលឡើយ ប៉ុន្តែគឺការបង្កើតរដ្ឋាភិបាលដែលមានសំឡេងភាគច្រើន និងគណបក្សប្រឆាំង។ ដូច្នេះកិច្ចការទូទៅរបស់សភាត្រូវបានអនុវត្តទៅតាមថាមភាពជាក់លាក់នៃមុខងារ និងពេលវេលានៃការបែងចែកអំណាច។ ខណៈដែលក្រុមគ្រប់គ្រងព្យាយាមគាំទ្ររដ្ឋាភិបាលក្នុងការអនុវត្តអំណាចសភាដែលមានដូចជាការបោះឆ្នោត ការស្វែងរកដំណោះស្រាយគំនិតផ្តួចផ្តើម និងបទប្បញ្ញត្តិ ក្រុមប្រឆាំងប្រើប្រាស់អំណាចក្នុងការពិនិត្យតាមដាន ការរិះគន់ និងបង្ហាញជម្រើសផ្សេងៗដល់រដ្ឋាភិបាល។

ជាមួយគ្នានេះ ក្រុមអ្នកនយោបាយ និងគណបក្សអនុវត្តមុខងារនៃរបៀបវារៈគោលនយោបាយ ការធ្វើសេចក្តីសម្រេចចិត្ត និងការជ្រើសរើសអ្នកដឹកនាំនយោបាយ។ មុខងារនេះត្រូវបានបង្ហាញនៅក្នុងការបោះឆ្នោតរបស់រដ្ឋាភិបាល និងតាមរយៈការគាំទ្រសម្រាប់គោលនយោបាយរដ្ឋាភិបាលបច្ចុប្បន្ន។ អំណាចពិតប្រាកដនៃក្រុមអ្នកនយោបាយអាស្រ័យលើកត្តាដែលមានឥទ្ធិពលបន្ថែម ជាពិសេសថាតើមានបញ្ហានៃអំណាចត្រួតស៊ីគ្នារវាងថ្នាក់ដឹកនាំគណបក្ស និងថ្នាក់ដឹកនាំក្រុមអ្នកនយោបាយ ឬរវាងរដ្ឋាភិបាល និងប្រធានគណបក្ស។ ឥទ្ធិពលរវាងរដ្ឋាភិបាលដែលមានសំឡេងភាគច្រើន និងគណបក្សប្រឆាំងគឺមានបង្ហាញនៅក្នុងវិធីដែលមានសង្គតិភាពរបស់ពួកគេ និងមានឥទ្ធិពលទៅលើលទ្ធផលបោះឆ្នោតរបស់ពួកគេ។ ក្រុមអ្នកនយោបាយរដ្ឋាភិបាលដែលបែកបាក់គ្នា មិនអាចតំណាងប្រកបដោយប្រសិទ្ធភាពឡើយ អំពីគោលនយោបាយរបស់រដ្ឋាភិបាល។ គណបក្សប្រឆាំងដែលបានបែកបាក់គ្នាត្រង់ចំណុចសំខាន់ណាមួយនោះមិនអាចក្លាយជាជម្រើសមួយដែលអាចធ្វើទៅបាន សម្រាប់រដ្ឋាភិបាលនាពេលបច្ចុប្បន្ននេះឡើយ។

វិន័យក្នុងចំណោមក្រុមអ្នកនយោបាយ កើតឡើងចេញពីការចងក្រងក្រុមអ្នកនយោបាយនៅក្នុងចំណោមសមាជិកសភា។ ទាំងវិន័យ និងការចងក្រងក្រុមអ្នកនយោបាយបានធ្វើឱ្យក្រុមអ្នកនយោបាយខ្លាំង ដើម្បីបង្ហាញពីខ្លួនឯង និងអនុវត្តគំនិតរបស់ខ្លួន។ សមាជិកក្រុមអ្នកនយោបាយរៀបចំខ្លួនឯងទៅជាក្រុមមួយដែលផ្តល់នូវវណ្ណសិរ្សបង្រួបបង្រួមជាតិ។ ការធ្វើបែបនេះអាចធ្វើឱ្យមានសមត្ថភាពការងារនៃក្រុមអ្នកនយោបាយ។ការប្រឈមមុខគ្នាលើសំណួរនៃការប្រកាន់នយោបាយ គឺមានការលើកលែងទៅលើច្បាប់។ ដោយតាមរយៈក្រុមអ្នកនយោបាយ រដ្ឋសភាត្រូវបានបង្កើតឡើង។ កម្លាំងរបស់ក្រុមអ្នកយោបាយបង្កើតបានជាមូលដ្ឋានយុទ្ធសាស្រ្តសម្រាប់ការបង្កើតគណៈកម្មាធិការ ការបែងចែកប្រធាន សមាសភាពនៃក្រុមប្រឹក្សាកិត្តិយស និងថ្នាក់ដឹកនាំសភា។ ការគ្រប់គ្រងក្រុមអ្នកនយោបាយអាស្រ័យលើប្រធានក្រុមអ្នកនយោបាយ អ្នកគ្រប់គ្រងកិច្ចការសភា និងក្រុមប្រឹក្សាប្រតិបត្តិរបស់ពួកគេ។

តាមរយៈការងារសភារបស់ខ្លួន និងរណសិរ្សបង្រួបបង្រួមរបស់ខ្លួន ក្រុមអ្នកនយោបាយបង្កើតបុរេលក្ខខណ្ឌសំខាន់បំផុត សម្រាប់ភាពជោគជ័យរបស់គណបក្សខ្លួនក្នុងការបោះឆ្នោត តាមរយៈការបង្ហាញភាពអាចទុកចិត្តបាន និងអំណាច។ ក្រុមអ្នកនយោបាយ គឺជាស្ថាប័នស្មុគស្មាញ យ៉ាងហោចណាស់មានការប្ដេជ្ញាចិត្តប្រកាន់គំនិតកណ្ដាលដែរ។ ប៉ុន្តែ ពួកគេក៏តំណាងទិសដៅនយោបាយដ៏ច្រើនផងដែរ។ ការទទួលខុសត្រូវណាមួយដែលបង្ហាញពីសមាជិកភាពរបស់ក្រុមនេះ សមាជិកសភា ក្នុងនាមជា "ទាហានស្មោះត្រង់នឹងបក្ស" ឬជា "ជនឱកាសនិយមដែលសម្របខ្លួនបានល្អ" គឺមិនជាក់លាក់ទេ។ ឆន្ទៈក្នុងការសម្របសម្រួល និងភាពស្មោះត្រង់ក្នុងចំណោមសមាជិកសភាគឺជាមូលដ្ឋានសម្រាប់ "ការឯកភាពដោយស្ម័គ្រចិត្ត"។ រចនាសម្ព័ន្ធរបស់ក្រុមនេះ គឺធ្វើសេចក្ដីសម្រេចដែលអាចធ្វើទៅបាននៅក្នុងសភាទំនើប ក៏អាចផ្ដល់លទ្ធភាពដល់ការបែងចែកមុខងារដល់ក្រុមអភិបាល និងក្រុមប្រឆាំងរបស់ខ្លួនផងដែរ។

ជាទូទៅក្រុមអ្នកនយោបាយ មានការឧបត្ថម្ភគាំទ្រគ្រប់គ្រាន់ពីធនធានរដ្ឋ ធនធានបុគ្គល និងកំណត់សិទ្ធិ និងភារកិច្ចច្បាស់លាស់ដែលផ្ដល់លទ្ធភាពដល់ពួកគេអនុវត្តការងារ និងមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

ហេតុដូចនេះហើយ ជំនួយរបស់មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ នឹងផ្ដល់ការយល់ដឹងកាន់តែប្រសើរពីតួនាទី ការងារ ការគ្រប់គ្រងផ្ទៃក្នុង និងទំនាក់ទំនងផ្នែកច្បាប់របស់ក្រុមអ្នកនយោបាយ តាមរយៈការសិក្សាប្រៀបធៀប។ សូមថ្លែងអំណរគុណជាពិសេសដល់លោក **Allan Tram Sam** ចំពោះការចូលរួមជាយោបល់ និងការស្រាវជ្រាវល្អិតល្អន់នេះដែលបានធ្វើឱ្យការបោះពុម្ពផ្សាយនេះកាន់តែប្រសើរឡើង។

ភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤

**ដេនីស ស្រ៊ែយ៍**

តំណាងប្រចាំប្រទេស

មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ

ព្រះរាជាណាចក្រកម្ពុជា

# ឯកសារពិគ្រោះយោបល់សម្រាប់ការអភិវឌ្ឍគណបក្សនយោបាយ

## ការរៀបចំ និងការងាររបស់ក្រុមអ្នកនយោបាយក្នុងសភា

## ១. សេចក្តីផ្តើម៖ ប្រវត្តិដើម និងគោលការណ៍របស់ក្រុមអ្នកនយោបាយ

### ក. ប្រវត្តិសង្ខេបរបស់ក្រុមអ្នកនយោបាយ

ក្រុមអ្នកនយោបាយបានកើតចេញជារូបរាង ចាប់តាំងពីចុងសតវត្សទី១៨ ដែលជាផ្នែកមួយនៃការបង្កើតឡើងនូវប្រព័ន្ធសភា។ ជាដំបូង ពួកគេគ្រាន់តែមានចរិតលក្ខណៈជា "ការប្រមូលផ្តុំគ្នា" ក្រៅផ្លូវការរវាងសមាជិកសភាដែលមានបំណងផ្លាស់ប្តូរព័ត៌មានគ្នា អំពីកិច្ចការបច្ចុប្បន្នតែប៉ុណ្ណោះ។ នេះគឺជាករណីមួយសម្រាប់ «ក្លឹប» ក្នុងអំឡុងពេលបដិវត្តន៍របស់ប្រទេសបារាំងដែលជាឧទាហរណ៍មួយ។ ការប្រមូលផ្តុំនេះក្រោយមក បានក្លាយទៅជាការជួបប្រជុំមួយដែលមានរចនាសម្ព័ន្ធ និងមានជំនាញវិជ្ជាជីវៈជាងមុន នៅពេលដែលការបោះឆ្នោតទ្រង់ទ្រាយធំតាមបែបលទ្ធិប្រជាធិបតេយ្យមានការរីកចម្រើនខ្លាំង។ មាគ៌ាឆ្ពោះទៅកាន់ការបោះឆ្នោតជាសកល បានធ្វើឲ្យបេក្ខជនដែលនឹងអាចឈរឈ្មោះបោះឆ្នោតនាពេលអនាគត ត្រូវការមធ្យោបាយទំនាក់ទំនង ជាមួយប្រជាពលរដ្ឋដែលមានប្រសិទ្ធភាពជាងមុន ទាំងការរៀបចំ និងជំនួយបច្ចេកទេស ត្រូវមានលក្ខណៈកាន់តែប្រសើរជាងមុនដែរ។ យុទ្ធនាការល្អមួយនេះ បានក្លាយទៅជាតម្រូវការមុនមួយ ដើម្បីឈ្នះការបោះឆ្នោត។ គណបក្សនយោបាយ បានផ្តល់ជូនគាត់នូវសេចក្តីថ្លែងការណ៍នយោបាយ ការដាក់ស្លាកយីហោគណបក្ស និងត្រូវធានាថា បេក្ខជនដែលនឹងត្រូវឈរឈ្មោះឲ្យគេបោះឆ្នោត ត្រូវមានគុណ

សម្បត្តិចាំបាច់គ្រប់គ្រាន់។ស្របពេលជាមួយគ្នានេះ រចនាសម្ព័ន្ធក្នុងការសម្រប សម្រួលសមាជិក សភាត្រូវការពារផលប្រយោជន៍ដូចគ្នានៅក្នុងសភាដែរ ដើម្បីឲ្យក្លាយជាវិជ្ជាជីវៈច្រើនជាងមុន។ សព្វថ្ងៃនេះ ស្ថាប័នទាំងនេះ បានក្លាយទៅជាសមាសធាតុពិសេសទូទៅមួយ នៅក្នុងរបបប្រជាធិបតេយ្យសេរីទំនើប ពោលគឺរបបដែលក្នុងនោះ គណបក្សនយោបាយត្រូវបានបោះឆ្នោត ដោយផ្អែកលើកម្មវិធីនយោបាយមូលដ្ឋានមួយ និងទទួលបានអាណត្តិក្នុងការបើកវេទិកាគោលនយោបាយគណបក្សរបស់ពួកគេ ឲ្យក្លាយទៅជាគោលនយោបាយផ្លូវការរបស់រដ្ឋាភិបាល។

អ្នកបោះឆ្នោតជ្រើសរើសសមាជិកសភា គឺអាស្រ័យទៅតាមមនោគមវិជ្ជា និងកម្មវិធីនយោបាយរបស់គណបក្ស ដែលពួកគេជាសមាជិកនៅក្នុងបក្សនោះ ឬគណបក្សដែលពួកគេស្រឡាញ់ចូលចិត្ត។ ការបោះឆ្នោតឲ្យគណបក្សមួយជំនួសដោយការបោះឆ្នោតឲ្យបុគ្គលម្នាក់ ជាតំណាងពិតប្រាកដនៃឆន្ទៈរបស់ប្រជាពលរដ្ឋនៅក្នុងរដ្ឋសភា។ គណបក្សដែលឈ្នះការបោះឆ្នោតនឹងទទួលបានភាពស្របច្បាប់ និងមធ្យោបាយគ្រប់គ្រាន់ ក្នុងការអនុវត្តសំណើដែលមានសេចក្តីពិស្តារចែងនៅក្នុងគោលនយោបាយ។ ក្នុងពេលជាមួយគ្នានេះ អាចធ្វើឲ្យមានស្ថិរភាពសភានៅក្នុងប្រទេស ក្នុងន័យនេះ គឺថាជីវិតនយោបាយកាន់តែអាចទស្សន៍ទាយបានប្រសើរជាងមុន រដ្ឋាភិបាលដឹងថា -ភាគច្រើននៃពេលវេលា- វានឹងមានការគាំទ្រភាគច្រើន មកលើគោលនយោបាយរបស់ខ្លួន ទាំងនេះហើយវារឹតតែជួយបង្កើនគណនេយ្យភាព តាមបែបប្រជាធិបតេយ្យឲ្យកាន់តែប្រសើរឡើង វាកាន់តែងាយស្រួលសម្រាប់អ្នកបោះឆ្នោត ក្នុងការវិនិច្ឆ័យថាតើបេក្ខជនជាប់ឆ្នោតបានបំពេញតាមការសន្យារបស់ខ្លួនដែរឬទេ ហើយបង្ហាញពីការពេញចិត្ត ឬមិនពេញចិត្តរបស់ពួកគាត់ ជាមួយនឹងលទ្ធផលនៅពេលបោះឆ្នោតលើកក្រោយទៀត។

ក្នុងប្រព័ន្ធបែបនេះ មានសមាជិកសភាជាច្រើន ចែករំលែកគំនិតដូចគ្នាធ្វើការរួបរួមគ្នា ពួកគេក៏មានកាលានុវត្តភាពកាន់តែច្រើន ដើម្បីអនុវត្តគោលនយោបាយដែលទាក់ទាញ ឲ្យប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសពួកគេ។ ការ

បកស្រាយពន្យល់ទាំងនេះ គឺដោយហេតុថា សមាជិកសភាមានគំនិតដូចគ្នា បានដឹងពីតម្រូវការទាំងអស់នៃប្រវត្តិសាស្ត្ររបស់ប្រព័ន្ធសភាទំនើប ក្នុងការប្រមូលផ្តុំ និងក្នុងការសម្របសម្រួលសកម្មភាពរបស់ពួកគេ។ ទម្រង់នៃការរៀបចំជួបជុំពេលបច្ចុប្បន្ននេះ គឺជាអ្វីដែលយើងនឹងពិភាក្សានៅក្នុងឯកសារនេះនៅក្រោមក្រុមអ្នកនយោបាយ។ **ក្រុមអ្នកនយោបាយ ត្រូវបានកំណត់ថាជាក្រុមដែលរៀបចំឡើងរបស់បុគ្គលនៃស្ថាប័នតំណាង ដែលបានជាប់ឆ្នោតនៅក្រោមស្លាកគណបក្សដូចគ្នា ឬស្ថិតនៅក្រោមស្លាកគណបក្សផ្សេងគ្នាដែលមិនបានប្រកួតប្រជែងគ្នា'។**

## ខ. ភាពពាក់ព័ន្ធនៃក្រុមអ្នកនយោបាយសព្វថ្ងៃ

ក្រុមអ្នកនយោបាយបានរីកសាយភាយនៅពាសពេញពិភពលោក ហើយសព្វថ្ងៃនេះមានឈ្មោះ និងរចនាសម្ព័ន្ធខុសៗគ្នា និងមានឯករាជ្យតិច ឬច្រើនដោយធៀបទៅនឹងស្ថាប័នគណបក្សរបស់ខ្លួន។ ក្រុមអ្នកនយោបាយមួយចំនួន ត្រូវបានកំណត់ដោយច្បាប់ (ដូចជាក្រុមអ្នកនយោបាយ នៅក្នុងសភាសហព័ន្ធអាល្លឺម៉ង់) ខណៈក្រុមអ្នកនយោបាយខ្លះទៀតរីករាយនឹងសេរីភាព ហើយមិនបានចែងនៅក្នុងអត្ថបទច្បាប់នៃប្រទេសរបស់ខ្លួនឡើយ (ឧទាហរណ៍ គណបក្សសភាចក្រភពអង់គ្លេសនៅក្នុងសភាជាន់ទាបរបស់ខ្លួន)។ ក្រុមអ្នកនយោបាយចាំបាច់មិនត្រូវរៀបរាប់យ៉ាងជាក់លាក់ ដោយច្បាប់ដែលមានជាធរមាន នោះទេ។ ក្រុមអ្នកនយោបាយមួយអាចដំណើរការបាន ប្រសិនបើសមាជិកសភាមួយចំនួនមាន ចំណាប់អារម្មណ៍បង្កើតក្រុមអ្នកនយោបាយនោះឡើង និងដំរាបណាមិនធ្វើអ្វី ផ្ទុយពីវិធានដែលចែងដោយច្បាប់របស់ប្រទេសនោះ។

*ក្រុមអ្នកនយោបាយចាំបាច់មិនត្រូវរៀបរាប់យ៉ាងជាក់លាក់ដោយច្បាប់ដែលមានជាធរមាននោះទេ។*

ទម្រង់របស់ក្រុមអ្នកនយោបាយទទួលបាន និងប្រសិទ្ធិភាពអំណាចរបស់ខ្លួន គឺអាស្រ័យយ៉ាងខ្លាំងលើរដ្ឋធម្មនុញ្ញរបស់ប្រទេសនេះ លើស្ថានភាពនយោ

១ នៅទីនេះអ្នកនិពន្ធយកការអនុវត្តនិយមន័យដែលផ្តល់ដោយ Knut Heidar និង Ruude Koole នៅក្នុងការសិក្សាដែលទទួលបានការផ្តល់សិទ្ធិអំពីប្រធានបទខាងលើ។ Cf K. Heidar និង R. Koole, ed., *ក្រុមគណបក្សសភានៅក្នុងប្រជាធិបតេយ្យអឺរ៉ុប គណបក្សនយោបាយនៅក្រោយទ្វារដែលបិទជិត* (ទីក្រុងឡុង៖ រ៉ូលេជ ឆ្នាំ២០០០), xiii

បាយបច្ចុប្បន្ន លើប្រវត្តិសាស្ត្រ និងប្រពៃណីនយោបាយ។ ឧទាហរណ៍ ក្រុមអ្នកនយោបាយនៃគណបក្សអភិរក្សនិយមរបស់ចក្រភពអង់គ្លេស មានប្រវត្តិការទាក់ទងនឹងស្វ័យភាព និងមានអំណាចពេញលេញ ហើយនិងចូលរួមនៅក្នុងការជ្រើសរើសថ្នាក់ដឹកនាំរបស់គណបក្ស។ ផ្ទុយទៅវិញក្រុមសភារបស់គណបក្សសង្គមនិយមនៅក្នុងប្រទេសបារាំងឃើញថាមានការលំបាកក្នុងការតទល់នឹងគណបក្សរបស់ខ្លួន និងមិនមានសម្លេងជាពិសេសក្នុងការជ្រើសរើសថ្នាក់ដឹកនាំលើកក្រោយបានឡើយ។

បើទោះបីជាវប្បធម៌ និងប្រវត្តិសាស្ត្រ អាចធ្វើទៅបានជាពិសេសក៏ដោយ **ក្រុមអ្នកនយោបាយ ជាទូទៅមានភាពស្របច្បាប់ដូចខាងក្រោម៖**

- ពួកគេប្រតិបត្តិការដោយផ្សារភ្ជាប់រវាងសភាគណបក្សនយោបាយ និងប្រជាពលរដ្ឋ។ កត្តានេះ ពិតជាចាំបាច់សម្រាប់ជីវភាពរបស់ប្រព័ន្ធសភាទំនើប។ ជាពិសេស អនុញ្ញាតឲ្យគណបក្សនយោបាយ និងសមាជិកសភាធ្វើសកម្មភាពស្របពេលគ្នាដោយខ្លួនឯង និងស្របតាមឆន្ទៈរបស់អ្នកបោះឆ្នោត។
- ការងាររបស់ក្រុមអ្នកនយោបាយ មានសារៈសំខាន់សម្រាប់ស្ថិរភាពសភា និងដំណើរប្រព្រឹត្តទៅនៃជីវិតនយោបាយរបស់ប្រទេសមួយទាំងមូល។
- ក្រុមអ្នកនយោបាយត្រូវពង្រឹងប្រសិទ្ធិភាពគណបក្សនយោបាយ ការសម្របសម្រួលសកម្មភាពរបស់គណបក្ស និងផ្តល់ឲ្យគណបក្សនូវឧបករណ៍ថ្មីៗដើម្បីបំពេញអាណត្តិរបស់ខ្លួនឲ្យបានកាន់តែប្រសើរ។ ដូច្នេះការផ្តល់ឲ្យពួកគាត់មានកាលានុវត្តភាពកាន់តែប្រសើរឡើង ដើម្បីដណ្តើមយកអំណាច-ឬរក្សាអំណាចរបស់ខ្លួន។

*ដូចការកំណត់របស់ក្រុមអ្នកនយោបាយបានបង្ហាញថាពួកគេគឺមិនមានតែនៅក្នុងសភាតែមួយនោះទេ*

បន្ថែមលើនេះទៀត ការកើនឡើងនៃកម្រិតវិមជ្ឈការនៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីទំនើប បានផ្តល់នូវវលកទីពីរក្នុងការសាយភាយនៃក្រុមអ្នកនយោបាយ។ តាមការពិត ដូចការកំណត់របស់ក្រុមអ្នកនយោបាយបានបង្ហាញថាពួកគេ គឺមិនមានតែនៅក្នុងសភាតែមួយនោះទេ ប៉ុន្តែក៏មាននៅក្នុង "ស្ថាប័នតំណាង" ទូទៅផងដែរ។ នេះមានន័យថា ការប្រព្រឹត្តទៅរបស់ស្ថាប័នទាំងអស់

គឺស្រដៀងគ្នាទៅនឹងសភាដែរ (ស្ថាប័ននៅមូលដ្ឋាន ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក/ក្រុមប្រឹក្សាឃុំ-សង្កាត់។ល។) អាចនឹងប្រើប្រាស់ក្រុមអ្នកនយោបាយដោយអនុវត្តតាមគំរូដូចៗគ្នា និងមានផលប្រយោជន៍ដូចគ្នានឹង សភាបានអនុវត្តដែរ។ ក្នុងនាមជាសភានៅថ្នាក់ក្រោមជាតិ -ជាការពិតណាស់- មានធនធានតិច ដែលបានមកពីការរួមបញ្ចូលគ្នារបស់ក្រុមអ្នកនយោបាយ អាចប្រឈមទៅនឹងការកម្រិត និងការបែងចែកការងាររបស់ពួកគេ ច្រើនជាងក្រុមអ្នកនយោបាយនៅថ្នាក់ជាតិ។ មុខងារ និងអត្ថប្រយោជន៍ដ៏សំខាន់ ដែលក្រុមអ្នកនយោបាយហុចផលឲ្យ គឺនៅតែដូចគ្នា។

*ក្រុមអ្នកនយោបាយដើរតួសំខាន់ណាស់ក្នុងការបន្ត និងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកតំណាងនៅមូលដ្ឋាន និងម្ចាស់ឆ្នោតរបស់ខ្លួន។*

តម្រូវការសម្រាប់ការសម្របសម្រួលក្នុងចំណោមអ្នកតំណាងនៅមូលដ្ឋាន (ក្រុមប្រឹក្សាមូលដ្ឋាន ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក / ក្រុមប្រឹក្សាឃុំ-សង្កាត់) និងស្ថាប័នគណបក្សនយោបាយពាក់ព័ន្ធនៅក្នុងមូលដ្ឋានរបស់ខ្លួន មានសារៈសំខាន់សម្រាប់ប្រព័ន្ធលទ្ធិប្រជាធិបតេយ្យ ដូចជានៅថ្នាក់ជាតិដែរ (សូមមើល




រូបភាព១៖ រចនាសម្ព័ន្ធរបស់ក្រុមគណបក្សនយោបាយ

រូបភាពទី១)។ ក្រុមអ្នកនយោបាយដើរតួសំខាន់ណាស់ក្នុងការបន្ត និងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងផ្សារភ្ជាប់ទំនាក់ទំនងរវាងអ្នកតំណាងនៅមូលដ្ឋាន និងម្ចាស់ឆ្នោតរបស់ខ្លួន។ អនុសាសន៍ទាំងអស់មាននៅក្នុង*សេចក្តីណែនាំនេះ* ដែលអនុវត្តជាបន្តបន្ទាប់ចំពោះក្រុមអ្នកនយោបាយនៅគ្រប់កម្រិតទាំងអស់ ហើយការទាក់ទងទៅនឹងអនុសាសន៍ទាំងនេះ គឺអាស្រ័យលើទំហំក្រុមអ្នកនយោបាយទាំងនោះ។

# ២. តើត្រូវបង្កើតក្រុមអ្នកនយោបាយដោយរបៀបណា? ជំហានជាមូលដ្ឋាន

## ក. សេចក្តីថ្លែងការណ៍នយោបាយ

សំខាន់ទីមួយនោះ គឺក្រុមអ្នកនយោបាយ ជាក្រុមនៃអង្គភាពតំណាងដែលមានគំនិតមួយដូចៗគ្នា។ ដូច្នេះពួកគេទាំងអស់យល់ព្រមលើសេចក្តីថ្លែងការណ៍នយោបាយដែលជាឆ្អឹងខ្នងរបស់ក្រុមអ្នកនយោបាយ។

សេចក្តីថ្លែងការណ៍នយោបាយ ដែលនឹងក្លាយជាសេចក្តីប្រកាសរបស់ក្រុមនៅក្នុងកិច្ចប្រជុំមួយ ត្រូវបានគេធ្វើឡើងជាសាធារណៈ និងអនុវត្តមិនផ្ទុយពីសេចក្តីប្រកាសរបស់គណបក្សកណ្តាលឡើយ។ សេចក្តីប្រកាសនេះ គឺជាមូលដ្ឋានសម្រាប់ការងាររបស់ក្រុមអ្នកនយោបាយនៅក្នុងសភា។

**ឧទាហរណ៍នៃសេចក្តីថ្លែងការណ៍នយោបាយ/បទបញ្ជាផ្ទៃក្នុង។**

## ខ. សមាជិកភាព

ពេលបង្កើតក្រុមអ្នកនយោបាយ សារៈសំខាន់នោះ គឺតម្រូវឲ្យកំណត់ជាដំបូងនូវលក្ខណៈសម្បត្តិរបស់អ្នកដែលនឹងអាចក្លាយជាសមាជិក។ ជាការពិត លក្ខខណ្ឌដែលមិនអាចជៀសផុតនោះ គឺអ្នកតំណាងដែលត្រូវបានគេបោះឆ្នោតពាក់ព័ន្ធទៅនឹងសភា មានដូចជា សមាជិក សមាជិកាសភា ឬក្រុមប្រឹក្សាក្រុង។

*អ្នកតំណាងដែលត្រូវបានគេ បោះឆ្នោតពាក់ព័ន្ធទៅនឹងសភា*

លើសពីវិធានជាមូលដ្ឋានដែលជាលក្ខខណ្ឌវិនិច្ឆ័យ ក្នុងការជ្រើសរើសសមាជិកភាពរបស់ក្រុមអ្នកនយោបាយ ក៏អាចនឹងរងឥទ្ធិពលដោយសារ បទប្បញ្ញត្តិដែលមានជាធរមានរបស់ប្រទេសនេះផងដែរ។ ឧទាហរណ៍ អត្តិភាព និង

មុខងារក្រុមអ្នកនយោបាយនៅក្នុងប្រទេសអាល្លឺម៉ង់ ត្រូវបានត្រួតពិនិត្យយ៉ាងតឹងរឹងដោយច្បាប់មួយចំនួនរបស់ប្រទេសនេះ។ ការប៉ះពាល់ដល់ស្ថាប័នរបស់ក្រុមអ្នកនយោបាយអាល្លឺម៉ង់នោះគឺ៖ ច្បាប់ស្តីពីសមាជិកសភា សភាសហព័ន្ធ (Abgeordnetengesetz)[២] វិធាននៃនីតិវិធី របស់សភាសហព័ន្ធអាល្លឺម៉ង់[៣] រដ្ឋធម្មនុញ្ញ (Grundgesetz) ច្បាប់ស្តីពីការបោះឆ្នោតសហព័ន្ធ ច្បាប់ស្តីពីគណបក្សនយោបាយ និងសេចក្តីសម្រេចជាង ២០ទៀត របស់តុលាការធម្មនុញ្ញសហព័ន្ធ។ សមាជិកសភាត្រូវប្រាកដថា ពួកគេប្រមូល បានសម្លេងយ៉ាងតិច៥%នៃអសនៈសរុបនៅក្នុងសភា ដើម្បីបង្កើតក្រុមអ្នកនយោបាយមួយបាននៅក្នុងសភាសហព័ន្ធ។ ច្បាប់គ្រាន់តែចែងថា គណបក្សនយោបាយចូលរួមជាមួយក្រុមអ្នកនយោបាយ មិនអាចប្រកួតប្រជែងគ្នានៅក្នុងការបោះឆ្នោតបានឡើយ។ គណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រឹស្ត គណបក្សសហព័ន្ធសង្គមគ្រឹស្ត ក្រុមអ្នកនយោបាយ[៤] ឧទាហរណ៍ សមាជិកសភាទាំងនោះ បានប្រមូលផ្តុំគ្នាមកពីគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រឹស្តអាល្លឺម៉ង់និងគណបក្សសហព័ន្ធសង្គមគ្រឹស្ត ដែលមកពីរដ្ឋសហព័ន្ធបាវ៉ារៀ។ ក្រោយមក ពួកគេគ្រាន់តែតំណាងឲ្យបេក្ខជនក្នុងតំបន់នៃរដ្ឋសហព័ន្ធបាវ៉ារៀ របស់ប្រទេសអាល្លឺម៉ង់តែប៉ុណ្ណោះ ខណៈដែលគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រឹស្ត ដើរតួជាតំណាងឲ្យបេក្ខជននៅគ្រប់តំបន់នៃប្រទេសអាល្លឺម៉ង់ទាំងមូល។ ដូច្នេះហើយគណបក្សទាំងពីរមិនមែនជាដៃគូប្រកួតប្រជែងគ្នាទេ មិនតែប៉ុណ្ណោះ បានចូលរួមនៅក្នុងក្រុមអ្នកនយោបាយតែមួយជាមួយគ្នាផង។

នៅក្នុងន័យនេះ វិធានទាំងនេះអាចខុសគ្នាពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត។ ក្រុមអ្នកនយោបាយនៅក្នុងប្រទេសបារាំងអាចបង្កើតឡើងមកពីគណបក្សនយោបាយខុសៗគ្នា សូម្បីតែគណបក្សទាំងនេះប្រកួតប្រជែងគ្នានៅក្នុងការបោះឆ្នោតក៏ដោយ។ ទោះបីជាយ៉ាងនេះក៏ដោយ សម្ព័ន្ធភាពនយោ

២ មើលឧបសម្ពន្ធ១៖ សម្រង់ច្បាប់ស្តីពីសមាជិកសភាសហព័ន្ធអាល្លឺម៉ង់

៣ មើលឧបសម្ពន្ធ២៖ សម្រង់បទបញ្ជាផ្ទៃក្នុងរបស់សភាសហព័ន្ធអាល្លឺម៉ង់

៤ សម្រាប់ឧទាហរណ៍ឧបសម្ពន្ធ៣៖ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមអ្នកតំណាងរាស្ត្រ CDU/CSU ក្នុងសភាសហព័ន្ធអាល្លឺម៉ង់ នីតិកាលទី១៧ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១០

បាយរវាងគណបក្សទាំងនេះ ត្រូវបានធ្វើឡើងដោយមានការប្រុងប្រយ័ត្នបំផុត។

ក្រៅពីសមាជិក ចំពោះអ្នកដែលអាចក្លាយជាសមាជិកបាន គេត្រូវតែសម្រេចចិត្តថាពួកគេអាចក្លាយជាសមាជិកដោយរបៀបណា? តើអ្នកតំណាងម្នាក់ក្លាយជាសមាជិកពិតប្រាកដមួយ តាមរយៈសម្ព័ន្ធភាពនយោបាយរបស់គាត់បានឬទេ? ឧទាហរណ៍ នៅក្នុងរដ្ឋសភាប្រទេសអង់គ្លេស ដោយសារតែគណបក្សប្រជាធិបតេយ្យសេរីនិយមបច្ចុប្បន្ន ការគ្រប់គ្រងនៅក្រោមសម្ព័ន្ធភាពជាមួយនឹងគណបក្សអភិរក្សនិយម ដូច្នេះសមាជិកសភាមកពីគណបក្សប្រជាធិបតេយ្យសេរីនិយម បានជ្រើសរើសនៅក្រោមស្លាកគណបក្សប្រជាធិបតេយ្យសេរីនិយមដោយស្វ័យប្រវត្តិ ដើម្បីបានក្លាយជាសមាជិកម្នាក់នៃក្រុមនយោបាយសភាភាគច្រើន។ សកម្មភាពទាំងនេះគឺធ្វើឡើងដោយស្វ័យប្រវត្តិ និងនៅតែមានសុពលភាពរហូតដល់ពេលបោះឆ្នោតមួយ នៅក្នុងក្រុមអ្នកនយោបាយសភាបានសម្រេចចិត្ត។ យន្តការនេះ គឺអាចធ្វើទៅបាននៅពេលណាដែលភាពជាដៃគូនយោបាយរឹងមាំ និងត្រូវបានបញ្ជាក់យ៉ាងច្បាស់ ដូចគ្នាទៅនឹងយន្តការនៅក្នុងចក្រភពអង់គ្លេសដែរ។

ទីបញ្ចប់ជាការធម្មតាក្នុងការស្វែងរកក្រុមអ្នកនយោបាយដែលបានប្រមូលផ្តុំ**សមាជិកឯករាជ្យមួយ** (សមាជិកដែលគ្មានបំណងចងសម្ព័ន្ធភាពជាមួយគណបក្សនយោបាយណាមួយជាក់លាក់)។មុខងាររបស់ក្រុមអ្នកនយោបាយប្រភេទនេះ ដូចគ្នានឹងក្រុមអ្នកនយោបាយដទៃទៀតដែរ លើកលែងតែ ករណីដែលពួកគេមិនដាក់អនុសាសន៍នៃការបោះឆ្នោត ទៅលើសមាជិករបស់ខ្លួន។ ក្រុមអ្នកនយោបាយឯករាជ្យភាគច្រើន មានវត្តមាននៅក្នុងអង្គនីតិប្បញ្ញត្តិដែលគាំទ្របច្ចេកទេស និងកូតាពេលវេលានិយាយត្រូវបានរៀបចំឲ្យក្នុងចំណោមក្រុមអ្នកនយោបាយ ស្របតាមចំនួនអសនៈដែលពួកគេមាននៅក្នុងសភា (ជំនួសឲ្យការបែងចែកដោយផ្ទាល់ទៅសមាជិកដែលមានក្នុងអង្គប្រជុំ)។ ដោយការប្រមូលផ្តុំនៅក្រោមស្លាកឈ្មោះ "ឯករាជ្យ" សមាជិកត្រូវប្រាកដថា ពួកគេនឹងត្រូវបានគេបែងចែកធនធាន និងពេលវេលានិយាយដោយគ្មានរើសអើងថាពួកគេមកពីគណបក្សណា។

## គ. អង្គការលេខផ្ទៃក្នុងរបស់ក្រុមអ្នកនយោបាយ

*សារៈសំខាន់នោះ គឺត្រូវមានឋានានុក្រមច្បាស់លាស់ និងការយល់ដឹងអំពីតួនាទីរបស់សមាជិកនីមួយៗ*

ដំណាក់កាលទីពីរ ក្នុងការបង្កើតក្រុមអ្នកនយោបាយមួយ គឺត្រូវកំណត់ អំពីការទទួលខុសត្រូវនៅក្នុងក្រុម។ សារៈសំខាន់នោះ គឺត្រូវមានឋានានុក្រមច្បាស់លាស់ និងការយល់ដឹងអំពីតួនាទីរបស់សមាជិកនីមួយៗ៖

- ទីមួយ ការសំខាន់នោះគឺត្រូវដឹងថា នរណាជាអ្នកនិយាយចុងក្រោយក្នុងករណីដែលមានការខ្វែងគំនិតគ្នានៅក្នុងចំណោមសមាជិក។ នេះគឺជាវិធីមួយ ដែលជាការងាររបស់ក្រុមអ្នកនយោបាយត្រូវអនុវត្តន៍ឲ្យដំណើរបានរលូន និងមានប្រសិទ្ធភាព។
- ទីពីរ គឺថាសមាជិកទាំងអស់ត្រូវមានសមត្ថភាពឲ្យសមនឹងតួនាទីរបស់ខ្លួន និងគាត់ត្រូវប្តេជ្ញាចិត្តទៅនឹងការងាររបស់គាត់។

រចនាសម្ព័ន្ធរបស់ក្រុមអ្នកនយោបាយ ដែលបានពន្យល់ខាងក្រោមនេះ គឺអាចអនុម័តបាន ដោយយោងតាមចំនួនរបស់សមាជិករបស់ក្រុម។ ខណៈនៅក្នុងផលប្រយោជន៍របស់ក្រុមធំ ការបែងចែកផ្នែករងជាច្រើនទៀតក្នុងការអភិវឌ្ឍនោះ ដែលផ្នែកនីមួយៗត្រូវទទួលខុសត្រូវដោយប្រុងប្រយ័ត្នជាមួយនាយកដ្ឋានជំនាញរបស់រដ្ឋាភិបាល ហើយឯក្រុមតូចៗវិញដែលគ្មានលទ្ធភាពនោះ ត្រូវទទួលយកការបែងចែកនៅតាមផ្នែករង ដោយផ្តោតទៅលើសកម្មភាពរបស់នាយកដ្ឋានរដ្ឋាភិបាលនីមួយៗ។ ដូច្នេះហើយ ក្រុមតូចៗនេះត្រូវជ្រើសយកការពិនិត្យតាមដានសកម្មភាព ឧទាហរណ៍របស់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដោយដំណើរការនេះត្រូវអនុវត្តន៍ទន្ទឹមគ្នាដែលជំនួសឲ្យដោយការបង្កើតអង្គភាពដាច់ដោយឡែកៗពីគ្នា។ ចំនួនដ៏ច្រើនដែលមាននៅក្នុងក្រុម ការបែងចែកជំនាញតាមផ្នែក តម្រូវការបុគ្គលិកគួរតែមានច្រើនដែរ។

*ចំនួនដ៏ច្រើនដែលមាននៅក្នុងក្រុម ការបែងចែកជំនាញតាមផ្នែក តម្រូវការបុគ្គលិកគួរតែមានច្រើនដែរ។*

## ប្រធាន និងអនុប្រធាន ឬនាយក(នាយិកា) និងនាយករង(នាយិការង)

*ប្រធានតំណាងឲ្យក្រុមអ្នកនយោបាយនៅក្នុងកិច្ចប្រជុំសំខាន់ៗ និងមានសិទ្ធិដឹកនាំនីតិវិធី*

តួនាទីរបស់ប្រធានក្រុមអ្នកនយោបាយ គឺសំខាន់ណាស់។ ប្រធានតំណាងឲ្យក្រុមអ្នកនយោបាយនៅក្នុងកិច្ចប្រជុំសំខាន់ៗ ដូចជាសន្និសីទប្រធាន[៥] ដែលក្រុមរបស់ប្រធានៗ ជួបប្រជុំគ្នាដើម្បីបង្កើតរបៀបវារៈនៃកិច្ចប្រជុំសភាសម្រាប់សប្តាហ៍ខាងមុខ (មានដូចជា បទបញ្ជា បទប្បញ្ញត្តិ រយៈពេលប្រជុំ។ល។) ប្រធាន ក៏មានសិទ្ធិពិសេសលើនីតិវិធីផងដែរ ឧទាហរណ៍ នៅក្នុងសភាជាតិប្រទេសបារាំង ប្រធានក្រុមអ្នកនយោបាយ អាចស្នើឡើងឲ្យបង្កើតគណៈកម្មាធិការសម្រាប់ការសួរចម្លើយសភា ជាមួយនឹងសិទ្ធិពិសេសក្នុងការស៊ើបអង្កេតបញ្ហាសំខាន់ណាមួយជាដើម។ ប្រធាននេះ ក៏អាចស្នើឲ្យប្រធានសភាព្យួរទុកកិច្ចប្រជុំកំពុងដំណើរការ ដើម្បីពិភាក្សាបញ្ហាបន្ទាន់ជាមួយក្រុមអ្នកនយោបាយបានដែរ។ សំណើបច្ចេកទេសផ្សេងទៀតក៏អាចស្នើឡើងបានដែរ។ លើសពីនេះទៀត ក្រុមអ្នកនយោបាយបក្សប្រឆាំង មានសិទ្ធិក្នុងការសម្រេចលើរបៀបវារៈរបស់កិច្ចប្រជុំរៀងរាល់មួយខែម្តង។ បុព្វសិទ្ធិជាច្រើនត្រូវបានផ្តល់ឲ្យបក្សប្រឆាំង អាស្រ័យលើស្ថានការណ៍ប្រទេសនីមួយៗ។ នៅក្នុងប្រទេសបង់ក្លាដែស មេដឹកនាំ និងមេដឹកនាំរងរបស់គណបក្សប្រឆាំងទទួលបានការយកចិត្តទុកដាក់ជាពិសេស។ ពួកគេត្រូវទទួលបានកន្លែងការិយាល័យនៅក្នុងអង្គ នីតិប្បញ្ញត្តិ និងមានលេខាផ្ទាល់ខ្លួន ហើយនិងមានសិទ្ធិក្នុងការស្នើសុំ ដើម្បីទទួលបានឯកសារ និងទិន្នន័យដែលធម្មតាវាមិនមែនសម្រាប់សាធារណជនទូទៅ និងសមាជិកសភាទេ។

ដោយអាស្រ័យលើស្ថានការនយោបាយ និងទម្លាប់នៃប្រទេស អ្នកដឹកនាំនៃក្រុមអ្នកនយោបាយមួយ អាចត្រូវបានជ្រើសរើសដោយសេរី ដោយសមាជិករបស់ខ្លួន ឬនៅក្នុងការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយនឹងអ្នកដឹកនាំរបស់គណបក្ស។ ជាញឹកញាប់មានការចរចាយ៉ាងខ្លាំងនៅពីក្រោយការបិទទ្វារ

៥ សន្និសីទប្រធានជាធម្មតារួមបញ្ចូលប្រធាន ឬប្រធានសភា និងអនុប្រធានរដ្ឋសភា ដោយមានប្រធាន និងអនុប្រធានគណកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងប្រធាន និងអនុប្រធានក្រុមគណបក្ស។

រវាងភាគី និងក្រុមអ្នកនយោបាយក្នុងការសម្រេចចិត្តថានរណាដែលនឹងដឹកនាំក្រុមនៅក្នុងសភា។ ប្រធានក្រុមអ្នកនយោបាយនេះ គឺកម្រធ្វើជាប្រធាននៃគណបក្ស ឬរបស់គណបក្សទាំងមូលណាស់។ នៅចក្រភពអង់គ្លេសផ្ទុយមកវិញ ដែលក្រុមអ្នកនយោបាយត្រូវបានគ្រប់ដណ្តប់ដោយអង្គការបក្សដែលពួកមេដឹកនាំនៃគណបក្សសភាដ៏សំខាន់ទាំងពីរនេះ ក្លាយជាមេដឹកនាំនៃគណបក្សរបស់ខ្លួនដោយស្វ័យប្រវត្តិ។ ហេតុដូច្នេះហើយ សមាជិកនៃសភាមានសិទ្ធិទាំងស្រុងដើម្បីរើសមេដឹកនាំរបស់ពួកគេ។

មាននីតិវិធីពីរយ៉ាង ដើម្បីជ្រើសរើសប្រធានរបស់ក្រុមអ្នកនយោបាយ។ សមាជិកនៃក្រុមអ្នកនយោបាយម្នាក់ៗ អាចបោះឆ្នោតដោយសេរីក្នុងការ សម្រេចជ្រើសរើសអ្នកដែលនឹងដឹកនាំពួកគេ ឬប្រសិនបើមេដឹកនាំនោះ ត្រូវបានជ្រើសរើសដោយគណបក្ស អញ្ចឹងសមាជិកទាំងអស់នោះ ត្រូវតែបោះឆ្នោត ដើម្បីបញ្ជាក់ពីការយល់ព្រមរបស់ពួកគេ ក្នុងការទទួលយកបេក្ខជនដែលស្នើឡើងដោយគណបក្ស។ វិធីមួយណាក៏បានក្នុងចំណោមវិធីទាំងពីរនោះ ក្នុងការក្លាយជាប្រធានគឺ៖

*ប្រធានត្រូវគោរព និងយល់ព្រមដោយមតិភាគច្រើន និងត្រូវមានបទពិសោធន៍នយោបាយគ្រប់គ្រាន់ និងគុណសម្បត្តិចាំបាច់ក្នុងការដឹកនាំក្រុមអ្នកនយោបាយ*

- ទីមួយ គឺត្រូវគោរព និងយល់ព្រមដោយមតិភាគច្រើនរបស់សមាជិកក្រុមអ្នកនយោបាយ។ ប្រសិនបើមេដឹកនាំទំនងជាមិនអាចទទួលបានភាពស្របច្បាប់គ្រប់គ្រាន់ទេនោះ វានឹងមានហានិភ័យ ដែលក្រុមអ្នកនយោបាយនឹងត្រូវបែងចែកជាពីរផ្នែកផ្សេងគ្នា នៃក្រុមអ្នកនយោបាយដែលមាននិន្នាការខុសៗគ្នា ដែលធ្វើឱ្យអន្តរាយដល់ប្រសិទ្ធភាព និងសមត្ថភាពរបស់ក្រុម ក្នុងការសម្រេចគោលដៅរបស់ខ្លួន។
- ទីពីរ លក្ខខណ្ឌវិនិច្ឆ័យសំខាន់ គឺត្រូវមានបទពិសោធន៍នយោបាយគ្រប់គ្រាន់ និងគុណសម្បត្តិចាំបាច់ក្នុងការដឹកនាំក្រុមអ្នកនយោបាយប្រចាំថ្ងៃ។

## អគ្គលេខាធិការ ឬប្រធានក្រុមគណបក្ស

អាស្រ័យទៅលើទំហំបក្សរបស់ពួកគេ ក្រុមអ្នកនយោបាយនីមួយៗគួរមាន

ប្រធានក្រុមគណបក្សម្នាក់ (ច្រើននាក់) -ឬអគ្គលេខាធិការម្នាក់ (ច្រើននាក់)។ ប្រធានក្រុមគណបក្សម្នាក់ ត្រូវគ្រប់គ្រងធុរៈកិច្ចរបស់គណបក្សជាចម្បងនៅក្នុងអង្គនីតិប្បញ្ញត្តិ និងទទួលខុសត្រូវសម្រាប់កិច្ចការទំនាក់ទំនងរវាងអ្នកតំណាងដែលមានឥទ្ធិពលតិចតួច និងថ្នាក់ដឹកនាំរបស់ពួកគេ ក៏ដូចជាទំនាក់ទំនងរវាងក្រុមអ្នកនយោបាយ និងគណបក្ស។

*ប្រធានក្រុមគណបក្សម្នាក់ ត្រូវគ្រប់គ្រងធុរៈកិច្ចរបស់គណបក្សជាចម្បងនៅក្នុងអង្គនីតិប្បញ្ញត្តិ*

ប្រធានក្រុមគណបក្សល្អម្នាក់ គួរតែជាសមាជិកម្នាក់ដែលមានឥទ្ធិពលរបស់គណបក្ស។ គាត់គួរតែមានភាពស្របច្បាប់នៅក្នុងកេរ្តិ៍ឈ្មោះរបស់សមាជិកទាំងអស់ ហើយនិងមានសមត្ថភាពពិភាក្សាដោយបើកចំហពីបញ្ហាពាក់ព័ន្ធជាមួយនឹងថ្នាក់ដឹកនាំរបស់ក្រុមអ្នកនយោបាយ។ ដោយស្មើភាពគ្នា គឺសមាជិកម្នាក់ៗ របស់ក្រុមអ្នកនយោបាយគួរតែមានលទ្ធភាពចូលជួបប្រធាន និងអាចនិយាយដោយសេរី អំពីបញ្ហាដែលពួកគេកំពុងតែប្រឈមជាមួយ។ ប្រធានក្រុមគណបក្សត្រូវដឹងនូវអ្វីៗទាំងអស់ អំពីការងារ និងសកម្មភាពរបស់ក្រុមអ្នកនយោបាយ និងផលវិបាក គួរតែដាក់បញ្ចូលក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំ ទាំងអស់គាត់ត្រូវដឹងពីការអភិវឌ្ឍ និងសេចក្តីសម្រេចចុងក្រោយបំផុត។ លើសពីនេះទៅទៀត ប្រធានក្រុមគណបក្សគួរតែមានជំនាញទំនាក់ទំនងល្អ និងសមត្ថភាពការចរចាដ៏ប៉ិនប្រសព្វ ដើម្បីធ្វើការងារឱ្យមានប្រសិទ្ធិភាព។ ជាចុងក្រោយ គាត់គួរតែមានចំណេះដឹងជាចាំបាច់ក្នុងការប្រើប្រាស់ នូវបច្ចេកវិជ្ជាទំនាក់ទំនងទំនើប (ការវាយអត្ថបទ ការឆ្លើយឆ្លងអ៊ីម៉ែល ប្រព័ន្ធព័ត៌មានសង្គម ការប្រើប្រាស់កម្មវិធីវាយអត្ថបទ។ល។)

*ប្រធានក្រុមគណបក្សល្អម្នាក់ គួរតែជាសមាជិកម្នាក់ដែលមានឥទ្ធិពលរបស់គណបក្ស*

លោកអ្នកក៏អាចអានអត្ថបទ នៅចំណុច៣.ខ៉ៈ ដើម្បីទទួលបានព័ត៌មានលម្អិតជាងនេះ អំពីកាតព្វកិច្ចរបស់ប្រធានក្រុមគណបក្ស។

## អ្នកនាំពាក្យ

សារៈសំខាន់សម្រាប់ស្ថាប័ននីមួយៗ គឺត្រូវតែតែងតាំងអ្នកនាំពាក្យមួយរូប។ នេះគឺជានាថាយុទ្ធសាស្ត្រទំនាក់ទំនងខាងក្រៅនៃស្ថាប័នមួយនេះ មានសង្គតិ

*អ្នកនាំពាក្យត្រូវធានាថាយុទ្ធសាស្ត្រទំនាក់ទំនងខាងក្រៅនៃស្ថាប័នមួយនេះ មានសង្គតិភាព ហើយបានអនុវត្តប្រកបដោយវិជ្ជាជីវៈ*

ភាព ហើយបានអនុវត្តប្រកបដោយវិជ្ជាជីវៈ។ នៅពេលដែលអ្នកនាំពាក្យត្រូវបានតែងតាំងច្បាស់លាស់ហើយ ពេលនោះប្រព័ន្ធព័ត៌មាន និងអ្នកពាក់ព័ន្ធដទៃទៀតដឹងថា គេត្រូវទាក់ទងជាមួយអ្នកណាសម្រាប់ការទទួលបានព័ត៌មាន។ ដូច្នេះហើយ សមាជិកផ្សេងទៀតរបស់ក្រុម ក៏បានធូរស្រាលពីកាតព្វកិច្ចនេះ ព្រោះគេអាចមានពេលវេលាច្រើនជាងមុន ដោយផ្តោតលើការទទួលខុសត្រូវរបស់ពួកគេ។

ចំនួនអ្នកនាំពាក្យដែលចាំបាច់សម្រាប់ក្រុមអ្នកនយោបាយ អាស្រ័យទៅលើទំហំនៃក្រុមនោះ គឺអាចមានពីរ បី ឬពេលខ្លះច្រើនជាងនេះ អាស្រ័យទៅតាមតម្រូវការចាំបាច់។ អ្នកនាំពាក្យម្នាក់ គួរតែមានភាពជាអ្នកដឹកនាំ និងមានជំនាញទំនាក់ទំនងល្អប្រសើរ ហើយមានសមត្ថភាពអាចសរសេរសេចក្តីព្រាងប្រកាសសារព័ត៌មានច្បាស់លាស់ និងអាចផ្តល់កិច្ចសម្ភាសន៍ដល់ទូរទស្សន៍ និងវិទ្យុបាន។ អ្នកនាំពាក្យគួរតែអាចទាក់ទងបានគ្រប់ពេលវេលាទាំងអស់ សម្រាប់ឆ្លើយឆ្លងនឹងសំណួរ និងមានជំនាញបច្ចេកវិទ្យាទំនាក់ទំនងទំនើបល្អ (ការវាយអត្ថបទ ការសរសេរអ៊ីម៉ែល ប្រព័ន្ធព័ត៌មានសង្គម។ល។)

អ្នកនាំពាក្យម្នាក់ គួរតែជូនដំណឹងអំពីសកម្មភាពខាងក្នុងនៃក្រុមអ្នកនយោបាយ និងការជួបប្រជុំជាមួយថ្នាក់ដឹកនាំឲ្យបានទៀងទាត់ ដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រទំនាក់ទំនងនេះ។

## បញ្ហា និង ទ្ធមិសាស្ត្រ - ផ្អែកលើជំនាញ

ដើម្បីធ្វើការងារឲ្យមានប្រសិទ្ធិភាព សមាជិកនៅក្នុងក្រុមអ្នកនយោបាយត្រូវតែមានជំនាញទូទៅមួយក្នុងវិស័យនេះ។ ការបែងចែកបែបនេះ អនុញ្ញាត សម្រាប់ការជួបជុំក្នុងការសម្រេចចិត្ត ដោយផ្អែកលើចំណេះដឹងជំនាញរបស់សមាជិកម្នាក់ៗ លើប្រធានបទជាក់លាក់។

មានវិធីសាស្ត្រចម្បងពីរយ៉ាងដើម្បីសម្រួចឯកទេសនេះ។ លទ្ធភាពទីមួយគឺ**បញ្ហា-ផ្អែកលើការបែងចែក**។ ឧទាហរណ៍ដូចជា សមាជិកមួយចំនួននៃក្រុម

អ្នកនយោបាយអាចចាប់អារម្មណ៍ផ្ទាល់ខ្លួន និង/ឬ វិជ្ជាជីវៈអំពីបញ្ហាពាក់ព័ន្ធបទប្បញ្ញត្តិពលកម្មការងារ ខណៈដែលសមាជិកមួយចំនួនផ្សេងទៀតងាកមកចាប់អារម្មណ៍អំពីគោលនយោបាយសុខភាព។ វិធីសាស្ត្រទីពីរគឺ អនុវត្តន៍តាម **ជំនាញខាងភូមិសាស្ត្រ-ផ្អែកលើការបែងចែក** មានន័យថា សមាជិកសភាមួយចំនួន ដែលទាក់ទងជាមួយតំបន់នោះជាពិសេស គួរតែមានអាទិភាពច្រើនសម្រាប់ការពិគ្រោះយោបល់។

ការបែងចែកបែបនេះ អាចជាផ្លូវការ (គណៈកម្មាធិការដែលមានរចនាសម្ព័ន្ធផ្លូវការក្នុងចំណោមក្រុមអ្នកនយោបាយ) ឬមិនផ្លូវការ (ប្រជាជនផ្តោតលើប្រធានបទជាក់លាក់មួយចំនួន និងត្រូវបានចាត់ទុកថាជា «កិច្ចការជំនាញ» លើកម្មវត្ថុដែលទាក់ទងទៅនឹងពួកគាត់)។គឺអាស្រ័យលើទំហំនៃក្រុមអ្នកនយោបាយ បរិមាណ និងកម្រិតនៃការបែងចែកការងារប្រហែលមានការផ្លាស់ប្តូរ។ គំនិតនេះ គឺប្រើប្រាស់ដើម្បីពង្រឹងសមត្ថភាពសមាជិកឲ្យកាន់តែរឹងមាំ (បទពិសោធន៍ជីវិត និងការងារពីមុនរបស់ពួកគាត់) សម្រាប់ក្រុមអ្នកនយោបាយ ក្នុងការក្លាយខ្លួនជាក្រុមមួយមានសមត្ថភាព មានចំណេះដឹង និងមានប្រសិទ្ធិភាពការងារច្រើនជាងមុន។

## នាយកដ្ឋានរដ្ឋាភិបាល - ផ្អែកលើការងារជំនាញ (គណៈរដ្ឋមន្ត្រីស្រមោល)

បន្ថែមលើនេះ មានរដ្ឋសភាមួយចំនួន បានអនុម័តនូវនាយកដ្ឋានរដ្ឋាភិបាលមួយ ដែលឈរលើវិធីសាស្ត្រ ដោយបង្កើតជាគណៈកម្មាធិការមួយចំនួននៅក្នុងក្រុមអ្នកនយោបាយ ដែលបានចម្លងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល៖ គណៈកម្មាធិការរបស់ក្រុមអ្នកនយោបាយមួយ ត្រូវគ្របដណ្តប់លើបណ្តាវិស័យជាច្រើន ដូចគ្នាទៅនឹងក្រសួងមួយដែរ។ ជាធម្មតា គណៈកម្មាធិការទាំងអស់នេះត្រូវបំពេញបន្ថែម ជាជាងការជំនួសឲ្យគណៈកម្មាធិការដែលផ្អែកលើបញ្ហា ឬភូមិសាស្ត្រ។ ឧទាហរណ៍មួយ ដូចជាករណីមួយនៅក្នុងប្រទេសអង់គ្លេស ដែលគេហៅថាគណៈរដ្ឋមន្ត្រីស្រមោលនេះ បានកើតមានរូបរាងច្រើនជាងមួយសត

វត្សមកហើយ និងតំណាងជារដ្ឋាភិបាលមួយផ្សេងទៀត ដែលគាំទ្រដោយគណបក្សប្រឆាំង។ ក្រសួងនីមួយៗរបស់រដ្ឋាភិបាល គឺមើលឃើញថាវាមានសមមាត្រគ្នាទៅនឹងគណៈរដ្ឋមន្ត្រីស្រមោល។ វិធីសាស្ត្រនេះគឺបង្ហាញថាគណបក្សប្រឆាំងមានរចនាសម្ព័ន្ធត្រឹមត្រូវ និងត្រៀមខ្លួនរួចជាស្រេច ដើម្បីកាន់កាប់អំណាចដែរ។ រដ្ឋមន្ត្រីស្រមោល ត្រូវពិនិត្យ ការអនុវត្តការងារក្រសួងនីមួយៗ របស់រដ្ឋាភិបាលពាក់ព័ន្ធរបស់ពួកគេ គណៈរដ្ឋមន្ត្រីស្រមោលនេះ ត្រូវបង្កើត គោលនយោបាយផ្ទាល់ខ្លួន និងសំណើនីតិប្បញ្ញត្តិ ហើយបញ្ជាក់ថាខ្លួនក៏មានបច្ចុប្បន្នភាពស្របជាមួយនឹងកិច្ចការបច្ចុប្បន្នទាំងអស់នោះដែរ។ គណៈកម្មាធិការទាំងអស់នេះ បានចម្លងអង្គការលេខនៃក្រុមអ្នកនយោបាយនៅខ្នាតតូចមួយ។

## ឃ. វិធាននៃនីតិវិធីកិច្ចប្រជុំក្រុមអ្នកនយោបាយ

ពេលបង្កើតក្រុមអ្នកនយោបាយមួយ ការសំខាន់នោះគឺ ត្រូវព្រមព្រៀងគ្នាទៅលើនីតិវិធីត្រូវអនុវត្តក្នុងអំឡុងពេលកិច្ចប្រជុំ។ ទីមួយ គឺជាមធ្យោបាយមួយរបស់ការងារប្រកបដោយប្រសិទ្ធិភាព។ ទីពីរ គឺត្រូវណែនាំដល់សមាជិកទាំងអស់នៅក្នុងពេលវេលាមួយដែលគាត់មានភាពមិនច្បាស់លាស់។ ទីបី គឺត្រូវដោះស្រាយវិវាទកម្ម ឬការខ្វែងគំនិតគ្នាជាមួយមធ្យោបាយមួយប្រកបដោយសន្តិភាព និងអាចទទួលយកបានទាំងអស់គ្នា។

វិធាននៃនីតិវិធី គួរតែកំណត់នូវធាតុទាំងអស់របស់អង្គការលេខនៃអង្គប្រជុំមួយ ដែលរួមមានទាំង៖

- នីតិវិធីកិច្ចប្រជុំមានលក្ខណៈស្តង់ដារ
- ធ្វើកំណត់ហេតុ (អ្នកណាទទួលខុសត្រូវ?)
- អ្នកចូលរួមនៅក្នុងកិច្ចប្រជុំ (សមាជិករបស់គណបក្ស? អគ្គលេខាធិការសភា? រដ្ឋមន្ត្រី? អ្នកជំនាញការ?)
- រៀបចំការបោះឆ្នោត (ការបោះឆ្នោតដោយចំហ ឬបិទទ្វារ? មានការផ្តល់សិទ្ធិសម្លេងភាគច្រើនដាច់ខាតជាលក្ខណៈធម្មតា?)

■ រយៈពេលនិយាយ

អ្នកអាចអានទៅចំណុច៣.ខ.iii អំពីការពិពណ៌នាលំម្អិតរបស់វិធីនៃកិច្ចប្រជុំក្រុមអ្នកនយោបាយត្រូវបានគេរៀបចំឡើង។

## ង. សង្គតិភាពក្រុមអ្នកនយោបាយ និងវិន័យក្រុម

### *i. សង្គតិភាពក្រុមអ្នកនយោបាយ៖ យុទ្ធសាស្ត្រ និងឧបករណ៍*

ដូចបានពន្យល់កាលពីមុនរួចហើយ សង្គតិភាពនឹងនាំមកនូវប្រសិទ្ធិភាព ក្រុមអ្នកនយោបាយឲ្យបានប្រសើរជាងមុន និងភាពមើលឃើញកាន់ច្បាស់នៅលើឆាកនយោបាយ។ ទោះបីជាយ៉ាងនេះក្ដី វប្បធម៌ ឬតុល្យភាពអំណាចរបស់នយោបាយ ពេលខ្លះបង្កការលំបាកដល់គោលការណ៍នេះ។ ប្រទេសអូស្ត្រាលីបានផ្ដល់នូវឧទាហរណ៍នៃបទពិសោធន៍ទាំងពីរនេះ។ នៅក្នុងករណីគណបក្សពលករ គណបក្សនយោបាយមានសិទ្ធិនិយាយចុងក្រោយ និងសេចក្ដីសម្រេចរបស់ខ្លួន គឺជាសេចក្ដីសម្រេចផ្លូវការសម្រាប់សមាជិកសភាអនុវត្តតាម។ នៅក្នុងករណីកម្មវិធីគោលនៃគណបក្សវិញ មិនបានគ្របដណ្ដប់លើប្រធានបទជាក់លាក់ណាមួយនោះទេ វាគឺជាសិទ្ធិរបស់ក្រុមអ្នកនយោបាយ ក្នុងការរៀបចំការបោះឆ្នោតមួយក្នុងចំណោមសមាជិករបស់ខ្លួន ហើយនិងសម្រេចនូវជំហររបស់ក្រុម គួរធ្វើយ៉ាងណាអំពីបញ្ហានោះ។ បន្ទាប់មក លទ្ធផលនឹងក្លាយជាផ្លូវការសំរាប់សមាជិកសភាគណបក្សពលករទាំងអស់។ ផ្ទុយទៅវិញ សមាជិកសភាគណបក្សប្រជាធិបតេយ្យ មិនត្រូវបានបង្ខំដោយសេចក្ដីណែនាំនៃការបោះឆ្នោតរបស់ពួកគេពីគណបក្សនយោបាយឡើយ។ ពួកគេមានសេរីភាពក្នុងការបោះឆ្នោតប្រឆាំងទៅនឹងបំណងប្រាថ្នារបស់គណបក្សនោះ ដរាបណាពួកគេប្រាកដច្បាស់ថា នោះគឺជាជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ និងថាវាមិនបានឆ្លុះបញ្ចាំងពីគំនិតរបស់គណបក្សឡើយ។ នៅសហរដ្ឋអាមេរិក គណបក្សប្រជាធិ

បតេយ្យបានជ្រើសរើសការសម្របសម្រួលៈ សមាជិករបស់ខ្លួនត្រូវបានគេស្នើឱ្យអនុវត្តន៍តាមសេចក្ដីណែនាំការបោះឆ្នោតរបស់គណបក្ស ក៏ប៉ុន្តែសមាជិកទាំងនោះ ត្រូវអនុញ្ញាតបោះឆ្នោតតាមឆន្ទៈយល់ឃើញរបស់ខ្លួន ទៅតាមប្រធានបទជាក់លាក់មួយចំនួនជាបន្តបន្ទាប់ នៅពេលពិភាក្សាដេញដោលទាក់ទងនឹងសិទ្ធិក្នុងការរំលូតកូន ការកាត់ទោសប្រហារជីវិត ការធ្វើវិស្វកម្មហ្សែន ឬសិទ្ធិជ្រើសរើសការស្លាប់ដោយភាពងាយស្រួល។ សមាជិកសភាសហរដ្ឋអាម៉េរិក ក៏បានបង្កើតយុទ្ធសាស្រ្តក្នុងការបញ្ជាក់ពីការជំទាស់របស់ពួកគេ ដោយមិនធ្វើឲ្យគណបក្សរបស់គេចុះខ្សោយឡើយ ដូចជាការស្ម័គ្រចិត្តអវត្តមាននៅពេលបោះឆ្នោត ឬការចុះចេញពីដំណែងជាបណ្ដោះអាសន្ន ដើម្បីអនុញ្ញាតឱ្យអ្នកដទៃបោះឆ្នោតជំនួស។

ដោយមិនគិតពីកម្រិតសេរីភាពបុគ្គល សមាជិកនៃក្រុមអ្នកនយោបាយពួកគាត់រីករាយជាមួយនឹងយុទ្ធសាស្រ្តដែលមាន ក្នុងការពង្រឹងសង្គតិភាពក្រុម និងជៀសវាងការបែងចែកកំឡុងការបោះឆ្នោត។ យុទ្ធសាស្រ្តទាំងនេះ គួរត្រូវបានប្រើប្រាស់ជាចម្បងដោយប្រធានក្រុមរបស់ក្រុមគណបក្ស (សូមមើលៈ ២.គ) ប៉ុន្តែក៏ត្រូវប្រើប្រាស់ដោយថ្នាក់ដឹកនាំក្រុមអ្នកនយោបាយផងដែរ ប្រសិនបើចាំបាច់។ យុទ្ធសាស្រ្តទាំងនេះ រួមមានៈ

- ជ្រើសរើសដោយប្រុងប្រយ័ត្ននូវបេក្ខជន។ មុនពេលប្រកាសថានរណាម្នាក់ជាបេក្ខជនរបស់គណបក្ស ថ្នាក់ដឹកនាំគួរតែប្រាកដថាបេក្ខជនដែលបានស្នើឡើងនោះបានចូលរួមនៅក្នុងសកម្មភាពរបស់គណបក្សមានរយៈពេលយូរគ្រប់គ្រាន់ និងបានបង្ហាញនូវសញ្ញានៃអត្តសញ្ញាណជាមួយនឹងគុណតម្លៃ និងគោលនយោបាយដែលដាក់ចេញដោយគណបក្ស។ ពិនិត្យបញ្ជាក់មើលគុណតម្លៃសីលធម៌របស់មនុស្ស ក៏ដូចជាសមត្ថភាព និងមហិច្ឆិតារបស់គាត់ មុនពេលដែលតែងតាំងគាត់ជាបេក្ខជន ដើម្បីកាត់បន្ថយហានិភ័យនៃការទាមទារសេរីភាពរបស់គាត់ច្រើនហួសហេតុ នៅពេលដែលគាត់ត្រូវបានជ្រើសរើស ឬត្រូវដឹងការពិតថា គាត់មិនបានយល់ស្របទៅនឹង ទស្សនៈរបស់គណបក្សទេ។

- **អំពាវនាវឱ្យមានភាពស្មោះត្រង់របស់សមាជិកចំពោះគណបក្ស។** នៅពេលដែលបញ្ហាមួយមានសារៈសំខាន់ជាពិសេសសម្រាប់គណបក្ស ហើយការបែកបាក់គ្នា ជាផ្នែកមួយបានគំរាមកំហែងដល់ភាពជោគជ័យរបស់គណបក្ស ក្នុងពេលបោះឆ្នោត។ ការខ្វែងគំនិតគ្នារបស់អ្នកតំណាងទាំងនោះ គួរតែរំឭកអំពីផលវិបាកដែលមានសក្តានុពលសម្រាប់គណបក្ស។ មានករណីខ្លះដែលមានផលប្រយោជន៍សម្រាប់គណបក្ស ពួកគេគួរតែពិចារណាមិនត្រូវបោះឆ្នោតប្រឆាំងជាមួយជួរបណ្តាញក្រុមអ្នកនយោបាយ នៅលើប្រធានបទជាក់លាក់ណាមួយឡើយ។ ការរំឭកដល់សមាជិកទាំងអស់នោះ គឺត្រូវយល់ច្បាស់ថា ភាពទន់ខ្សោយរបស់គណបក្ស វានឹងនាំទៅដោយស្វ័យប្រវត្តិក្នុងការពង្រឹងយ៉ាងរឹងមាំដល់គណបក្សប្រឆាំង។ ប្រហែលនេះជាការអះអាងមួយប្រកបដោយប្រសិទ្ធិភាព។
- **ការចរចា** ដូចគ្នានេះដែរ ប្រសិនបើជាមានការបោះឆ្នោតជាពិសេស ដែលសំខាន់សម្រាប់គណបក្ស គេអាចចរចាជាមួយនឹងសមាជិកក្រុមអ្នកនយោបាយបាន ព្រោះថាពួកគាត់អាចមានសេរីភាពច្រើនក្នុងការបោះឆ្នោតនៅលើប្រធានបទផ្សេងៗទៀត ប្រសិនបើការណែនាំរបស់គណបក្សត្រូវបានអនុវត្តន៍នៅក្នុងករណីនេះ។
- **ការអភិវឌ្ឍអាជីព និងការលើកទឹកចិត្តជាវិជ្ជមាន។** ប្រសិនបើចាំបាច់ គួរអាចរំឭកប្រាប់ដល់សមាជិកដែលនៅស្ទាក់ស្ទើរថា ការគាំទ្រសម្រាប់គណបក្សត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំង និងអាចជួយដល់សមាជិកក្នុងការបោះឆ្នោត ឬតែងតាំងជាមន្ត្រីការិយាល័យដែលគួរឱ្យចាប់អារម្មណ៍បាន។ ជាការពិត ក្រុមអ្នកនយោបាយជ្រើសរើសប្រធានដែលពួកគេចង់បាន អ្នកដែលទទួលបានការនិយាយអំឡុងពេលកិច្ចប្រជុំពេញអង្គ និងអ្នកចង់ធ្វើជាគណអធិបតីនៅក្នុងអង្គប្រជុំគណៈកម្មាធិការ ឬអ្នកចង់ធ្វើជាគណអធិបតីនៃអង្គប្រជុំខ្លួនឯងផ្ទាល់។ នៅក្នុងន័យនេះ ការទទួលបានយ៉ាងទៀងទាត់នៅគម្លាតមួយពីជួរបណ្តាញក្រុមអ្នកនយោបាយ និងធ្វើឲ្យអន្តរាយដល់ភាពមើលឃើញ របស់ខ្លួននៅចំពោះមុខអង្គប្រជុំទាំងមូល វាបង្ហាញយ៉ាង

ច្បាស់ណាស់ថា មិនមែនជាយុទ្ធសាស្ត្រល្អមួយទេ។

*គ្មានសមាជិកត្រូវទទួលរងការបង្ខំក្នុងការបោះឆ្នោតគាំទ្រ ឬប្រឆាំងទៅនឹងប្រធានបទមួយដែលស្ថិតនៅក្រោមកាលៈទេសៈណាមួយនោះទេ*

អ្វីដែលត្រូវការ ក្នុងការគូសបញ្ជាក់ទាក់ទងទៅនឹងយុទ្ធសាស្ត្រខាងលើនេះ គឺជាមធ្យោបាយមួយបែបនៃការបញ្ចុះបញ្ចូល និងការចរចាដែលគួរតែទទួលបានដោយសេរីចំពោះការអនុវត្តដោយគ្មានអំពើពុករលុយ។ គ្មានសមាជិកត្រូវទទួលរងការបង្ខំក្នុងការបោះឆ្នោតគាំទ្រ ឬប្រឆាំងទៅនឹងប្រធានបទមួយដែលស្ថិតនៅក្រោមកាលៈទេសៈណាមួយនោះទេ។

*ii. ឧបករណ៍ដាក់ពិន័យ*

ជាការពិត យូរៗម្តងការខ្វែងគំនិតគ្នាគឺតែងតែកើតមានឡើង។ ជាទូទៅ គេគួរតែមានមហិច្ឆិតាក្នុងការទប់ស្កាត់ការពារពួកគេ នៅពេលដែលរឿងរ៉ាវបានកើតឡើង ការគេចវេះចេញពីជម្លោះនោះ វាមិនមែនជាដំណោះស្រាយល្អឡើយ។ នៅពេលខ្លះ ការលើកទឹកចិត្តតាមបែបលក្ខណៈវិជ្ជមាន ក៏មិនបើកឱកាសគ្រប់គ្រាន់ ឲ្យលទ្ធភាពរបស់ក្រុមទទួលយកវិធានការដាក់ពិន័យប្រឆាំងលើសមាជិកណាម្នាក់ក្នុងចំណោមសមាជិករបស់ខ្លួនបានទេ ពួកគេត្រូវមានភស្តុតាងជាចាំបាច់ក្នុងការស្តារឡើងវិញនូវបទបញ្ជា ឬក្នុងករណីដែលមានការរំលោភបំពានទៅលើក្រមប្រតិបត្តិជាដើម។

*វិធានការដាក់ពិន័យគួរតែជាវិធានការវិសាមញ្ញ*

មានគំនិតសំខាន់ៗពីរគឺ។ ទីមួយ វិធានការដាក់ពិន័យគួរតែជាវិធានការវិសាមញ្ញ មានន័យថា ការប្រើប្រាស់វិធាននេះអោយបានទូលំទូលាយ នោះគឺអាចយកឈ្នះលើគោលបំណងរបស់ពួកគេបាន។ ភាពជោគជ័យនៃឧបករណ៍ដាក់វិន័យនេះ គឺស្ថិតនៅក្នុងការផ្សះផ្សាពួកគេដែលជាតំណាង ហើយមិនត្រូវប្រើប្រាស់វិធាននេះញឹកញាប់ពេកនោះដែរ។ សមាជិកម្នាក់ៗត្រូវដឹងថាប្រសិនបើគាត់បានប្រព្រឹត្តអ្វីមួយដែលផ្ទុយ ឬធ្វើអោយខូចកេរ្តិ៍ឈ្មោះរបស់បក្សនោះ គាត់ត្រូវតែប្រឈមនឹងផលវិបាក និងការស្តីបន្ទោសពីបក្ស។ ទីពីរ វិធានការដាក់ពិន័យគួរតែមានការវិវឌ្ឍសន្សឹមៗនិងប្រែប្រួលទៅតាមសភាពការណ៍ជាក់

ស្តែងនៃស្ថានការណ៍។ នោះមិនមែនជាការឆ្លាតវៃរបស់បក្សទេ ដែលត្រូវផ្តល់ចម្លើយដដែលៗទៅនឹងការប្រព្រឹត្តខុសតិចតួច ឬទៅនឹងកំហុសដែលធ្ងន់ធ្ងរនោះ។ និយាយរួម ការដាក់ទណ្ឌកម្មត្រូវតែយុត្តិធម៌។

*ការដាក់ទណ្ឌកម្មត្រូវតែយុត្តិធម៌*

ការសម្រេចចិត្តក្នុងការដាក់ទោសលើសមាជិកណាម្នាក់ មិនត្រូវអនុវត្តន៍ទោសស្រាលពេកនោះទេ គឺត្រូវអនុវត្តតាមនីតិវិធីដ៏តឹងរ៉ឹងមួយ។ គណៈកម្មាធិការវិន័យ ជាធម្មតា បានបង្កើតឡើងដោយថ្នាក់ដឹកនាំរបស់ក្រុមអ្នកនយោបាយ និងអាចរួមបញ្ចូលសមាជិក មានប្រធាន អនុប្រធានរបស់ក្រុមអ្នកនយោបាយ អគ្គលេខាធិការ និងប្រធាននៃគណៈកម្មាធិការនានារបស់ក្រុមអ្នកនយោបាយ។ ដូចជានៅវាល់សវនាការ «ថៅក្រុម» មិនលម្អៀងដូចដែលអាចធ្វើទៅបាន។ ពួកគេត្រូវតែបង្ហាញនូវហេតុផលនៃការវិនិច្ឆ័យទោសមានលក្ខណៈអព្យាក្រឹត ឬក៏យោងតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ។ សមាជិកដែលទទួលរងការចោទប្រកាន់ គួរតែទទួលបានសិទ្ធិពេញលេញក្នុងការការពារខ្លួន។

*«ថៅក្រុម» មិនលម្អៀងដូចដែលអាចធ្វើទៅបាន*

ឧបករណ៍ដាក់ពិន័យដែលក្រុមអ្នកនយោបាយ អាចអនុវត្តប្រឆាំងទៅនឹងសមាជិករបស់ខ្លួន រួមមាន ៖

- ការព្រមានផ្ទាល់មាត់ពីអគ្គលេខាធិការ ឬថ្នាក់ដឹកនាំ
- ការព្រមានជាលាយលក្ខណ៍អក្សរពីអគ្គលេខាធិការ ឬថ្នាក់ដឹកនាំ
- ការដាក់ពិន័យអាស្រ័យលើស្ថានភាពទម្ងន់ទោសនៃកំហុស
- ការដកចេញពីមុខតំណែង
- ការបណ្តេញចេញពីក្រុមអ្នកនយោបាយ (ឬបក្ស) សម្រាប់ការបំពានធ្ងន់ធ្ងរ

## ច. មូលនិធិ

### *i. មូលនិធិសាធារណៈសម្រាប់ក្រុមនយោបាយ*

សំណួរពាក់ព័ន្ធទៅនឹងមូលនិធិសាធារណៈសម្រាប់ក្រុមអ្នកនយោបាយ គឺមានភាពខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ឧទាហរណ៍ ក្នុងប្រទេសបារាំង

នៅពេលដែលក្រុមអ្នកនយោបាយត្រូវបានទទួលស្គាល់ជាផ្លូវការ ពេលនោះក្រុមអ្នកនយោបាយនៅក្នុងរដ្ឋសភាទទួលបានមូលនិធិទ្រទ្រង់ពីរដ្ឋ (ពាក់កណ្ដាលនៃថវិកាទាំងមូល គឺផ្ដត់ផ្ដង់ឲ្យមូលនិធិរបស់គណបក្សនយោបាយ)។ បរិមាណនៃមូលនិធិនេះ គឺត្រូវបានបែងចែកនៅក្នុងចំណោមក្រុមអ្នកនយោបាយដោយសមាមាត្រទៅនឹងភាពចាំបាច់នីមួយៗ របស់ពួកគេតាមចំនួនអសនៈនៅក្នុងសភា។ មូលនិធិសាធារណៈនេះ ភាគច្រើនត្រូវបានប្រើប្រាស់ដោយក្រុមអ្នកនយោបាយសម្រាប់ការចំណាយលើបុគ្គលិករបស់ខ្លួន និងការ ជួលការិយាល័យ ក៏ប៉ុន្តែត្រូវបានប្រើប្រាស់លើការចំណាយប្រតិបត្តិការការងារ លេខាធិការ និងការចំណាយលើកិច្ចការទំនាក់ទំនងសាធារណៈផងដែរ (ដូចជា ការផ្សព្វផ្សាយ ការបោះពុម្ព និងការចែកចាយសៀវភៅ ខិតប័ណ្ណ។ល។)។ ក្រុមអ្នកនយោបាយក៏ទទួលបាននូវរបបពន្ធពិសេសផងដែរ ដែលជាទម្រង់មួយផ្សេងទៀតនៃមូលនិធិសាធារណៈ។ ប្រព័ន្ធដូចគ្នានេះដែរ មាននៅក្នុងប្រទេសភាគច្រើន ដែលក្រុមអ្នកនយោបាយត្រូវបានទទួលស្គាល់លើសលុប ដូចជាស្ថាប័នសភា។

*មូលនិធិសាធារណៈរបស់ក្រុមអ្នកនយោបាយនេះ គឺប្រើប្រាស់ក្នុងទិសដៅពង្រឹងការបញ្ចេញមតិតាមបែបប្រជាធិបតេយ្យ បានផ្ដល់អោយតួអង្គទាំងអស់ធ្វើជាមធ្យោបាយក្នុងការបំពេញកាតព្វកិច្ចរបស់ពួកគេក្រោមលក្ខខណ្ឌស្មើភាពគ្នា និងក្នុងការបង្កើតនូវគោលនយោបាយមួយល្អប្រសើរ*

មូលនិធិសាធារណៈរបស់ក្រុមអ្នកនយោបាយនេះ គឺប្រើប្រាស់ក្នុងទិសដៅពង្រឹងការបញ្ចេញមតិតាមបែបប្រជាធិបតេយ្យ បានផ្ដល់អោយតួអង្គទាំងអស់ធ្វើជាមធ្យោបាយ ក្នុងការបំពេញកាតព្វកិច្ចរបស់ពួកគេ ក្រោមលក្ខខណ្ឌស្មើភាពគ្នា និងក្នុងការបង្កើតនូវគោលនយោបាយមួយល្អប្រសើរ។ តាមរយៈមធ្យោបាយសាធារណៈ ដែលមានតម្លាភាពនៃការផ្ដល់មូលនិធិដល់ក្រុមអ្នកនយោបាយ ត្រូវបានធានាថាជាជំនួយហិរញ្ញវត្ថុត្រឹមត្រូវនិងយុត្តិធម៌។ វាជាថវិកាដែលវិភាជន៍ តាមរយៈការបែងចែករបស់រដ្ឋជាសាធារណៈអាចកាត់បន្ថយអាស្រ័យតាមគណបក្សរបស់ពួកគេ ឬភាគីពាក់ព័ន្ធឯកជនដទៃទៀត ដែលឆ្លុះបញ្ចាំងនូវសក្ដានុពលសម្រាប់ការផ្ដល់មូលនិធិដែលជាអំពើសូកប៉ាន់ត្រូវបានថយចុះ។

### *ii. ប្រភពថវិកានៃមូលនិធិ*

ច្បាប់ស្ដីពីការផ្ដល់ហិរញ្ញវត្ថុឯកជនរបស់ក្រុមអ្នកនយោបាយ គឺមានភាពខុសៗ

គ្នានៅក្នុងប្រទេសនីមួយៗ។ ជាទូទៅ ច្បាប់គឺធ្វើការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងលើការផ្តល់ហិរញ្ញវត្ថុឯកជននេះ ដើម្បីកុំឲ្យមានភាពជ្រួលច្របល់លើតុល្យភាពនយោបាយ និងភាពចាញ់ប្រៀបគ្នារបស់ភាគីដែលមានមធ្យោបាយតិចតួចជាងនោះ។ ឧទាហរណ៍ ដូចជាការបរិច្ចាគធនធានឯកជន ជាទូទៅត្រូវកំណត់ក្នុងចំនួនមួយជាក់លាក់។

*ជាទូទៅច្បាប់គឺធ្វើការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងលើការផ្តល់ហិរញ្ញវត្ថុឯកជននេះ ដើម្បីកុំឲ្យមានភាពជ្រួលច្របល់លើតុល្យភាពនយោបាយ និងភាពចាញ់ប្រៀបគ្នារបស់ភាគីដែលមានមធ្យោបាយតិចតួចជាងនោះ*

មួយផ្នែកទៀតនៃមូលនិធិរបស់ក្រុមអ្នកនយោបាយ គឺបានមកពីការវិភាគទានដោយផ្ទាល់ពីសមាជិករបស់ខ្លួន ដែលបានបរិច្ចាគប្រាក់ខែមួយចំណែករបស់ខ្លួន ចូលក្នុងមូលនិធិរបស់ក្រុមអ្នកនយោបាយ។ ហេតុដូច្នេះហើយការធានាថាក្រុមអ្នកនយោបាយ និងអ្នកតំណាងរបស់ខ្លួនឯងផ្ទាល់ អាចឲ្យគេបំពេញការងារបានប្រកបដោយភាពពេញចិត្តពេញថ្លើម។ មិនតែប៉ុណ្ណោះសមាជិកទាំងនោះ អាចដក ឬប្តូរបុគ្គលិករបស់ខ្លួនជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ទៅកន្លែងផ្សេងមួយទៀតបាន ក្នុងការបម្រើឲ្យក្រុមអ្នកនយោបាយ និងអាចជួយអោយការងារនៅទីនោះឲ្យប្រព្រឹត្តទៅបានដោយរលូន។

ជាចុងក្រោយរាល់សកម្មភាពទាំងឡាយដែលបានរៀបចំឡើងដោយគណបក្សនយោបាយ ក៏អាចជាប្រភពចំណូលផងដែរ (ជាឧទាហរណ៍ ការប្រមូលផ្តុំអ្នកស្មោះត្រង់នយោបាយ, ព្រឹត្តិការណ៍សង្គម ការឧបត្ថម្ភដល់សន្និបាត ។ល។)

# ៣. ការងាររបស់ក្រុមអ្នកនយោបាយ

## ក. ទំនាក់ទំនងជាមួយនឹងស្ថាប័នគណបក្សនយោបាយ

នៅក្នុងប្រទេសអូស្ត្រាលី លក្ខន្តិកៈរបស់គណបក្សសេរីនិយមបានចែងថា ក្រុមអ្នកនយោបាយនិងមន្ត្រីរបស់គណបក្សនយោបាយមានកាតព្វកិច្ចត្រូវផ្តល់ដល់គ្នាទៅវិញទៅមក នូវការវិវត្តនយោបាយចុងក្រោយ និងត្រូវសហការគ្នាយ៉ាងជិតស្និទ្ធបំផុត។ នៅក្នុងប្រទេសស៊ុយអែត អ្នកប្រជាធិបតេយ្យសង្គម គឺត្រូវទទួលខុសត្រូវលើការងាររបស់ខ្លួននៅចំពោះមុខរបស់សមាជគណបក្ស និងត្រូវបញ្ជូនរបាយការណ៍ ស្តីពីសកម្មភាពប្រចាំឆ្នាំ ទៅគណៈកម្មាធិការប្រតិបត្តិបក្ស។ នៅក្នុងប្រទេសកាណាដា មេដឹកនាំរបស់ គណបក្សសេរីនិយមបានចាត់តាំងមន្ត្រីទទួលខុសត្រូវមួយរូប ដែលមានតួនាទីក្នុងការរាយការណ៍ជូននាយកនៃក្រុមប្រឹក្សារបស់គណបក្សអំពីសកម្មភាពទាំងអស់ និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមអ្នកនយោបាយ។

យន្តការនៃកិច្ចសហប្រតិបត្តិការដ៏តឹងរ៉ឹងបែបនេះ គឺបានចង្អុលបង្ហាញថាសារៈសំខាន់សំរាប់ក្រុមអ្នកនយោបាយធ្វើយ៉ាងណា ក្នុងការរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយនឹងគណបក្សនយោបាយរបស់ខ្លួនបាន។ ទីមួយ សមាជិកទាំងអស់ នៃក្រុមអ្នកនយោបាយត្រូវបានជ្រើសតាំងឡើងដោយការបោះឆ្នោតរបស់គណបក្ស។ ហើយពួកគេត្រូវបានតែងតាំង ឲ្យធ្វើជាបេក្ខជនរបស់បក្សឈរឈ្មោះនៅក្នុងការបោះឆ្នោត ដោយហេតុនេះហើយ ត្រូវការប្រើប្រាស់ស្លាកសញ្ញារបស់បក្សនៅក្នុងការិយាល័យរបស់ពួកគេ។ គណបក្សនយោបាយបានផ្តល់ឲ្យពួកគាត់នូវមធ្យោបាយក្នុងការធ្វើយុទ្ធនាការ មានដូចជា៖ ហិរញ្ញវត្ថុ អ្នកស្ម័គ្រចិត្តចែកចាយខិតប័ណ្ណ មធ្យោបាយដឹកជញ្ជូនពួកគេទៅកាន់ការិយាល័យបោះឆ្នោត។ល។ លើសពីនេះទៅទៀត ចាប់តាំងពីគណបក្សបានបង្កើតនូវរចនាសម្ព័ន្ធដ៏ល្អមួយនៅទូទាំងប្រទេសមក ប្រជាពលរដ្ឋងាយស្រួលទទួល

បានព័ត៌មានតាមប្រព័ន្ធនេះ។ ទីពីរ មូលហេតុចាំបាច់សម្រាប់ក្រុមអ្នកនយោបាយ ក្នុងការរក្សាទំនាក់ទំនងជាមួយនឹងគណបក្សនយោបាយរបស់ខ្លួន គឺថា បើទោះជាអង្គភាពពីរដាច់ដោយឡែកគ្នាក៏ដោយ ក្រុមអ្នកនយោបាយ គឺជាផ្នែកដ៏មានសារៈសំខាន់មួយ របស់គណបក្សនយោបាយនីមួយៗ របស់ពួកគេ៖ មានអង្គភាពពីរនៅក្នុងអាគារតែមួយ។ ពួកគេស្ថិតនៅក្នុងអង្គភាពតែមួយ ហើយទទួលបានអត្ថប្រយោជន៍ដូចគ្នា ក្នុងការពង្រឹងសមត្ថភាពគណបក្ស។ ដូច្នេះហើយ ភារកិច្ចស្នូលរបស់ក្រុមអ្នកនយោបាយ គឺការថែរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគណបក្សនយោបាយ ហើយត្រូវប្រាកដថា ពួកគេធ្វើការដើម្បីសម្រេចបាននូវគោលដៅរួមគ្នា។ សេចក្តីថ្លែងការណ៍ គឺជាមូលដ្ឋានយ៉ាងរឹងមាំ មិនថាក្រុមអ្នកនយោបាយនោះ មានភាពឯករាជ្យពីគណបក្សនយោបាយយ៉ាងណាក៏ដោយ៖ យុទ្ធសាស្ត្រត្រូវបានសម្របសម្រួល ហើយបុគ្គលម្នាក់ៗត្រូវតែដឹងថាអ្វីដែលនឹងកើតមានឡើងនៅក្នុង "អាគាររបស់ខ្លួន" នេះ។

*ដូច្នេះហើយ ភារកិច្ចស្នូលរបស់ក្រុមអ្នកនយោបាយ គឺការថែរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគណបក្សនយោបាយហើយត្រូវប្រាកដថា ពួកគេធ្វើការដើម្បីសម្រេចបាននូវគោលដៅរួមគ្នា*

កិច្ចខិតខំប្រឹងប្រែងដើម្បីថែរក្សាទំនាក់ទំនងប្រកបដោយប្រសិទ្ធផល រវាងក្រុមអ្នកនយោបាយ និងគណបក្សនយោបាយ រួមមាន៖

- កិច្ចប្រជុំទៀងទាត់រវាងថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ និងក្រុមអ្នកនយោបាយ
- របាយការណ៍ជាទៀងទាត់អំពីការអភិវឌ្ឍចុងក្រោយបំផុត របស់ភាគីទាំងពីរ ជាធម្មតាគឺរបាយការណ៍ដោយប្រធានក្រុមគណបក្សឬមន្ត្រីគណនេយ្យភាពមួយរូប។ របាយការណ៍នេះ អាចធ្វើឡើងជាលក្ខណៈផ្លូវការ (ឧទាហរណ៍ របាយការណ៍ជាលាយលក្ខណ៍អក្សរ ដាក់ជូនថ្នាក់ដឹកនាំគណបក្សនយោបាយ ចុះកាលបរិច្ឆេទច្បាស់លាស់ ឬដាក់ជូនសមាជិកអំឡុងពេលកិច្ចប្រជុំបក្ស) ឬជាលក្ខណៈមិនផ្លូវការ (ការកោះហៅចូលកិច្ចប្រជុំ ការផ្ញើសារ ការផ្ញើតាមរយៈ អ៊ីម៉ែល)។
- ការចូលរួមនៅក្នុងកិច្ចការពាក់ព័ន្ធនឹងគណបក្សទាំងមូល។ សមាជិករបស់ក្រុមអ្នកនយោបាយ គួរតែចូលរួមក្នុងការជ្រើសរើសថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ។ ផ្ទុយមកវិញ គណបក្សនយោបាយគួរតែមានសិទ្ធិក្នុង

ការជ្រើសរើសថ្នាក់ដឹកនាំរបស់ក្រុមអ្នកនយោបាយបានដែរ។ ការអនុវត្តរបៀបនេះ គឺថ្នាក់ដឹកនាំទាំងពីរប្រើសិទ្ធិស្របច្បាប់បានយ៉ាងទូលំទូលាយ ខណៈ កិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ ក្នុងការសម្របសម្រួលឲ្យបានកាន់តែប្រសើរ។ ព្រឹត្តការណ៍ទូទៅ ឬដំណើរទស្សនកិច្ចជាមួយសមាជិកនៃក្រុមអ្នកនយោបាយ និងគណបក្សនយោបាយ គឺជាវិធីសាស្ត្រមួយផ្សេងទៀត ក្នុងការពង្រឹងទំនាក់ទំនងបុគ្គលរវាងសមាជិក និងបង្កើនការផ្លាស់ប្តូរព័ត៌មានរវាងស្ថាប័នទាំងពីរ។

## ខ. ការរៀបចំសកម្មភាពគណបក្សនៅក្នុងអង្គនីតិបញ្ញត្តិ

*i. ប្រធានក្រុម (បុគ្គល)*

ដូចបានរៀបរាប់ខាងលើ (២.គ) ប្រធានក្រុមគណបក្សដើរតួនាទីដ៏សំខាន់ក្នុងជីវភាពប្រចាំថ្ងៃរបស់ក្រុមអ្នកនយោបាយ។

តួនាទីមុខងារទាំងនោះ រួមមាន៖

- បង្កើតបញ្ជីឈ្មោះសមាជិក ដែលគាត់ចង់ឡើងបញ្ចេញមតិយោបល់ ក្នុងសម័យប្រជុំទាក់ទងទៅនឹងញត្តិពិសេសណាមួយ និងរយៈពេលនិយាយយូរប៉ុណ្ណា។ ប្រធានក្រុមរៀបចំឱ្យមានការចូលរួមធ្វើបទអន្តរាគមន៍ ពីសំណាក់ ក្រុមអ្នកនយោបាយរបស់ខ្លួន អំឡុងពេលសម័យប្រជុំសភា ហើយបែងចែករយៈពេលនៃការថ្លែងការណ៍ទៅកាន់សមាជិក។ ប្រធានរៀបរាប់កែសម្រួលពេលវេលាតាមដែលអាចធ្វើបានផងដែរ ថាមានសមាជិកណាខ្លះចង់ឡើង ធ្វើបទបង្ហាញ។
- ត្រូវធានាថាសមាជិកមួយចំនួន នៃក្រុមអ្នកនយោបាយ នឹងចូលរួមសម្រាប់ការបោះឆ្នោត។ នេះតម្រូវឲ្យកោះហៅពួកគាត់ ឬផ្ញើសារអេឡិចត្រូនិចទៅកាន់ពួកគាត់ ដើម្បីធានាថាការចូលរួមពួកគាត់ទៅតាមពេលវេលាចាំបាច់។
- វាយតម្លៃលើជំហររបស់សមាជិកផ្សេងៗទៀត ទាក់ទងនឹងបញ្ហាជាក់លាក់

មួយចំនួន និងលើការគាំទ្រប្រកបដោយសក្តានុពល របស់ពួកគាត់ចំពោះសេចក្តីព្រាងច្បាប់។ នេះមានន័យថា ត្រូវរក្សាទំនាក់ទំនងជាមួយសមាជិកមុនពេលប្រជុំបោះឆ្នោត ដើម្បីស្វែងយល់ពីការខ្វែងគំនិតគ្នាដែលអាចធ្វើទៅបានជាមួយអ្នកតំណាងមួយចំនួន ក្នុងការបោះឆ្នោតគាំទ្រសេចក្តីព្រាងច្បាប់នេះ។ ប្រធានគួរតែព្យាយាមបញ្ចុះបញ្ចូលសមាជិកក្រុមរបស់ខ្លួន ត្រូវឆ្លើយតបនឹងសំណួររបស់ពួកគាត់ និងរៀបចំកិច្ចប្រជុំរវាងសមាជិកទាំងនោះ និងមេដឹកនាំក្រុមអ្នកនយោបាយ នៅក្នុងករណីតានតឹង។ ការដោះស្រាយការភ័ន្តច្រឡំ ឬបញ្ហាបន្តិចបន្តួចនៅមុនពេលសម័យប្រជុំពេញអង្គ អាចធ្វើឱ្យក្រុមអ្នកនយោបាយសាមគ្គីគ្នា និងមានសំឡេងកាន់តែខ្លាំងក្នុងការបោះឆ្នោត ហើយផ្តល់ឱ្យមានឱកាសទទួលបានជោគជ័យ។

- ការផ្សព្វផ្សាយព័ត៌មាន និងធានាថាគ្រប់សមាជិកម្នាក់ៗទទួលបានព័ត៌មានថ្មីជានិច្ច។ ឯកសារដែលបានធ្វើឱ្យជារៀងរាល់សប្តាហ៍ដោយប្រធានក្រុម ក៏បានផ្តល់ការណែនាំទិសដៅអំពីការបោះឆ្នោត ដែលបានអនុម័តដោយមេដឹកនាំនៃក្រុមអ្នកនយោបាយផងដែរ (សូមមើលចំណុចខាងក្រោម៖ ៣.ខ.២)។
- ការរៀបចំសេចក្តីណែនាំជាកញ្ចប់ ដែលនៅក្នុងនោះ ប្រធានបានរំលេចអំពីចំណុចសំខាន់ៗដែលគណបក្ស ចង់សង្កត់ប្រាប់ឱ្យសមាជិករបស់ខ្លួនលើកឡើងបញ្ជាក់ជាមួយនឹងម្ចាស់ឆ្នោតរបស់ខ្លួន ឬជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ឧទាហរណ៍ នៅពេលបញ្ហាជាក់លាក់ណាមួយកើតឡើង ប្រធានគួរតែពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំ របស់ក្រុមអ្នកនយោបាយ និងគណបក្សនយោបាយ ដើម្បីចងក្រងយោបល់នេះ ធ្វើជាអំណះអំណាងដ៏រឹងមាំ ដោយឈរលើជំហររបស់គណបក្សដែលគាំទ្របញ្ហាពាក់ព័ន្ធនេះ។ សមាជិកក្រុមអ្នកនយោបាយទាំងអស់គួរតែអានឯកសារនេះ ព្រោះវានឹងផ្តល់ឱ្យគាត់ជាមួយយុទ្ធសាស្ត្រ ក្នុងការការពារជំហររបស់បក្ស និងនៅពេលពួកគាត់ជួបម្ចាស់ឆ្នោតរបស់ខ្លួន ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ គណបក្សនេះនឹង និយាយក្នុងសំឡេងតែមួយ និងពង្រឹងសង្គតិភាពបក្សរបស់

ខ្លួន និងភាពមើលឃើញកាន់តែច្បាស់ ក្នុងការស្វែងរកដំណោះស្រាយ។

- ធ្វើជាអន្តរការីរវាងថ្នាក់ដឹកនាំ និងសមាជិករបស់ក្រុមអ្នកនយោបាយដែលមានឥទ្ធិពលតិច។ ប្រធានគួរតែបញ្ជូនបណ្តឹងសារទុក្ខ និងការខ្វែងគំនិតគ្នាទៅថ្នាក់ដឹកនាំរបស់ក្រុមអ្នកនយោបាយ។
- ការជួយសមាជិកដែលទើបជាប់ឆ្នោតថ្មីៗ ក្នុងការទទួលបានការចាប់ផ្តើម និងស្វែងយល់អំពីការងារនៅក្នុងសភា ឬក្នុងក្រុមអ្នកនយោបាយ។ បើសមាជិកថ្មីដឹងពីការទទួលខុសត្រូវរបស់ខ្លួនបានឆាប់រហ័សនោះ ក្រុមអ្នកនយោបាយក៏កាន់តែមានប្រសិទ្ធភាពទៅតាមនោះដែរ។

*ii. សេចក្តីណែនាំប្រចាំសប្តាហ៍ (សារាចរ)*

នៅសហរដ្ឋអាម៉េរិក ប្រធានត្រៀមរៀបចំសេចក្តីណែនាំដែលគូសបញ្ជាក់អំពីតារាងពេលវេលាច្បាប់ របស់សភាជាមួយនឹងការកំណត់ពេលវេលាខុសៗគ្នាសម្រាប់ការបោះឆ្នោត។ នៅប្រទេសអង់គ្លេស ការប្រឹក្សាទាំងនេះត្រូវបានគេហៅថា "សេចក្តីណែនាំ" ហើយជម្រើសផ្សេងៗ ត្រូវបានគូសបន្ទាត់ពីក្រោមទៅតាមសារៈសំខាន់របស់វា។ នៅពេលជម្រើសមួយត្រូវបានគូសបន្ទាត់បីនៅពីក្រោមជម្រើសនេះសំខាន់ខ្លាំងជាងគេ ហើយតម្រូវឱ្យសមាជិកក្រុមអ្នកនយោបាយមានវត្តមានដើម្បីធ្វើការបោះឆ្នោត។ ជម្រើសដែលត្រូវបានគូសបន្ទាត់ពីរនៅពីក្រោម ជម្រើសនេះសំខាន់ល្មម ប៉ុន្តែសមាជិកក្រុមអាចអវត្តមានតាមរយៈនីតិវិធី «ចាប់គូ»[៦]។ ជម្រើសដែលគូសបន្ទាត់មួយនៅពីក្រោម មានន័យថាអវត្តមានអំឡុងពេលបោះឆ្នោតអាចយោគយល់ឱ្យបាន។

៦ នីតិវិធីចាប់គូរ អនុញ្ញាតឱ្យសមាជិកម្នាក់នៃក្រុមអ្នកនយោបាយភាគច្រើនអវត្តមានក្នុងការបោះឆ្នោត ប្រសិនបើសមាជិកម្នាក់នៃក្រុមអ្នកនយោបាយបក្សប្រឆាំង មិនធ្វើការបោះឆ្នោត។ តាមរយៈនេះគេអាចរក្សាតុល្យ ភាពនយោបាយក្នុងសភាឱ្យនៅដដែល ហើយវាមិនធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបោះឆ្នោតឡើយ។ ប្រធានក្រុមតំណាងរាស្ត្រនៃក្រុមអ្នកនយោបាយនីមួយៗ គួរតែជួបគ្នាមុនពេលធ្វើការបោះឆ្នោត ដោយមានបញ្ជីឈ្មោះសមាជិកដែលចង់អវត្តមានអំឡុងពេលបោះឆ្នោត និងចាប់ដៃគូឱ្យពួកគេប្រសិនបើអាចទៅរួច។

សេចក្តីណែនាំប្រចាំសប្តាហ៍ ឬសេចក្តីជូនដំណឹង គឺជាឧបករណ៍ដ៏សំខាន់ ដែលថ្នាក់ដឹកនាំក្រុមនយោបាយអាចប្រើប្រាស់ ដើម្បីធ្វើទំនាក់ទំនងជាមួយ សមាជិកឱ្យកាន់តែមានប្រសិទ្ធភាព។ ប្រធានក្រុមតំណាងរាស្ត្រ គឺជាអ្នកចេញ លិខិតទាំងនេះ។ ឯកសារនេះ ត្រូវសង្ខេបគ្រប់ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធ នឹងកិច្ចការរបស់សមាជិកសម្រាប់សប្តាហ៍បន្ទាប់។ ប្រធានគួរតែរំឭកអំពីកាល បរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត និងកិច្ចប្រជុំដែលអាចនឹងកើតឡើង អំឡុងសប្តាហ៍ខាងមុខនេះ។ ព្រឹត្តការណ៍ផ្សេងៗ ដែលសមាជិកក្រុមអ្នកនយោ បាយអាចត្រូវបានអញ្ជើញចូលរួមនោះ ក៏អាចបញ្ចូលទៅក្នុងសារាចរនេះផង ដែរ។

សារាចរនេះ គួរតែផ្ញើចេញជារៀងរាល់សប្តាហ៍ទៅឱ្យសមាជិកនីមួយៗ ហើយគួរតែចាត់ទុកថាជាប្រភពព័ត៌មានសំខាន់។ នេះមានន័យថា សមាជិក ទាំងអស់អាចរកបានព័ត៌មាន នៅពេលត្រូវការព័ត៌មាននេះ ឬនៅពេលមានការ ងឿងឆ្ងល់អំពីជំហររបស់បក្សទៅលើជម្រើសនៃការបោះឆ្នោតជាក់លាក់មួយ។

សេចក្តីណែនាំនេះត្រូវបោះពុម្ព និងចែកចាយទៅឱ្យសមាជិក ប៉ុន្តែក៏អាច បញ្ជូនឱ្យតាមរយៈសារអេឡិចត្រូនិច ឬបង្ហោះនៅលើគេហទំព័ររបស់សមា ជិក។ នេះគួរតែងាយក្នុងការទទួលបាន សរសេរឱ្យមានលក្ខណៈសាមញ្ញ និងច្បាស់លាស់ ហើយមិនគួរវែងពេកនោះទេ។ ម្យ៉ាងវិញទៀត សមាជិកគួរតែ អាចស្វែងរកព័ត៌មានទាំងអស់នៅក្នុងសេចក្តីណែនាំ ដែលពួកគេអាចត្រូវការ ទាក់ទងនឹងសកម្មភាពរបស់ក្រុមនយោបាយនិងសភាសម្រាប់សប្តាហ៍បន្ទាប់។

ជាចុងក្រោយ សេចក្តីណែនាំនេះគួរតែបោះពុម្ពឱ្យបានគ្រប់គ្រាន់ជាមុន សម្រាប់សមាជិកមានពេលអាន និងអាចរៀបចំផែនការដោយយោងទៅតាម តារាងពេលវេលារបស់ខ្លួន។ ទោះជាយ៉ាងណា ដើម្បីធានាបានថា ព័ត៌មាន ទាំងនេះមានបញ្ចូលនូវការអភិវឌ្ឍ និងព័ត៌មានលម្អិតថ្មីៗទាំងឡាយ អំពីសកម្ម ភាពបន្ទាប់របស់សភា គួរតែមិនត្រូវផ្ញើមកយឺតពេលនោះទេ។

### *iii. កិច្ចប្រជុំរបស់ក្រុមអ្នកនយោបាយ*

ដូចគ្នានឹងសេចក្តីជូនដំណឹងប្រចាំសប្តាហ៍ដែរ កិច្ចប្រជុំរបស់ក្រុមអ្នកនយោបាយ គឺជាឱកាស ដែលព័ត៌មានអាចចែករំលែកក្នុងចំណោមសមាជិកបាន។ ប៉ុន្តែ អំឡុង កិច្ចប្រជុំក្រុមអ្នកនយោបាយ អាចចែករំលែកព័ត៌មានបានកាន់តែទូលំទូលាយជាង។

ជាបឋម កិច្ចប្រជុំបានប្រមូលផ្តុំសមាជិកទាំងអស់មកជួបជុំគ្នាដើម្បីធ្វើការផ្លាស់ប្តូរទស្សនៈ និងធ្វើបច្ចុប្បន្នភាព។ កិច្ចប្រជុំគឺជាឱកាសសម្រាប់កិច្ចពិភាក្សាដេញដោល និងដោះស្រាយបញ្ហាក់ពីការភ័ន្តច្រឡំ។ មិនតែប៉ុណ្ណោះ ថែមទាំងផ្តល់ឱកាសឱ្យសមាជិកមិនសូវមានឥទ្ធិពល បង្ហាញពីអារម្មណ៍ថ្នាំងថ្នាក់ដែលពួកគេមិនពេញចិត្តនូវយុទ្ធសាស្រ្តរបស់ក្រុមអ្នកនយោបាយ។ មិនស្តាប់ពួកគេនិយាយអំពីបញ្ហាកង្វល់របស់ពួកគាត់ ពាក់ព័ន្ធនឹងចំណុចខ្លះៗនៃទស្សនៈ និងការណែនាំរបស់ក្រុមអ្នកនយោបាយ ដែលអាចបណ្តាលឱ្យមានការបន្តភ័ន្តច្រឡំ ហើយនិងការបែងចែកជាក្រុមជាពួកនៅក្នុងក្រុមអ្នកនយោបាយ។ ប្រការនេះ នឹងនាំឱ្យពួកគេចេញមុខរិះគន់ក្រុមអ្នកនយោបាយជាសាធារណៈ ចំពោះការមិនសប្បាយចិត្តរបស់សមាជិកទាំងនោះ ឬសូម្បីតែងតែការបោះឆ្នោតប្រឆាំង មិនគាំទ្រអំឡុងពេលសម័យប្រជុំពេញអង្គនៃសភា។ ការខ្វែងគំនិតដែលអាចកើតមាន គួរតែដោះស្រាយឱ្យបាននៅមុនពេលបោះឆ្នោតអំឡុងពេលកិច្ចប្រជុំក្រុមអ្នកនយោបាយ។

អំឡុងពេលប្រជុំក្រុមអ្នកនយោបាយ មេដឹកនាំក្រុមក៏ត្រូវបានជ្រើសរើស និងធ្វើការសម្រេចចិត្តផងដែរ។ នៅពេលចាប់ផ្តើមសម័យប្រជុំរបស់សភា ឬក្រោយពេលបោះឆ្នោតសមាជិកទាំងអស់ បោះឆ្នោតដើម្បីជ្រើសតាំងប្រធានក្រុម ក៏ដូចជាសមាជិកដទៃទៀតរបស់ថ្នាក់ដឹកនាំគណបក្ស។ ក្រុមនេះក៏អាចបោះឆ្នោតឱ្យមានការផ្លាស់ប្តូរតួនាទី ឬកែប្រែគោលនយោបាយរបស់ក្រុមអ្នកនយោបាយបានដែរ។ ក្នុងករណីគោលនយោបាយរបស់គណបក្ស មិនអាចដោះស្រាយបញ្ហាបាន កិច្ចប្រជុំក្រុមអ្នកនយោបាយមានតួនាទីបង្កើតឡើង

ដើម្បីស្វែងរកដំណោះស្រាយ។ មានការឯកភាពខាងលើនេះ ខណៈនៅពេលជាមួយគ្នានោះ មនោគមន៍វិជ្ជា និងអត្តសញ្ញាណទូទៅរបស់គណបក្ស គឺរក្សាទុកនូវនៅដដែល។

ក្រុមនយោបាយជាធម្មតាជួបប្រជុំជារៀងរាល់មួយសប្តាហ៍ម្តង នៅពេលបើកសម័យប្រជុំពេញអង្គ។ ពេលវេលា និងកាលបរិច្ឆេទនៃកិច្ចប្រជុំគួរតែកំណត់ និងជជែកគ្នាឱ្យបានច្បាស់ប្រាប់សមាជិកទាំងអស់។ របៀបវារៈនៃកិច្ចប្រជុំគួរតែរៀបចំទុកជាមុនដោយថ្នាក់ដឹកនាំនៃក្រុមនយោបាយ (ប្រធាន អនុប្រធាន ប្រធានក្រុមតំណាងរាស្ត្រ ប្រធានគណៈកម្មាធិការក្រុមនយោបាយ និងវាគ្មិន។)

របៀបវារៈកិច្ចប្រជុំអាស្រ័យលើស្ថានភាព ហើយអាចខុសគ្នាពីមួយសប្តាហ៍ទៅមួយសប្តាហ៍ ជាទូទៅដូចជា៖

១. សុន្ទរកថាបើកកិច្ចប្រជុំដោយប្រធានក្រុមនយោបាយ
២. សុន្ទរកថាដោយប្រធានក្រុមតំណាងរាស្ត្រ
៣. កិច្ចពិភាក្សាដេញដោល អំពីគោលជំហរដែលត្រូវអនុវត្តពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ ដែលត្រូវដាក់ចេញក្នុងការបោះឆ្នោតអំឡុងពេលប្រជុំសភាលើកក្រោយទៀត។
៤. កិច្ចពិភាក្សាដេញដោលអំពីយុទ្ធសាស្ត្រដែលត្រូវអនុម័ត
៥. កិច្ចពិភាក្សាដេញដោលបើកចំហរ ដែលសមាជិកអាចពិភាក្សាអំពីកង្វល់របស់ខ្លួន ឬលើកឡើងអំពីប្រធានបទថ្មីៗ

## គ. ការបង្កើតគោលនយោបាយលម្អិត

ការទទួលខុសត្រូវរបស់ក្រុមអ្នកនយោបាយនៅក្នុងការបង្កើតគោលនយោបាយអាចមានលក្ខណៈខុសគ្នា ពីគណបក្សមួយទៅគណបក្សមួយ។ វាអាស្រ័យលើស្ថានភាពនយោបាយខុសៗគ្នា និងប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ និងទំនាក់ទំនងរវាងគណបក្សនយោបាយ និងក្រុមអ្នកនយោបាយ។

ទោះជាយ៉ាងណា សមាជិកសភា គឺជានីតិបុគ្គលដែលមានវត្តមាននៅក្នុងសម័យប្រជុំពេញអង្គរបស់សភា ហើយក៏ជាអ្នកបោះឆ្នោតគាំទ្រ ឬប្រឆាំងទៅនឹងសេចក្តីព្រាងច្បាប់ដែរ។ ដូច្នេះហើយ ប្រការសំខាន់នោះ គឺពួកគាត់ត្រូវចូលរួមក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់ដែរ ក្នុងការដាក់បញ្ជូនដោយគណបក្សរបស់ខ្លួន និងចូលរួមចំណែកក្នុងការបង្កើតគោលនយោបាយ ដែលឆ្លើយតបនឹងគ្នា។ ប្រសិនបើសមាជិកមិនពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ដែលកំពុងតែពិភាក្សាក្នុងសភាទេនោះ ហើយពួកគាត់មានអារម្មណ៍ថាត្រូវបានគេមើលរំលងនោះ ពួកគេអាចនឹងព្យាយាមក្នុងការបោះឆ្នោតប្រឆាំងតបវិញ។ សមាជិកក្រុមអ្នកនយោបាយ គឺជាសមាជិកដ៏សំខាន់របស់គណបក្ស ហើយមានសិទ្ធិស្របច្បាប់ក្នុងការបោះឆ្នោតនេះ។ វាជារឿងសាមញ្ញទៅហើយ ដែលពួកគាត់ត្រូវការក្នុងការដាក់បញ្ចូលទៅក្នុងដំណើរការបង្កើតគោលនយោបាយបក្ស ទាំងជាលក្ខណៈផ្លូវការ ឬមិនផ្លូវការ។

ការបង្កើតគោលនយោបាយត្រូវធ្វើឡើងជាច្រើនដំណាក់កាល។ សមាជិកក្រុមអ្នកនយោបាយត្រូវតែចូលរួមគ្រប់ក្នុងដំណាក់កាលទាំងអស់។

១. **ការកំណត់របៀបវារៈ** នេះជាដំណាក់កាលកំណត់អត្តសញ្ញាណនៃបញ្ហា។ ការទទួលស្គាល់នេះ គឺថាជាអ្វីមួយត្រូវកែលម្អអាចកើតមានឡើងតាមរយៈការចូលរួមរបស់រដ្ឋាភិបាល។ សមាជិកមានភាពជិតស្និទ្ធ និងមានទំនាក់ទំនងជាធម្មតាដោយផ្ទាល់ជាមួយម្ចាស់ឆ្នោតរបស់ខ្លួន។ តាមរយៈនេះ ពួកគាត់មានសិទ្ធស្របច្បាប់ និងប្រើប្រាស់បានយ៉ាងពេញលេញ ក្នុងការស្វែងរកកំហុសដែលតម្រូវតាមគោលនយោបាយ។ ពួកគេគួរតែអាចមានឥទ្ធិពលលើការកំណត់របៀបវារៈ។

២. **ការវិភាគគោលនយោបាយ និងការបង្កើតឧបករណ៍គោលនយោបាយ** ដែលជាយុទ្ធសាស្រ្ត និងជម្រើសខុសៗគ្នា ត្រូវបានចាត់ទុកថាជាដំណោះស្រាយប្រកបដោយសក្តានុពល ក្នុងការកំណត់បញ្ហាមុន។ ដោយហេតុថាបទពិសោធន៍របស់ពួកគេមានជាមួយនឹងស្ថាប័ននយោបាយ និងភាពយល់ដឹងរបស់ពួកគេអំពីបញ្ហា និងដំណោះស្រាយប្រឈមរបស់ម្ចាស់ឆ្នោតដែល

ពាក់ព័ន្ធជាមួយសមាជិករបស់ក្រុមអ្នកនយោបាយ គឺជាបញ្ហាសំខាន់។

៣. **ការប្រឹក្សាយោបល់** ការសាកសួរប្រជាជនដែលរងផលប៉ះពាល់ដោយសារបញ្ហាអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគាត់។ រៀបចំបទសម្ភាសន៍ និងធ្វើឲ្យប្រសើរឡើង នូវឱកាសដែលនឹងប៉ះពាល់ដល់គោលនយោបាយចាស់/ថ្មី។ ចំណុចនេះ ក៏អាចផ្តល់អត្ថប្រយោជន៍សំខាន់ក្នុងការស្នើសុំឱ្យអ្នកជំនាញបញ្ចេញមតិយោបល់ និងគំនិតរបស់ខ្លួន។ ការប្រមូលផ្តុំព័ត៌មានបែបនេះ អាចរៀបចំឡើងដោយក្រុមអ្នកនយោបាយ ដែលជាក្រុមការងារធ្វើការងារលើប្រធានបទនេះ។ ព្រោះថា ពួកគាត់មានជំនាញក្នុងវិស័យមួយជាក់លាក់ និងធ្វើការជាមួយបណ្តាញអ្នកជំនាញពាក់ព័ន្ធនឹងវិស័យនេះ។

៤. **ការសម្របសម្រួលនិងដំណាក់កាលសម្រេចចិត្ត** ជាដំណាក់កាលមួយដ៏សំខាន់ ហើយសមាជិកគួរតែចូលរួម។ លទ្ធផលបោះឆ្នោតជាវិជ្ជមាន គឺចាំបាច់ណាស់ ដើម្បីធ្វើឱ្យសេចក្តីព្រាងច្បាប់មួយក្លាយជាច្បាប់។ ការបោះឆ្នោតរបស់ពួកគាត់បានបង្ហាញថា ជាការទទួលខុសត្រូវរបស់សមាជិកនៅចំពោះមុខម្ចាស់ឆ្នោតរបស់ពួកគាត់ ហើយពួកគាត់មិនចង់ប្រថុយប្រថានជាមួយនឹងការបោះឆ្នោតឡើងវិញរបស់ពួកគាត់ទេ សម្រាប់គោលនយោបាយមួយដែលមិនពាក់ព័ន្ធដល់ពួកគាត់ដែរ។ រួមបញ្ចូលទាំងអ្នកតំណាងឱ្យចូលរួម ក្នុងការសម្រេចចិត្ត ក្នុងការតាក់តែងគោលនយោបាយនេះ គឺជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធផល។

៥. **ការអនុវត្ត និងការវាយតម្លៃ** ទំនាក់ទំនងជិតស្និទ្ធរបស់សមាជិកជាមួយម្ចាស់ឆ្នោត ធ្វើឱ្យពួកគាត់ក្លាយជាអ្នកតស៊ូមតិគាំទ្រគោលនយោបាយដ៏ល្អមួយ។ ពួកគាត់អាចពន្យល់អំពីគោលនយោបាយទៅកាន់ប្រជាពលរដ្ឋ និងឆ្លើយសំណួរអំឡុងពេលចុះមូលដ្ឋានជួបប្រជាជន ក្នុងមណ្ឌលបោះឆ្នោតនីមួយៗរបស់ពួកគាត់។ ដូច្នេះហើយ ពួកគាត់អាចប្រមូលបាននូវគំនិតយោបល់ជាបឋមនៅក្នុងដៃ។ ពួកគាត់ គឺជាគន្លឹះដ៏សំខាន់ក្នុងការយល់ដឹងអំពីរបៀប បង្កើតគោលនយោបាយយ៉ាងណានៅពេលចុះមូលដ្ឋាន ក៏ដូច

ជាវាយតម្លៃលើសមិទ្ធផលនៃគោលនយោបាយនេះ។ ការធ្វើបទសម្ភាសន៍ក៏ជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយផងដែរ សម្រាប់ការវាយតម្លៃលើគោលនយោបាយក្រោយពេលអនុវត្ត។ តាមរយៈការវាយតម្លៃចុងបញ្ចប់នៃគោលនយោបាយសម្រាប់អនាគតនឹងត្រូវមានទម្រង់ល្អមួយ។

## ឃ. ការគ្រប់គ្រងរដ្ឋាភិបាល

*អំណាចនីមួយៗ គួរតែអនុវត្តន៍ក្នុងការបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងមិនមែនផលប្រយោជន៍របស់ខ្លួនឡើយ*

នៅក្នុងប្រព័ន្ធសភា រដ្ឋាភិបាលត្រូវមានសម្លេងគាំទ្រភាគច្រើនពីអ្នកតំណាងរាស្ត្រ។ បើពុំដូច្នោះទេ សមាជិកសភាអាចធ្វើការផ្តួលរំលំរដ្ឋាភិបាល ហើយបង្កើតរដ្ឋាភិបាលថ្មីឱ្យឡើងកាន់អំណាច ដោយផ្តោតលើគុណតម្លៃរបស់ខ្លួន។ ការគំរាមកំហែងនេះ បានជំរុញឱ្យរដ្ឋាភិបាលត្រូវស្តាប់សភា។ តែរដ្ឋាភិបាលក៏អាចរំលាយរដ្ឋសភាបានដែរ។ សមាជិកសភា ត្រូវបានលើកទឹកចិត្តក្នុងការសហការជាមួយរដ្ឋាភិបាល និងបំពេញការងារប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណា អំណាចនីមួយៗនៃអំណាចទាំងបី (អំណាចនីតិប្រតិបត្តិ រដ្ឋាភិបាល អំណាចនីតិប្បញ្ញត្តិ រដ្ឋសភា និងអំណាចតុលាការ) មានអំណាច និងភារកិច្ចដើម្បីធានាបាននូវតុល្យភាពរវាងអំណាចទាំងបីហើយក៏ពុំមានការបំពានអំណាចរវាងគ្នានោះដែរ។ អំណាចនីមួយៗ គួរតែអនុវត្តន៍ក្នុងការបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងមិនមែនផលប្រយោជន៍របស់ខ្លួនឡើយ។ ក្រុមអ្នកនយោបាយ មិនថាពួកគាត់នៅជាក្រុមគណបក្សនយោបាយ ដែលមានសំឡេងភាគច្រើន ឬជាគណបក្សប្រឆាំងនោះទេ គឺពួកគាត់ជាផ្នែកមួយដើរ តួនាទីសំខាន់ក្នុងការរក្សាតុល្យាភាពទំនាក់ទំនងរវាងអំណាចនីមួយៗ។

## ង. ការតំណាងគណបក្សនយោបាយ៖ ទំនាក់ទំនងរបស់គណបក្ស

គណបក្សនយោបាយ និងក្រុមអ្នកនយោបាយគួរតែសហការគ្នាបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ សមាជិករបស់ក្រុមអ្នកនយោបាយ គឺជាបេះដូងនៃសកម្មភាពនយោបាយ ហើយជាញឹកញាប់ត្រូវបានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឈ្លេចសួរសំណួរ ដើម្បីឱ្យមានប្រតិកម្មចំពោះប្រធានបទដែលកំពុងក្តៅគគុក។ ផ្ទុយពីសេវាទំនាក់ទំនងរបស់សភា សមាជិករបស់ក្រុមអ្នកនយោបាយមិនត្រូវប្រកាន់ភាពអព្យាក្រឹត្យរហូតនោះទេ នៅពេលទំនាក់ទំនងជាមួយអ្នកស្តាប់។ ពួកគេមានសិទ្ធិពេញលេញក្នុងការចូលរួមកិច្ចពិភាក្សាដេញដោលផ្នែកនយោបាយ ស្របតាមរបៀបវារៈនយោបាយរបស់បក្ស និងរបស់ក្រុមអ្នកនយោបាយ។ សមាជិករបស់ក្រុមអ្នកនយោបាយ និងជាពិសេសអ្នកនាំពាក្យក្រុមអ្នកនយោបាយ គឺជាទ្រព្យសកម្មដ៏មានសារៈសំខាន់សម្រាប់ទំនាក់ទំនងរបស់បក្ស។ ប្រសិនបើថ្នាក់ដឹកនាំ និងអ្នកនាំពាក្យរបស់គណបក្សនយោបាយ ព្រមទាំងក្រុមអ្នកនយោបាយ មានការសម្របសម្រួលគ្នាគ្រប់គ្រាន់នោះពួកគេមានឱកាសចែករំលែកព័ត៌មានគ្នាកាន់តែទូលំទូលាយ នឹងទទួលអត្ថប្រយោជន៍ ដល់កិត្តិយសជាសាធារណៈរបស់ពួកគាត់ទៀតផង។ កត្តាសំខាន់នោះ គឺពួកគាត់ត្រូវជួបប្រជុំគ្នាឲ្យបានទៀងទាត់ និងយល់ស្របលើយុទ្ធសាស្ត្រទំនាក់ទំនងរួមគ្នា និងនាំឲ្យពួកគាត់ទទួលបានព័ត៌មានពីគ្នាទៅវិញទៅមកនៅគ្រប់កាលៈទេសៈទាំងអស់ ដូចជាការសម្ភាសន៍ ពេលចុះមូលដ្ឋាន ពេលធ្វើសុន្ទរកថាបើកកិច្ចប្រជុំនៅក្នុងព្រឹត្តិការណ៍ណាមួយ ទស្សនកិច្ចក្រៅប្រទេស ។ល។

សមាជិកគួរតែដឹងថា ការបង្ហាញខ្លួនរបស់គាត់ជាសាធារណៈមិនគ្រាន់តែមានតំណាងរបស់គាត់តែប៉ុណ្ណោះទេ គឺត្រូវមានថែមទាំងតំណាងឱ្យគណបក្សទាំងមូលតែម្តង។

# ឧបសម្ព័ន្ធ

# ឧបសម្ពន្ធ១៖ សម្រង់ច្បាប់ស្តីពីសមាជិកសភាពសហព័ន្ធអាល្លឺម៉ង់

## ផ្នែក ១១
## ក្រុមអ្នកតំណាងរាស្ត្រ

### ចំណុច ៤៥
### ការបង្កើតក្រុមអ្នកតំណាងរាស្ត្រ

**(១)** សមាជិកសភាសហព័ន្ធអាល្លឺម៉ង់ អាចបង្កើតក្រុមអ្នកតំណាងរាស្ត្រដោយខ្លួនឯង។

**(២)** ព័ត៌មានលម្អិតអាចរកបាន នៅក្នុងបទបញ្ជាផ្ទៃក្នុងនៃសភាសហព័ន្ធអាល្លឺម៉ង់។

### ចំណុច ៤៦
### ស្ថានភាពគតិយុត្តិ (ច្បាប់)

**(១)** ក្រុមអ្នកតំណាងរាស្ត្រ គឺជាសមាគមនៃសមាជិកសភាសហព័ន្ធអាល្លឺម៉ង់ដែលមានសមត្ថភាពទទួលខុសត្រូវខាងផ្លូវច្បាប់។

**(២)** ក្រុមអ្នកតំណាងរាស្ត្រអាចប្តឹង ឬអាចទទួលរងការប្តឹង។

**(៣)** ក្រុមអ្នកតំណាងរាស្ត្រ មិនមែនជាផ្នែកមួយនៃរដ្ឋបាលសាធារណៈទេ។ ពួកគេមិនប្រើប្រាស់សិទ្ធិអំណាចរបស់រដ្ឋាភិបាលឡើយ។

### ចំណុច ៤៧
### នាទីកិច្ច

**(១)** ក្រុមអ្នកតំណាងរាស្ត្រ ត្រូវជួយបំពេញភារកិច្ចរបស់សភាសហព័ន្ធអាល្លឺម៉ង់។

**(២)** ក្រុមអ្នកតំណាងរាស្ត្រ  អាចធ្វើការងាររួមគ្នាជាមួយក្រុមអ្នកតំណាងរាស្ត្រ ឬក្រុមគណបក្សនយោបាយនៅក្នុងសភាដទៃទៀត និងជាមួយស្ថាប័នសភាជាតិ និងអន្តរជាតិ។

(៣) ក្រុមអ្នកតំណាងរាស្ត្រ និងសមាជិករបស់ខ្លួន ត្រូវផ្តល់ព័ត៌មានដល់សាធារណជនអំពីសកម្មភាពទាំងឡាយរបស់ខ្លួន។

### ចំនុច ៤៨
### ការរៀបចំ

(១) ក្រុមអ្នកតំណាងរាស្ត្រ មានកាតព្វកិច្ចក្នុងការរៀបចំរចនាសម្ព័ន្ធ និងវិធីសាស្ត្រការងាររបស់ខ្លួន ដោយយោងតាមគោលការណ៍របស់សភាប្រជាធិបតេយ្យ ហើយត្រូវធ្វើយ៉ាងណាផ្សឹសង្វាក់រចនាសម្ព័ន្ធ និងវិធីសាស្ត្រការងាររបស់ខ្លួន សមស្របតាមគោលការណ៍ដែលបានរៀបរាប់ខាងលើ។

(២) ក្រុមអ្នកតំណាងរាស្ត្រ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

### ចំណុច ៤៩
### កាតព្វកិច្ចរក្សាការសម្ងាត់របស់មន្ត្រីបម្រើការនៃក្រុមអ្នកតំណាងរាស្ត្រ

(១) បើទោះជាបញ្ចប់កិច្ចសន្យាការងារហើយក្តី មន្ត្រីបម្រើការងាររបស់ក្រុមអ្នកតំណាងរាស្ត្រ ត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់លើរាល់កិច្ចការទាំងអស់ដែលខ្លួនបានដឹង អំឡុងពេលបំពេញការងាររបស់ខ្លួន។ ការ-ណ៍នេះ មានសុពលភាពមិនមែនសម្រាប់តែការពិតជាក់ស្តែង ឬព័ត៌មានដែលគ្មានតម្លៃសម្រាប់រក្សាការសម្ងាត់នោះទេ។

(២) បើទោះជាបញ្ចប់កិច្ចសន្យាការងារហើយក្តី មន្ត្រីបម្រើការងាររបស់ក្រុមតំណាងរាស្ត្រ មិនអាចធ្វើសក្ខីកម្ម ឬ ធ្វើសេចក្តីថ្លែងប្រាប់ព័ត៌មានណាមួយដោយគ្មានការអនុញ្ញាតឡើយ មិនថាឡើយទាំងក្នុង និងក្រៅតុលាការ។ ប្រធានក្រុមអ្នកតំណាងរាស្ត្រដែលពាក់ព័ន្ធ ត្រូវទទួលខុសត្រូវលើការផ្តល់ការអនុញ្ញាតនេះ។

(៣) បទប្បញ្ញត្តិនៃចំណុចរង (១) និង (២) ខាងលើ ត្រូវអនុវត្តដោយគ្មានការរើសអើងលើតួនាទីច្បាប់ក្នុងការរាយការណ៍អំពីបទឧក្រិដ្ឋ និងត្រូវ

ប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិបតេយ្យជាមូលដ្ឋាន ក្នុងករណីដែលពួកគេស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។

## ចំណុច ៥០
## ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗ

(១) ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ក្រុមអ្នកតំណាងរាស្ត្រ ត្រូវមានសិទ្ធិទទួលបានប្រាក់ឧត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗ ពីថវិកាសហព័ន្ធ។

(២) ប្រាក់ឧបត្ថម្ភ ត្រូវរួមមានកញ្ចប់ថវិកាគោលសម្រាប់ក្រុមអ្នកតំណាងរាស្ត្រនីមួយៗ កញ្ចប់ថវិកាសម្រាប់សមាជិកម្នាក់ៗ និងថវិកាបន្ថែមសម្រាប់ក្រុមនីមួយៗ ដែលមិនស្ថិតក្រោមរដ្ឋាភិបាល (ប្រាក់បន្ថែមសម្រាប់គណបក្សប្រឆាំង)។ចំនួនកញ្ចប់ថវិកាទាំងនេះនិងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់បក្សប្រឆាំងត្រូវធ្វើការកំណត់ជារៀងរាល់ឆ្នាំ ដោយសភាសហព័ន្ធ។ តាមរយៈការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាយោបល់ ចាស់ទុំ ប្រធានត្រូវធ្វើសេចក្តីព្រាងរបាយការណ៍ដាក់ជូនសភាសហព័ន្ធ ត្រឹមថ្ងៃទី៣០ ខែកញ្ញា ជារៀងរាល់ឆ្នាំ ទាក់ទងនឹងភាពសមហេតុផល នៃការផ្តល់កញ្ចប់ថវិកា និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់បក្សប្រឆាំង ហើយស្របពេលជាមួយគ្នានេះ ក៏ត្រូវដាក់ជូនសំណើដែលបានកែតម្រូវរួចផងដែរ។

(៣) អត្ថប្រយោជន៍ផ្សេងៗ ត្រូវផ្តល់ឱ្យដើម្បីយកទៅប្រើប្រាស់ ស្របតាមច្បាប់ហិរញ្ញវត្ថុ ។

(៤) អត្ថប្រយោជន៍ដែលផ្តល់ឱ្យនៅក្នុងចំណុចរង (១) ខាងលើ អាចត្រូវបានប្រើប្រាស់ដោយក្រុមអ្នកតំណាងរាស្ត្រតែប៉ុណ្ណោះ ដើម្បីបំពេញភារកិច្ចដែលដាក់ចេញដោយច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់បច្ចុប្បន្ន និងបទបញ្ជាផ្ទៃក្នុង នៃសភាសហព័ន្ធអាល្លឺម៉ង់។ ការប្រើប្រាស់អត្ថប្រយោជន៍ទាំងនេះក្នុងគោលបំណងបម្រើផលប្រយោជន៍នយោបាយបក្ស គឺមិនត្រូវបានអនុញ្ញាតឡើយ។

(៥) ប្រាក់ឧបត្ថម្ភដែលត្រូវទូទាត់ ដូចមានចែងក្នុងចំណុចរង(១) ខាងលើនឹង

អាចផ្ទេរទៅក្នុងគណនេយ្យសម្រាប់ដំណាក់កាលបន្ទាប់។

## ចំណុច ៤១
## ការគ្រប់គ្រងថវិកា និងសេដ្ឋកិច្ច គណនេយ្យ

**(១)** សេចក្តីលម្អិតនៃការគ្រប់គ្រងថវិកា និងសេដ្ឋកិច្ច ត្រូវបានចែងក្នុងបទប្បញ្ញត្តិសម្រាប់ការអនុវត្តន៍ ដែលដាក់ចេញដោយក្រុមប្រឹក្សាយោបល់ចាស់ទុំ ក្រោយពេលពិគ្រោះយោបល់ជាមួយនាយកដ្ឋានសវនកម្មសហព័ន្ធ។

**(២)** ក្រុមអ្នកតំណាងរាស្ត្រត្រូវរក្សាគណនីទាំងឡាយ ដែលបង្ហាញពីចំណូលចំណាយ និងទ្រព្យសកម្ម ដែលតម្រូវឱ្យធ្វើការកត់ត្រា។ ទិន្នន័យទាំងនេះត្រូវរក្សាទុកស្របតាមគោលការណ៍គណនេយ្យ ដែលមានការរៀបចំត្រឹមត្រូវ និងស្របតាមគោលបំណងនៃច្បាប់នេះ។

**(៣)** សម្ភារដែលទិញដោយប្រើប្រាស់ប្រាក់ឧបត្ថម្ភនេះ ដូចមានចែងក្នុងចំណុច ៥០(១) លើកលែងតែសម្ភារសម្រាប់ប្រើប្រាស់ក្នុងរយៈពេលខ្លី និងសម្ភារៈដែលមានតម្លៃថោក ត្រូវបញ្ចូល និងបញ្ជាក់នៅក្នុងឯកសារយោង។

**(៤)** គណនេយ្យទាំងនេះ ត្រូវរក្សាទុករយៈពេលប្រាំឆ្នាំ។

## ចំណុច ៤២
## ការកត់ត្រាគណនេយ្យ

**(១)** ក្រុមអ្នកតំណាងរាស្ត្រ ត្រូវទទួលខុសត្រូវជាសាធារណៈលើប្រភពដើម និងការប្រើប្រាស់ធនធានដែលខ្លួនទទួលបាន ដូចមានចែងក្នុងចំណុច ៥០(១) នៃច្បាប់នេះ នៅក្នុងឆ្នាំប្រតិទិននីមួយៗ (ឆ្នាំគណនេយ្យ)។

**(២)** គណនេយ្យ ត្រូវបង្ហាញដូចខាងក្រោម៖

១. ចំណូល

ក. ប្រាក់ឧបត្ថម្ភដែលទទួលបាន អនុលោមតាមចំណុច ៥០(១)

នៃច្បាប់នេះ

ខ. ចំណូលផ្សេងៗ

២. ចំណាយ

ក. ការទូទាត់សរុបដល់សមាជិកក្រុមសម្រាប់ការបំពេញមុខងារពិសេសៗនៅក្នុងក្រុម

ខ. ចំណាយសរុបផ្នែកបុគ្គលិកសម្រាប់សមាជិកក្រុម

គ. ចំណាយលើកម្មវិធីផ្សេងៗ

ឃ. ថ្លៃជួលអ្នកជំនាញ ចំណាយលើតុលាការ និងចំណាយស្រដៀងគ្នា

ង. ចំណាយលើការសហការជាមួយក្រុមអ្នកតំណាងរាស្ត្រ និងគណបក្សក្នុងសភាដទៃទៀត

ច. ចំណាយលើសកម្មភាពទំនាក់ទំនងសាធារណៈ

ឆ. ចំណាយលើសកម្មភាពធុរកិច្ចប្រចាំថ្ងៃ

ជ. ចំណាយលើការវិនិយោគ

ញ. ចំណាយផ្សេងៗ

**(៣)** គណនេយ្យ ត្រូវកំណត់អំពីទ្រព្យសកម្មដែលទទួលបានតាមរយៈការប្រើប្រាស់មូលនិធិនានា ដូចមានចែងក្នុងចំណុច ៥០(១) និងទឹកប្រាក់បម្រុងដែលបានមកពីមូលនិធិទាំងនេះ ក៏ដូចជាឥណទេយ្យ និងបំណុលផងដែរ។ របាយការណ៍ទ្រព្យសកម្ម និងបំណុល ត្រូវបង្ហាញជូនដូចខាងក្រោម៖

១. ទ្រព្យសកម្ម

ក. រូបិយវត្ថុ

ខ. ទ្រព្យសកម្មផ្សេងៗ

គ. ការបង្គរ និងការពន្យារពេលទូទាត់ប្រាក់

២. បំណុល

ក. ប្រាក់បម្រុង

ខ. សំវិធានធន
គ. បំណុលចំពោះស្ថាប័នហិរញ្ញវត្ថុ
ឃ. បំណុលផ្សេងៗ
ង. ការបង្គរ និង ការពន្យារពេលទូទាត់ប្រាក់

**(៤)** របាយការណ៍ត្រូវពិនិត្យដោយសវនករ (គណនេយ្យករដែលមានលិខិតបញ្ជាក់ទទួលស្គាល់ ឬក្រុមហ៊ុនគណនេយ្យដែលមានលិខិតបញ្ជាក់ទទួលស្គាល់) ដែលត្រូវបានជ្រើសរើសដោយការពិគ្រោះយោបល់ជាមួយនាយកដ្ឋានសវនកម្មសហព័ន្ធ ដើម្បីឲ្យប្រាកដថា ខ្លួនអនុវត្តតាមចំណុចរង (២) និង (៣) ខាងលើ និងត្រូវមានការបញ្ជាក់ពីសវនករ។ របាយការ-ណ៍ដែលត្រូវបានធ្វើសវនកម្មរួច ត្រូវដាក់ជូនទៅប្រធានសភាសហព័ន្ធអាល្លឺម៉ង់កុំឱ្យលើសពីរយៈពេលប្រាំមួយខែ បន្ទាប់ពីដំណាច់ឆ្នាំ ឬខែប្រតិទិន ដែលក្នុងនោះប្រាក់ឧបត្ថម្ភនានា ដូចមានចែងក្នុងចំណុច ៥០ (១) នៃច្បាប់នេះ គឺជាការទូទាត់ចុងក្រោយ។ ប្រធានសភា សហព័ន្ធអាល្លឺម៉ង់អាចពន្យារពេលផុតកំណត់រហូតដល់បីខែ សម្រាប់ហេតុផលពិសេសណាមួយ។ របាយការណ៍ដែលធ្វើសវនកម្មរួច នឹងត្រូវបោះពុម្ពចែកជូនជាឯកសារសម្រាប់សភាសហព័ន្ធ។

**(៥)** ប្រសិនបើ ក្រុមអ្នកតំណាងរាស្ត្រមិនបានដាក់ជូនរបាយការណ៍ទេនោះ ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ដែលត្រូវទូទាត់ ដូចមានចែងក្នុងចំណុច ៥០(១) នឹងមិនត្រូវប្រគល់ជូនឡើយ។

## ចំណុច ៥៣
## ការធ្វើសវនកម្មគណនី

**(១)** នាយកដ្ឋានសវនកម្មសហព័ន្ធ ត្រូវធ្វើសវនកម្មគណនេយ្យព្រមទាំងប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍នានា ដែលក្រុមតំណាងរាស្ត្រទទួលបាន ស្របតាមចំណុច ៥០(១) នៃច្បាប់នេះ ដើម្បីធានាថាប្រាក់ ឧបត្ថម្ភ និងអត្ថប្រយោជន៍នានា ត្រូវបានប្រើប្រាស់ដោយសន្សំសំចៃ និងត្រឹមត្រូវ

អនុលោមតាមបទប្បញ្ញត្តិប្រតិបត្តិ ដែលមានចែងក្នុង ចំណុច៥១ (១) ។

**(២)** អំឡុងពេលធ្វើសនវកម្ម ត្រូវពិចារណាឱ្យបានត្រឹមត្រូវចំពោះស្ថានភាពគតិយុត្តិ និងភារកិច្ចរបស់ក្រុមអ្នកតំណាងរាស្ត្រ។ ភាពចាំបាច់ពាក់ព័ន្ធនឹងវិធានការនយោបាយណាមួយ ដែលធ្វើឡើងដោយក្រុមនេះមិនត្រូវក្លាយជាកម្មវត្ថុនៃសវនកម្មឡើយ។

## ចំណុច ៥៨
## ការបញ្ចប់ស្ថានភាពគតិយុត្តិ និងការជម្រះបញ្ជី

**(១)** ស្ថានភាពគតិយុត្តិ ដូចមានចែងក្នុងផ្នែក៤៦ នៃច្បាប់នេះ ត្រូវអស់សុពលភាពសម្រាប់ការអនុវត្ត

១. នៅពេលបាត់បង់ឋានៈជាក្រុមអ្នកតំណាងរាស្ត្រ

២. នៅពេលរម្លាយក្រុមអ្នកតំណាងរាស្ត្រ

៣. នៅពេលបញ្ចប់អាណត្តិបោះឆ្នោត

**(២)** ត្រូវធ្វើការជម្រះបញ្ជី ក្នុងករណីដូចមានចែងក្នុងចំណុចរង (១)១. និង ២. ខាងលើ។ ក្រុមអ្នកតំណាងរាស្ត្រត្រូវចាត់ទុកថាមានអត្ថិភាព រហូតដល់បញ្ចប់ការជម្រះបញ្ជី ប្រសិនបើគោលបំណងនៃការជម្រះបញ្ជីនេះតម្រូវដូច្នោះ។ ការជម្រះបញ្ជី ត្រូវធ្វើឡើងដោយគណៈកម្មាធិការប្រតិបត្តិ បើពុំដូច្នោះទេ លុះត្រាតែមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមអ្នកតំណាងរាស្ត្រ។

**(៣)** អ្នកជម្រះបញ្ជីត្រូវបញ្ចប់ប្រតិបត្តិការធុរកិច្ចទាំងអស់ ដែលមិនទាន់បានបញ្ចប់ ទារបំណុលនិងទូទាត់សងឥណទាយក។ ក្នុងគោលបំណងនេះ អ្នកជម្រះបញ្ជីត្រូវមានសិទ្ធិអនុវត្តប្រតិបត្តិការថ្មីៗ និងបង្វែរទ្រព្យសកម្មទៅជាសាច់ប្រាក់។ ពួកគេត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងចំណុច៥០(៤) ទាក់ទងនឹងគោលបំណងនៃការប្រើប្រាស់អត្ថប្រយោ-ជន៍ទាំងនេះ។ អំឡុងដំណើរការជម្រះបញ្ជី ប្រសិនបើអ្នកជម្រះបញ្ជីត្រូវបានរកឃើញថា មានការធ្វេសប្រហែសមិនយកចិត្តទុកដាក់ពួក

គេត្រូវទទួលខុសត្រូវរួមគ្នាចំពោះឥណទាយក សម្រាប់ការខូចខាតដែលកើតឡើងទាំងអស់។

**(៤)** ប្រសិនបើប្រាក់ឧបត្ថម្ភដែលផ្តល់ឱ្យតាមចំណុច៥០(១) នៃច្បាប់នេះ នៅសេសសល់ បន្ទាប់ពីបញ្ចប់ការជម្រះបញ្ជី ប្រាក់ឧបត្ថម្ភទាំងនេះត្រូវបង់ចូលទៅក្នុងថវិកាសហព័ន្ធ។ ប្រការនេះត្រូវអនុវត្តផងដែរ ចំពោះទ្រព្យសកម្មដែលបានទិញដោយប្រើប្រាស់ប្រាក់ឧបត្ថម្ភទាំងនេះ។ អត្ថប្រយោជន៍ដែលផ្តល់ឱ្យ អនុលោមតាមចំណុច៥០(៣) ត្រូវប្រគល់ជូនអង្គភាពដែលផ្តល់ឱ្យវិញ។

**(៥)** ទ្រព្យសកម្មដែលនៅសេសសល់របស់ក្រុមអ្នកតំណាងរាស្ត្រ ត្រូវប្រគល់ជូនអ្នកទទួលផល។ អ្នកទទួលផល គឺជាបុគ្គល ឬអាជ្ញាធរ ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមអ្នកតំណាងរាស្ត្រ។

**(៦)** វិធានការតាមចំណុចរង (៤) និង (៥) ខាងលើ មិនអាចត្រូវបានអនុវត្តរហូតរយៈពេលប្រាំមួយខែ ចាប់ពីពេលបាត់បង់ស្ថានភាពគតិយុត្តិ ដូចមានចែងក្នុងចំណុច៤៦ នៃច្បាប់ជាធរមាន។ ការផ្តល់សន្តិសុខសម្រាប់អ្នកឥណទានយកត្រូវធ្វើឡើងដោយអនុលោមតាមចំណុច៥២ នៃក្រមរដ្ឋប្បវេណី។

**(៧)** ក្នុងករណីដូចមានចែងក្នុងចំណុចរង (១)៣. ខាងលើ ការជម្រះបញ្ជីមិនត្រូវកើតមានឡើងទេ ប្រសិនបើក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើមអាណត្តិបោះឆ្នោតថ្មី ក្រុមអ្នកតំណាងរាស្ត្រត្រូវបានបង្កើតឡើងដោយសមាជិករបស់ខ្លួនជាសមាជិករបស់គណបក្សមួយ ដែលតំណាងដោយ ក្រុមអ្នកតំណាងរាស្ត្រក្នុងសភាសហព័ន្ធអាល្លឺម៉ង់នៅអំឡុងពេលអាណត្តិបោះឆ្នោតលើកមុន និងប្រកាសថាខ្លួនថាជាសន្តតិជនរបស់ក្រុមអ្នកតំណាងរាស្ត្រអាណត្តិមុន។ ក្នុងករណីនេះ ក្រុមអ្នកតំណាងរាស្ត្រ ដែលទើបបង្កើតថ្មី ត្រូវក្លាយជាសន្តតិជននៃក្រុមអ្នកតំណាងរាស្ត្រអាណត្តិមុន។

# ឧបសម្ពន្ធ២៖ សម្រង់បទបញ្ជាផ្ទៃក្នុងរបស់សភាសហព័ន្ធអាល្លឺម៉ង់

## ៨. ក្រុមអ្នកតំណាងរាស្ត្រ

**វិធានទី ១០**

**ការបង្កើតក្រុមអ្នកតំណាងរាស្ត្រ**

**(១)** ក្រុមអ្នកតំណាងរាស្ត្រ ត្រូវតែជាក្រុមដែលមានសមាសភាពមិនតិចជាង ៥% នៃសមាជិកទាំងអស់របស់សភាសហព័ន្ធ ហើយសមាជិកទាំងនោះ ត្រូវមកពីគណបក្សនយោបាយតែមួយ ឬមកពីគណបក្សដែលមានគោលបំណងនយោបាយប្រហាក់ប្រហែលគ្នា ដែលមិនប្រជែងគ្នាក្នុងរដ្ឋណាមួយឡើយ។ នៅពេលដែលសមាជិកសភា សហព័ន្ធទាំងនោះចងក្រងជាក្រុមផ្អែកលើមូលដ្ឋានផ្សេង ដែលខុសពីប្រការដូចមានចែងនៅក្នុងប្រយោគដើមដំបូង នៃកថាខណ្ឌនេះ ត្រូវមានការអនុម័តយល់ព្រមពីសភាសហព័ន្ធ ដើម្បីទទួលស្គាល់ក្រុមតំណាងរាស្ត្របែបនេះ។

**(២)** ការបង្កើតក្រុមអ្នកតំណាងរាស្ត្រ អង្គការចាត់តាំងរបស់ខ្លួន និងឈ្មោះរបស់ប្រធាន សមាជិក និងភ្ញៀវរបស់ខ្លួនផ្សេងទៀត ត្រូវជូនដំណឹងទៅប្រធានជាលាយលក្ខណ៍អក្សរ។

**(៣)** ក្រុមអ្នកតំណាងរាស្ត្រអាចទទួលយកភ្ញៀវបាន ដែលចំនួនភ្ញៀវនោះ មិនត្រូវបានរាប់បញ្ចូលក្នុងចំនួនរបស់ក្រុមអ្នកតំណាងរាស្ត្រទេ ប៉ុន្តែចំនួននេះត្រូវរាប់បញ្ចូលក្នុងការបែងចែងមុខតំណែង (វិធាន១២)។

**(៤)** សមាជិកសភាសហព័ន្ធ ដែលមានបំណងចងក្រងជាសមាគម ក៏ប៉ុន្តែមិនអាចបំពេញទៅតាមចំនួនសមាជិកអប្បបរមា ដែលបានកំណត់ ដូចមានចែងនៅក្នុងលក្ខន្តិកៈនៃក្រុមអ្នកតំណាងរាស្ត្រ អាចត្រូវបានទទួលស្គាល់ត្រឹមតែជាក្រុមប៉ុណ្ណោះ។ កថាខណ្ឌ (២) និង (៣) ត្រូវអនុវត្តទៅលើសមាគមទាំងនេះបានដូចគ្នា។

(៥) ក្រុមការងារបច្ចេកទេសរួមរបស់គណបក្ស ដែលបង្កើតឡើងដោយក្រុមអ្នកតំណាងរាស្ត្រគ្មានឥទ្ធិពលដល់ចំនួននៃមុខតំណែងទេ ដែលចំនួនមុខតំណែងនេះ គឺត្រូវបែងចែកស្របទៅតាមចំនួនសមាជិករបស់ក្រុមអ្នកតំណាងរាស្ត្រនីមួយៗ។

## វិធានទី ១១
## លំដាប់របស់ក្រុមអ្នកតំណាងរាស្ត្រ

លំដាប់របស់ក្រុមអ្នកតំណាងរាស្ត្រ ត្រូវតែកំណត់ដោយផ្អែកលើចំនួនសមាជិករបស់ខ្លួន។ ក្នុងករណីដែលក្រុមមានទំហំស្មើគ្នា ប្រធានត្រូវកំណត់លំដាប់ ដោយការបោះឆ្នោតរើសកន្លែងអង្គុយក្នុងសភាសហព័ន្ធ។ ចំពោះអាសនៈដែលនៅទំនេររហូតទាល់តែអាសនៈនោះត្រូវបានបំពេញត្រូវ បន្តចាត់ចែងដោយគិតលើចំនួនសមាជិកនៃក្រុមអ្នកតំណាងរាស្ត្រ ដែលក្រុមនីមួយមានរហូតដល់ដឹងថាអាសនៈទាំងនោះ ជារបស់អ្នកណា។

## វិធានទី ១២
## ការបែងចែកមុខតំណែងក្នុងចំណោមក្រុមអ្នកតំណាងរាស្ត្រ

សមាសភាពរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់ចាស់ទុំ និងគណៈកម្មាធិការ ក៏ដូចជាការតែងតាំងប្រធាននៃគណៈកម្មាធិការផ្សេងៗគ្នា ត្រូវធ្វើឡើង ដោយស្របទៅតាមសមាមាត្រ នៃចំនួនសមាជិករបស់ក្រុមអ្នកតំណាងរាស្ត្រ។ គោលការណ៍ដូចគ្នានេះ ត្រូវអនុវត្តចំពោះការបោះឆ្នោតនានា ដែលអនុវត្តដោយសភាសហព័ន្ធ។

ឧបសម្ពន្ធ៣៖ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមអ្នកតំណាងរាស្ត្រ CDU/CSU ក្នុងសភាសហព័ន្ធអាល្លឺម៉ង់

បទបញ្ជាផ្ទៃក្នុង
របស់ក្រុមអ្នកតំណាងរាស្ត្រ **CDU / CSU**
ក្នុងសភាសហព័ន្ធអាល្លឺម៉ង់ នីតិកាលទី ១៧
ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១០

# មាតិកា

ទ១ សមាជិកភាព ..... ៥៩
ទ២ រចនាសម្ព័ន្ធ និងក្រុម ..... ៥៩
ទ៣ កិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ ..... ៦០
ទ៤ ភារកិច្ចនៃកិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ ..... ៦១
ទ៥ គណៈកម្មាការប្រតិបត្តិ ..... ៦២
ទ៦ ក្រុមប្រឹក្សាភិបាល ..... ៦៣
ទ៧ ប្រធាន ..... ៦៤
ទ៨ ក្រុមការងារ ..... ៦៤
ទ៩ ក្រុមប្រឹក្សាកិត្តិយស ..... ៦៥
ទ១០ គណៈកម្មាការហិរញ្ញវត្ថុ និងគណៈកម្មាការត្រួតពិនិត្យថវិកា ..... ៦៦

ទ១១ វិភាគទានក្រុមអ្នកតំណាងរាស្ត្រ ........ ៦៧
ទ១២ ការធ្វើសេចក្តីសម្រេច មតិភាគច្រើន ........ ៦៧
ទ១៣ ការបោះឆ្នោត ........ ៦៧
ទ១៤ ការដកសេចក្តីទុកចិត្ត ........ ៦៩
ទ១៥ ការបណ្តេញចេញ ........ ៦៩
ទ១៦ ការបោះឆ្នោតផ្សេងៗ ........ ៧០
ទ១៧ ការបោះឆ្នោតក្នុងសភាសហព័ន្ធអាល្លឺម៉ង់ ........ ៧០
ទ១៨ កាតព្វកិច្ចរបស់សមាជិក ........ ៧១
ទ១៩ ទំនាក់ទំនងជាមួយអង្គភាព និងសភារបស់រដ្ឋសហព័ន្ធ ........ ៧២
ទ២០ ច្រកចេញចូលរបស់ឯកសារ ........ ៧២
ឧបសម្ពន្ធ ........ ៧៣

អ្នកតំណាងរាស្ត្រនៃគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត (CDU) និងគណបក្សសហព័ន្ធសង្គមគ្រីស្ត (CSU) ក្នុងសភាសហព័ន្ធអាល្លឺម៉ង់ បានព្រមព្រៀងគ្នាបន្តសម្ព័ន្ធភាពរវាងគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត និងគណបក្សសហព័ន្ធសង្គមគ្រីស្ត សំរាប់នីតិកាល ទី១៧ កាលពីថ្ងៃទី ២៩ កញ្ញា ឆ្នាំ២០០៩។ តាមរយៈកិច្ចព្រមព្រៀងនេះ គេបានអនុម័តបទបញ្ជាផ្ទៃក្នុង សំរាប់កុម្រអ្នកតំណាងរាស្ត្រមកពីគណបក្សទាំងពីរ ដូចខាងក្រោម៖

### ទ១ សមាជិកភាព

(១) ក្រុមអ្នកតំណាងរាស្ត្រ នៃគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត/ គណបក្សសហព័ន្ធសង្គមគ្រីស្ត បានកើតឡើងដោយអ្នកតំណាងរាស្ត្ររបស់គណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត និងគណបក្សសហព័ន្ធសង្គមគ្រីស្តក៏ដូចជាអ្នកជំនាញទាំងឡាយ។ការសម្រេចទទួលយកអ្នកជំនាញត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ។ ការសម្រេចទទួលយកនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ៣ថ្ងៃបន្ទាប់ពីការដាក់ពាក្យស្នើសុំ។

(២) សមាជិកទាំងអស់មានសិទ្ធិ និងកាតព្វកិច្ចស្មើៗគ្នា។

### ទ២ រចនាសម្ព័ន្ធ និងក្រុម

(១) រចនាសម្ព័ន្ធរបស់ក្រុមអ្នកតំណាងរាស្ត្រគឺ៖

ក. កិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ

ខ. គណៈកម្មាការប្រតិបត្តិ

គ. ក្រុមប្រឹក្សាភិបាល

ឃ. ក្រុមការងារ

ង. ក្រុមប្រឹក្សាកិត្តិយស

ច. គណៈកម្មាការហិរញ្ញវត្ថុ

ឆ. គណៈកម្មាការត្រួតពិនិត្យហិរញ្ញវត្ថុ

**(២)** ក្រុមតូចៗដទៃទៀតរបស់ក្រុមអ្នកតំណាងរាស្ត្រមាន៖
ក. ក្រុមស្ត្រី
ខ. ក្រុមនិយោជិត
គ. ក្រុមសភាទទួលបន្ទុកអ្នកមានជីវភាពមធ្យម
ឃ. ក្រុមជនភាសិក, អ្នកចំណូលថ្មី និងជនជាតិដើមភាគតិច អាល្លឺម៉ង់
ង. ក្រុមសហគមនយោបាយមូលដ្ឋាន
ច. ក្រុមយុវជន។

**(៣)** ក្រុមបឹក្សាភិបាល អាចប្រើប្រាស់គណៈកម្មាការផ្សេងៗបន្ថែមទៀត សម្រាប់ការងារដែលមានរយៈពេលកំណត់ជាក់លាក់មួយ ហើយលទ្ធផលការងាររបស់គណៈកម្មាការនេះ ត្រូវបង្ហាញដល់ក្រុមអ្នកតំណាងរាស្ត្រ។

## ទ៣ កិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ

**(១)** កិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ ធ្វើឡើងយ៉ាងហោចណាស់ម្តង ក្នុងមួយសប្តាហ៍ ប្រជុំតាមរយៈការកោះអញ្ជើញរបស់ប្រធាន ជាពិសេសដើម្បីពិភាក្សាអំពី បញ្ហានយោបាយមុនពេលធ្វើការអនុម័ត ក្នុងសភាសហព័ន្ធអាល្លឺម៉ង់។
តាមសំណើរមួយភាគបីនៃសមាជិក ឬតាមការទាមទាររបស់ក្រុមការងារមួយក្នុងអំឡុងពេលសប្តាហ៍ប្រជុំ ប្រធានត្រូវកោះប្រជុំវិសាមញ្ញក្រុមអ្នកតំណាងរាស្ត្រមួយ។

**(២)** ប្រធានអាចអញ្ជើញភ្ញៀវឲ្យចូលរួមក្នុងកិច្ចប្រជុំ របស់ក្រុមអ្នកតំណាងរាស្ត្របាន។ ភ្ញៀវទាំងនោះ អាចជាសមាជិកគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រឹស្ត និងគណបក្សសហព័ន្ធសង្គមគ្រឹស្ត សមាជិករដ្ឋាភិបាល រដ្ឋលេខាធិការ សមាជិកក្រុមប្រឹក្សាសហព័ន្ធ ប្រធានក្រុមអ្នកតំណាងរាស្ត្រនៃសភារដ្ឋសហព័ន្ធ ថ្នាក់ដឹកនាំគណបក្ស និងអគ្គលេខាធិការបក្សសហព័ន្ធប្រជាធិបតេយ្យគ្រឹស្ត និងគណបក្សសហព័ន្ធសង្គមគ្រឹស្ត សមា

ជិកនៃក្រុមអ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាជនអឺរ៉ុប (អ្នកប្រជាធិបតេយ្យប្រកាន់គ្រីស្ត) ក្នុងសភាអឺរ៉ុប ក៏ដូចជាអតីតសមាជិកក្រុមអ្នកតំណាងរាស្ត្រទាំងអស់។

ការអនុញ្ញាតឲ្យមន្ត្រីរួមការងាររបស់បក្ស ដែលបំរើការងារក្នុងរដ្ឋាភិបាលសហព័ន្ធ និងក្នុងរដ្ឋាភិបាលរដ្ឋសហព័ន្ធ ឲ្យចូលរួមកិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ ជាការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

**(៣)** របៀបវារៈនៃកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ និងអនុសាសន៍ក្នុងការអនុម័តរបស់ប្រធាន និងរបស់ក្រុមការងារ ត្រូវដាក់ជូនកិច្ចប្រជុំជាលាយលក្ខណ៍អក្សរជាមុន។

តាមរយៈសម្លេងគាំទ្រលើសពីពាក់កណ្តាល នៃចំនួនសមាជិកដែលមានវត្តមាន គេអាចបន្ថែមរបៀបវារៈក្នុងកិច្ចប្រជុំបាន បើការនេះមិនមានជំទាស់ដោយបទបញ្ញាផ្ទៃក្នុងនេះទេ។

រាល់កិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ គេត្រូវធ្វើកំណត់ត្រាហើយសមាជិកទាំងអស់អាចមើលកំណត់ត្រានេះបានគ្រប់ពេលវេលា។

## ទ៤ ភារកិច្ចនៃកិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ

**(១)** កិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ ជាអ្នកសម្រេចនយោបាយរបស់គណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត និងគណបក្សសហព័ន្ធសង្គមគ្រីស្ត នៅក្នុងសភាសហព័ន្ធអាល្លឺម៉ង់។

ក. ពិភាក្សាអំពីចំណុចទាំងឡាយនៃរបៀបវារៈ នៃកិច្ចប្រជុំពេញអង្គរបស់សភាសហព័ន្ធ និងកំណត់នូវចំណាប់អារម្មណ៍របស់ក្រុមអ្នកតំណាងរាស្ត្រ។

ខ. អនុម័តនូវចំនួននិងដែនសមត្ថកិច្ចរបស់អនុប្រធានក្រុមអ្នកតំណាងរាស្ត្រ និងក្រុមការងារ ក៏ដូចជាចំនួននៃអ្នកដឹកនាំការងារសភា។

គ. អនុម័តនូវវិធានការរបស់ក្រុមប្រឹក្សាភិបាល។

**(២)** កិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ បោះឆ្នោតជ្រើសរើស៖

ក. ប្រធាន
ខ. ប្រធានក្រុមការងារ (អ្នកនាំពាក្យ) និងអនុប្រធានរបស់គេ (អ្នកសម្របសម្រួល)
គ. សមាជិកក្រុមអ្នកតំណាងរាស្ត្រនៅក្នុងក្រុមប្រឹក្សាចាស់ទុំ
ឃ. ក្រុមប្រឹក្សាកិត្តិយស
ង. គណៈកម្មាការហិរញ្ញវត្ថុ និង
ច. គណៈកម្មាការត្រួតពិនិត្យហិរញ្ញវត្ថុ។

(៣) កិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រតែងតាំង៖
ក. បេក្ខជនដែលត្រូវបានស្នើឡើង ដោយក្រុមអ្នកតំណាងរាស្ត្រសំរាប់ឈរឈ្មោះជាថ្នាក់ដឹកនាំសភាសហព័ន្ធអាល្លឺម៉ង់ និងសម្រាប់ការងារជាប្រធាន ឬជាអនុប្រធានគណៈកម្មាការជំនាញ ឬគណៈកម្មាការរបស់សភាសហព័ន្ធអាល្លឺម៉ង់
ខ. សមាជិកនៃក្រុមអ្នកតំណាងរាស្ត្រ សំរាប់ការងារក្រៅសភាសហព័ន្ធអាល្លឺម៉ង់ ប្រសិនបើគេត្រូវបានអនុម័តដោយសភាពេញអង្គ។

(៤) រាល់ពេលប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ ប្រធាន ឬអនុប្រធានណាមួយ ត្រូវរាយការណ៍ជូនអង្គប្រជុំ អំពីសកម្មភាពការងាររបស់ក្រុមប្រឹក្សាភិបាល។ តាមរយៈការទាមទាររបស់អង្គប្រជុំក្រុមអ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សាភិបាល ឬរបស់ក្រុមការងារណាមួយ ក៏ដូចជាក្រុមការងារទាំងឡាយឯទៀត ក៏ត្រូវរាយការណ៍អំពីការងាររបស់ខ្លួន តាមរយៈប្រធានក្រុមការងារ (អ្នកនាំពាក្យ) ឬដោយតំណាងម្នាក់ដែលត្រូវបានតែងតាំង។

## ទ៩ គណៈកម្មាការប្រតិបត្តិ

(១) គណៈកម្មាការប្រតិបត្តិកើតឡើងដោយប្រធាន និងអនុប្រធានរបស់ខ្លួន ថ្នាក់ដឹកនាំកិច្ចការសភា អ្នកច្បាប់ និងអ្នកនាំពាក្យនៃក្រុមសភានៃគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត របស់រដ្ឋសហព័ន្ធទាំងអស់។ ប្រធាន

អាចមានសិទ្ធិ អញ្ជើញភ្ញៀវឲ្យចូលរួមកិច្ចពិភាក្សា។

**(២)** គណៈកម្មាការប្រតិបត្តិ រៀបចំកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ គណៈកម្មការនេះជាអ្នកធានានូវការប្រព្រឹត្តទៅនៃក្រុមអ្នកតំណាងរាស្ត្រ។

## ៩៦ ក្រុមប្រឹក្សានិប្បាល

**(១)** ក្រុមប្រឹក្សាភិបាលកើតឡើងដោយ គណៈកម្មាការប្រតិបត្តិតាមមាត្រា ៩៥ ចំណុច១ ប្រធានក្រុមការងារទាំងអស់ (អ្នកនាំពាក្យ) ប្រធានក្រុមការងារផ្សេងៗ និងសមាជិក ១៥រូបទៀត (សមាជិកមិនអចិន្ត្រៃយ៍)។

**(២)** ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អ្នកដែលមានសិទ្ធិចូលរួមប្រជុំ មានប្រធានគណបក្ស និងអគ្គលេខាធិការរបស់គណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត និងគណបក្សសហព័ន្ធសង្គមគ្រីស្ត ប្រធានសាខាបក្សសភាគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត នៃរដ្ឋសហព័ន្ធទាំងអស់ ក៏ដូចជាសមាជិក សមាជិការបស់គណបក្ស សហព័ន្ធប្រជាធិបតេយ្យគ្រីស្ត និងគណបក្សសហព័ន្ធសង្គមគ្រីស្ត សមាជិកនៃការិយាល័យថ្នាក់ដឹកនាំសហព័ន្ធ និងសមាជិកនៃការិយាល័យថ្នាក់ដឹកនាំសភាអឺរ៉ុប និងសមាជិកនៃថ្នាក់ដឹកនាំរដ្ឋាភិបាលសហព័ន្ធ អតីតអធិកាបតី ប្រធានក្រុមអ្នកតំណាងរាស្ត្រនៃបក្សប្រជាជនអឺរ៉ុប (អ្នកប្រជាធិបតេយ្យប្រកាន់គ្រីស្ត) ក្នុងសភាអឺរ៉ុប និងប្រធានក្រុម នៃក្រុមតំណាងរាស្ត្រគណបក្សសហព័ន្ធប្រជាធបិតេយ្យគ្រីស្ត និងគណបក្សសហព័ន្ធសង្គមគ្រីស្ត។ ប្រធានអាចមានសិទ្ធិអញ្ជើញភ្ញៀវឲ្យចូលរួមផ្តល់ជាយោបល់។

**(៣)** ក្រុមប្រឹក្សាភិបាលជាអ្នកដឹកនាំការប្រព្រឹត្តទៅ នៃក្រុមអ្នកតំណាងរាស្ត្រដើម្បីឲ្យការឆ្លើយតបនឹងសេចក្តីសម្រេចនៃកិច្ចប្រជុំរបស់ក្រុមអ្នកតំណាងរាស្ត្រ។ គេពិភាក្សារាល់កិច្ចការទាំងអស់ របស់កិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ និងក្នុងក្រុមការងារដែលបានដាក់ស្នើមក។

ទ៧ ប្រធាន

(១) ប្រធានជាអ្នកដឹកនាំក្រុមអ្នកតំណាងរាស្ត្រ ហើយជាតំណាងក្រុមរបស់គេ ទាំងផ្ទៃក្នុង និងទៅខាងក្រៅ។ ប្រធានជាអ្នកកោះអញ្ជើញ កិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ហើយផ្តល់អនុសាសន៍ក្នុងការដាក់របៀបវារៈប្រជុំ។ ប្រធានជាអ្នកដឹកនាំក្រុមអ្នកតំណាងរាស្ត្រ ក្នុងកិច្ចប្រជុំពេញអង្គនៃសភាសហព័ន្ធអាល្លឺម៉ង់។

(២) ប្រធានអាចតែងតាំងសមាជិកម្នាក់ ដែលមានការជឿទុកចិត្តជាពិសេស (បេសកជន)។ គាត់ត្រូវបង្ហាញរាល់កិច្ចការទាំងនេះ ដល់កិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ។

(៣) ប្រធានអាចផ្តល់សិទ្ធិឲ្យថ្នាក់ដឹកនាំកិច្ចការសភា ក្នុងការដកហូត និងតែងតាំងមន្ត្រីបំរើការក្នុងក្រុមអ្នកតំណាងរាស្ត្រ ក៏ដូចជាការពិនិត្យមើលនូវដំណើរការហិរញ្ញវត្ថុរបស់ក្រុម។

(៤) ក្នុងករណីប្រធាន និងអនុប្រធានទី១ មានធុរៈរយៈពេលយូរកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រអាចតែងតាំងប្រធានស្តីទីមួយរូប តាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល ដើម្បីទទួលភារកិច្ចជំនួសប្រធាន។

ទ៨ ក្រុមការងារ

(១) សមាជិកនៃក្រុមការងារ គឺជាសមាជិក និងជាសមាជិកតំណាងឲ្យគណៈកម្មាការជំនាញនៃសភាសហព័ន្ធអាល្លឺម៉ង់ ហើយក្រុមការងារ គឺជាអ្នកទទួលខុសត្រូវលើការងាររបស់គណៈកម្មាការជំនាញ របស់គេ។ លើសពីនេះទៅទៀត គ្រប់សមាជិកនៃក្រុមអ្នកតំណាងរាស្ត្រ អាចដាក់ពាក្យសុំចូលជាសមាជិកនៃក្រុមការងារជំនាញបាន។ ការអនុញ្ញាតឲ្យចូលជាសមាជិកក្រុមការងារនេះ ត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល។ ចំពោះក្រុមការងារណា ដែលជំនាញរបស់គេមិនត្រូវនឹងការងាររបស់គណៈកម្មាការជំនាញទេ ពេលនោះក្រុមប្រឹក្សាភិបាលធ្វើការសម្រេច ដោយផ្អែកលើទំហំ និងសមាជិកភាព។ សមាជិកក្រុមអ្នកតំណាងរាស្ត្រទាំង

អស់ មានសិទ្ធិចូលរួមបញ្ចេញមតិ ក្នុងរាល់កិច្ចប្រជុំក្រុមការងារ។

(២) អ្នកដែលត្រូវបានបោះឆ្នោតជ្រើសរើសជាប្រធានក្រុមការងារ ក្នុងពេលប្រជុំក្រុមអ្នកតំណាងរាស្ត្រ ជាអ្នកដឹកនាំក្រុមការងារ។ គាត់ទទួលខុសត្រូវជាអ្នកនាំពាក្យរបស់ក្រុមអ្នកតំណាងរាស្ត្រ សម្រាប់ដែនសមត្ថកិច្ចរបស់ក្រុមកាងារ និងការងារសមាជិកក្រុមអ្នកតំណាងរាស្ត្រ នៅក្នុងគណៈកម្មាការជំនាញរបស់គាត់។ ប្រសិនបើសមាជិកណាម្នាក់ក្នុងក្រុមចង់ធ្វើសេចក្តីបំភ្លឺដល់ក្រុមអ្នកតំណាងរាស្ត្រ នោះគេត្រូវសុំការយល់ព្រមពីប្រធានក្រុម (អ្នកនាំពាក្យ) ដែលជាអ្នកទទួលខុសត្រូវជាមុនសិន។

(៣) អ្នកសម្របសម្រួល នៃក្រុមអ្នកតំណាងរាស្ត្រក្នុងគណៈកម្មាការជំនាញរបស់សភាសហព័ន្ធអាល្លឺម៉ង់ គឺជាអនុប្រធានរបស់ប្រធាន ក្រុមការងារជាអ្នកទទួលខុសត្រូវសម្រាប់ការងាររបស់គាត់។

(៤) ក្រុមការងារ ពិភាក្សាអំពីគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ និងឯកសារទាំងឡាយណាដែលក្រុមប្រឹក្សាភិបាលបញ្ជូនឲ្យ។ ក្រុមការងារជាអ្នកស្នើបេក្ខជនដែលត្រូវធ្វើបទអន្តរាគម ក្នុងនាមក្រុមអ្នកតំណាងរាស្ត្ររបស់ខ្លួន ឲ្យមានយោបល់ក្នុងកិច្ចប្រជុំពេញអង្គនៃសភាសហព័ន្ធ។

(៥) របៀបវារៈប្រជុំរបស់ក្រុមការងារទាំងឡាយ ត្រូវផ្ញើរជូនគ្រប់សមាជិកនៃក្រុមអ្នកតំណាងរាស្ត្រ។ រាល់កិច្ចប្រជុំ ត្រូវធ្វើកំណត់ត្រាខ្លីមួយ ហើយត្រូវផ្ញើរជូនគ្រប់សមាជិកក្រុមប្រឹក្សាភិបាល។

(៦) សមាជិកនៃក្រុមការងារទាំងអស់មានកាតព្វកិច្ច ជំរាបមកប្រធានក្រុម ឬអ្នកទទួលខុសត្រូវនៃក្រុមរបស់ខ្លួន ជាលាយលក្ខណ៍អក្សរឲ្យបានទាន់ពេលវេលា ប្រសិនបើខ្លួនមានធុរៈមិនអាចចូលរួមប្រជុំក្រុមការងារ ឬកិច្ចប្រជុំគណៈកម្មាការជំនាញបាន ដើម្បីរកអ្នកជំនួស។

## ៩ ក្រុមប្រឹក្សាកិត្តិយស

ក្រុមប្រឹក្សាកិត្តិយស មានសមាជិកបីរូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ ការងាររបស់គេត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

សមាជិកមួយរូបត្រូវមានឋានៈជាក្រុមប្រឹក្សាថៅក្រម។

## ទ១០ គណៈកម្មាការហិរញ្ញវត្ថុ និងគណៈកម្មាការត្រួតពិនិត្យថវិកា

(១) គណៈកម្មាការហិរញ្ញវត្ថុ កើតឡើងដោយសមាជិកបួនរូប ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយកិច្ចប្រជុំនៃក្រុមអ្នកតំណាងរាស្ត្ររួម និងអ្នកសរសេររបាយការណ៍ស្តីពីផែនការថវិការបស់ក្រុមបក្ស ក្នុងគណៈកម្មាការថវិកាជាតិនៃសភាសហព័ន្ធអាល្លឺម៉ង់។ ភាគច្រើននៃសមាជិកគណៈកម្មាការហិរញ្ញវត្ថុ មិនអាចជាសមាជិកនៃក្រុមប្រឹក្សាភិបាលទេ។
ជារៀងរាល់ឆ្នាំដល់ថ្ងៃទី១៥ ខែកុម្ភៈ គណៈកម្មាការហិរញ្ញវត្ថុ ធ្វើសេចក្តីព្រាងផែនការថវិកាបណ្តោះអាសន្ន របស់ក្រុមអ្នកតំណាងរាស្ត្រមួយបន្ទាប់មក យ៉ាងយូរបំផុតនៅ ៦ សប្តាហ៍ក្រោយនៃការអនុម័តថវិកាជាតិរបស់សភាសហព័ន្ធរួចហើយ ផែនការថវិកាស្ថាពរ និងផែនការសកម្មភាពនេះ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល និងកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រដើម្បីធ្វើការអនុម័ត។ ការអនុវត្តផែនការថវិកា ជាសមត្ថកិច្ចរបស់អ្នកដឹកនាំកិច្ចការសភា ដែលទទួលបានការតែងតាំងពីប្រធាន។

(២) គណៈកម្មាការត្រួតពិនិត្យថវិកាមានសមាជិកបីរូប ដែលត្រូវបានជ្រើសរើសដោយកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ ហើយដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ឬជាសមាជិកគណៈកម្មាការហិរញ្ញវត្ថុ។ មុនពេលកិច្ចប្រជុំធ្វើសេចក្តីសម្រេច គណៈកម្មាការនេះ ដាក់បង្ហាញជូនកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ នូវផែនការថវិការបស់ក្រុមអ្នកតំណាងរាស្ត្រសម្រាប់ឆ្នាំបន្ទាប់ របាយការណ៍ស្តីពីការអនុវត្តថវិកា ដែលបានបញ្ចប់ និងលទ្ធផលត្រួតពិនិត្យហិរញ្ញវត្ថុ។ គណៈកម្មាការនេះ ផ្តល់អនុសាសន៍ស្តីពីការជួយរកគោលនយោបាយតាមមាត្រាទ៤ ចំណុច១គ។

(៣) តាមសំណូមពរ រាល់សមាជិកនៃក្រុមអ្នកតំណាងរាស្ត្រ អាចពិនិត្យមើលនូវរាល់ចំណុចទាំងអស់នៃកញ្ចប់ថវិកា ទាំងកញ្ចប់ថវិកាពីអតីតកាល និងកញ្ចប់ថវិកាកំពុងដំណើរការបច្ចុប្បន្ន។

## ទ១១ វិភាគទានក្រុមអ្នកតំណាងរាស្ត្រ

(១) កិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ អាចអនុម័តដោយសម្លេងភាគច្រើន នូវវិភាគទានក្រុមអ្នកតំណាងរាស្ត្រ។

(២) ថវិកាដែលបានមកពីវិភាគទាន ត្រូវប្រើប្រាស់ជាជំនួយ ក្នុងករណីចាំបាច់ និងករណីពិសេសផ្សេងៗ។ ការប្រើប្រាស់ថវិកានេះ ត្រូវសម្រេចរួមគ្នា ដោយប្រធានក្រុមអ្នកតំណាងរាស្ត្រ ប្រធានទី១ របស់អ្នកដឹកនាំកិច្ចការសភា និងអ្នកដែលទទួលបានការតែងតាំងឲ្យដឹកនាំកិច្ចការសភា តាមមាត្រាទី៧ ចំណុច៣ ក្នុងការបំពេញការងារជាមួយថវិការួមគ្នា។

(៣) ការត្រួតពិនិត្យលើទ្រព្យសម្បត្តិពិសេស នៃវិភាគទានក្រុមអ្នកតំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់ប្រធានគណៈកម្មាការត្រួតពិនិត្យថវិកា និងប្រធានគណៈកម្មាការហិរញ្ញវត្ថុ។ គេមានសិទ្ធិយោងតាមមាត្រាទ១០ ចំណុច៣ ហើយគាត់ជាអ្នកផ្តល់អនុសាសន៍រួមគ្នា ក្នុងការជួយរកគោលនយោបាយតាមមាត្រាទ៤ ចំណុច១គ។

## ទ១២ ការធ្វើសេចក្តីសម្រេច មតិភាគច្រើន

(១) កិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ និងរចនាសម្ព័ន្ធរបស់ក្រុមអ្នកតំណាងរាស្ត្រ ដែលតម្រូវឲ្យមានការចូលរួមពីគ្រប់សមាជិករបស់សភាសហព័ន្ធអាល្លឺម៉ង់ទាំងអស់ ក្នុងករណីដែលអាចធ្វើសេចក្តីសម្រេចបាន លុះត្រាតែអ្នកទាំងនោះ បានទទួលការកោះអញ្ជើញយ៉ាងតិចណាស់៣ថ្ងៃមុន។

(២) បើគ្មានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះទេ ការអនុម័តត្រូវធ្វើឡើងដោយសម្លេងភាគច្រើន។ ក្នុងករណីសម្លេងស្មើគ្នា នោះបានន័យថាសំណើមិនត្រូវបានទទួលយកទេ។

(៣) សម្លេងអនុបវាទ មិនត្រូវបានរាប់បញ្ចូលឡើយ។

## ទ១៣ ការបោះឆ្នោត

(១) ដើម្បីធ្វើការបោះឆ្នោត គេត្រូវធ្វើការជូនដំណឹងមុនយ៉ាងហោចណាស់

៣ថ្ងៃមុន។

**(២)** ការបោះឆ្នោតជាការសម្ងាត់។

**(៣)** សម្រាប់ការបោះឆ្នោតជ្រើសរើសអនុប្រធាន (អ្នកសម្របសម្រួល) តាមមាត្រា៩៤ ចំណុច២ខ អ្នកដែលមានសិទ្ធិចង្អុលបង្ហាញបេក្ខជន គឺក្រុមប្រឹក្សាភិបាល និងសមាជិកពេញសិទ្ធិ និងសមាជិកជាតំណាងនៃគណៈកម្មាការជំនាញនោះផ្ទាល់តែម្តង។

**(៤)** ក្នុងករណីមានបេក្ខជនច្រើន ឈរឈ្មោះដើម្បីតំណែងមួយនោះ តម្រូវឲ្យធ្វើការបោះឆ្នោតពិសេសមួយ អ្នកដែលទទួលសម្លេងលើសពីពាក់កណ្តាលនៃសម្លេងឆ្នោត (សម្លេងភាគច្រើនដាច់ខាត) ត្រូវបានជ្រើសរើស។

ក្នុងករណីមិនទទួលបានសម្លេងភាគច្រើនដាច់ខាត នោះតម្រូវឲ្យធ្វើការបោះឆ្នោតជុំទី២។ បើការបោះឆ្នោតជុំទី២ មិនទទួលបានសម្លេងភាគច្រើនដាច់ខាត នោះតម្រូវឲ្យធ្វើការបោះឆ្នោតជុំទី៣ ហើយក្នុងពេលនេះគេអាចជ្រើសរើសយកបេក្ខជនថ្មីបន្ថែមទៀតបាន។ បើការបោះឆ្នោតជុំទី៣នេះ មិនទទួលបានសម្លេងភាគច្រើនដាច់ខាត នោះតម្រូវឲ្យធ្វើការបោះឆ្នោតឆ្លោះជាគំរូ រវាងបេក្ខជនពីររូប ដែលមានសម្លេងគាំទ្រលើសគេ។

**(៥)** ក្នុងករណីតំណែងមួយៗ មានបេក្ខជនតែមួយរូបឈរឈ្មោះ នោះគេអាចធ្វើការបោះឆ្នោតផ្តល់តំណែងទាំងនោះព្រមគ្នាបាន។ បេក្ខជនដែលទទួលបានសម្លេងគាំទ្រលើសពីពាក់កណ្តាល ត្រូវបានជ្រើសរើស។ ចំពោះបេក្ខជនណា ដែលមិនទទួលបានសម្លេងគាំទ្រភាគច្រើនដាច់ខាត បេក្ខជននោះត្រូវធ្វើការបោះឆ្នោតជុំទីពីរ បើជុំទីពីរមិនទទួលបានសម្លេងភាគច្រើនដាច់ខាតទៀត គេត្រូវធ្វើការបោះឆ្នោតជុំទីបី ហើយក្នុងពេលនេះគេអាចលើកយកបេក្ខជនថ្មីបន្ថែមបាន ហើយបេក្ខជនណាដែលទទួលបានសម្លេងគាំទ្រច្រើនជាង ត្រូវបានជ្រើសរើស។

**(៦)** បើមិនពាក់ព័ន្ធនឹងលក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងមាត្រា៩៤

ចំណុច៤ ឬ ៥ ទេ ការបោះឆ្នោតតាមមាត្រាទ៤ ចំណុច២គ ឃ ង ច និង ទ៨ចំណុច៣ខ ត្រូវប្រព្រឹត្តទៅដូចខាងក្រោម៖

បេក្ខជនដែលត្រូវបានជ្រើសរើស គឺជាបេក្ខជនទាំងឡាយណាដែលទទួលបានសម្លេងគាំទ្រភាគច្រើនដាច់ខាត ក្នុងការបោះឆ្នោតជុំទី១។ ក្នុងករណីមានបេក្ខជនចំនួនតិចតួច ទទួលបានសម្លេងគាំទ្រភាគច្រើនដាច់ខាត ដែលជាលក្ខខណ្ឌដើម្បីទទួលបានអាសនៈ នោះតម្រូវឲ្យធ្វើការបោះឆ្នោតជុំទី២។ បេក្ខជនដែលទទួលបាន សម្លេងគាំទ្រភាគច្រើនដាច់ខាត លើសម្លេងឆ្នោតបានការត្រូវបានជ្រើសរើស។ ក្នុងការបោះឆ្នោតជុំទី៣ គេអាចលើកយកបេក្ខជនថ្មីបន្ថែមទៀតបាន បេក្ខជនណាដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ ត្រូវបានជ្រើសរើស។

## ទ១៨ ការដកសេចក្តីទុកចិត្ត

កិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ អាចធ្វើការបោះឆ្នោតដោយសម្ងាត់ ដើម្បីអនុម័តដកសេចក្តីទុកចិត្ត លើសមាជិកក្រុមប្រឹក្សាភិបាល និងអ្នកសម្របសម្រួលបាន។ ពាក្យស្នើសុំដកសេចក្តីទុកចិត្ត ត្រូវផ្ញើរជូនដល់គ្រប់សមាជិកនៃក្រុមអ្នកតំណាងរាស្ត្រទាំងអស់ ជាលាយលក្ខណ៍អក្សរឲ្យបានមុនបីថ្ងៃ។ ការអនុម័តនេះ តម្រូវឲ្យមានសម្លេងគាំទ្រពីរភាគបីនៃសម្លេងឆ្នោតបានការ ហើយតម្រូវឲ្យមានការចូលរួមយ៉ាងហោចណាស់ពាក់កណ្តាល នៃសមាជិកនៃក្រុមអ្នកតំណាងរាស្ត្រ។

## ទ១៩ ការបណ្តេញចេញ

កិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ អាចធ្វើការបោះឆ្នោតដោយសម្ងាត់ ដើម្បីបណ្តេញសមាជិកនៃក្រុមអ្នកតំណាងរាស្ត្រចេញពីក្រុម។ ពាក្យស្នើសុំបណ្តេញសមាជិកចេញពីក្រុមនេះ ត្រូវផ្ញើរជូនគ្រប់សមាជិកនៃក្រុមអ្នកតំណាងរាស្ត្រទាំងអស់ ជាលាយលក្ខណ៍អក្សរឲ្យបានមុនបីថ្ងៃ។ ការអនុម័តតម្រូវឲ្យមានសម្លេងគាំទ្រពីរភាគបី នៃចំនួនសមាជិកក្រុមអ្នកតំណាង

រាស្រ្តសរុប។

ទ១៦ ការបោះឆ្នោតផ្សេងៗ

យោងតាមកិច្ចព្រមព្រៀង ស្តីពីការបន្តសម្ព័ន្ធភាពរវាងគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត និងគណបក្សសហព័ន្ធសង្គមគ្រីស្ត នីតិកាលទី១៧ ដែលបានធ្វើកាលពីថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០០៩ អ្នកតំណាងរាស្រ្តគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត និងគណបក្សសហព័ន្ធសង្គមគ្រីស្តនៃសភាសហព័ន្ធអាល្លឺម៉ង់ ជាអ្នកសម្រេចដោយខ្លួនឯងនូវវិធានការបោះឆ្នោត និងវិធានការតែងតាំងផ្សេងៗ។

ទ១៧ ការបោះឆ្នោតក្នុងសតាសហព័ន្ធអាល្លឺម៉ង់

(១) ក្នុងក្រុមអ្នកតំណាងរាស្រ្ត របស់គណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត និងគណបក្សសហព័ន្ធសង្គមគ្រីស្ត នៃសភាសហព័ន្ធអាល្លឺម៉ង់ មិនមានការបង្ខិតបង្ខំទេ។ ការអនុម័ត ជាសេរីភាពរបស់អ្នកតំណាងរាស្រ្ត ដែលជាសមាជិក។ សមាជិកណាដែលមានបំណងចង់បោះឆ្នោត ផ្ទុយពីឆន្ទៈនៃសម្លេងភាគច្រើនរបស់ក្រុម សមាជិកនោះមានកាតព្វកិច្ច ត្រូវជូនដំណឹងដល់ប្រធាន អ្នកដឹកនាំទី១នៃកិច្ចការសភា ឬកិច្ចប្រជុំក្រុមអ្នកតំណាងរាស្រ្ត មិនឲ្យហួសពីម៉ោង ៥ល្ងាច មួយ ថ្ងៃមុនការបោះឆ្នោតក្នុងសភាពេញអង្គទេ។

(២) ក្នុងករណីដែលក្រុមអ្នកតំណាងរាស្រ្ត សម្រេចធ្វើការបោះឆ្នោតក្នុងសភាពេញអង្គ តាមវិធីភ្ជាប់ទាំងឈ្មោះ ពេលនោះសមាជិកនៃក្រុមអ្នកតំណាងរាស្រ្តទាំងអស់ ត្រូវតែទទួលបានការជូនដំណឹងជាមុនភ្លាមៗ។ សិទ្ធិក្នុងការទាមទារឲ្យធ្វើការបោះឆ្នោតដោយវិធីភ្ជាប់ ឈ្មោះ ក្នុងរាល់ពេលប្រជុំពេញអង្គរបស់ប្រធាន ឬសមាជិកក្រុមប្រឹក្សាភិបាលក្នុងតំណែង តាមមាត្រា ទ១៨ ចំណុច៣ មិនមានអ្វីប៉ះពាល់ទេ។

**(៣)** នៅក្នុងការបោះឆ្នោតដោយវិធីភ្ជាប់ឈ្មោះបន្តបន្ទាប់ នៃកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ ឈ្មោះរបស់សមាជិកដែលមិនមានវត្តមាន ត្រូវបានប្រាប់ឲ្យដឹង ដោយពាក្យសុំទោស ដោយមានបញ្ជាក់មូលហេតុភ្ជាប់មកជាមួយ។ ការជូនដំណឹងនេះត្រូវបានបញ្ជូនតាមរយៈថ្នាក់ដឹកនាំក្រុមអ្នកតំណាងរាស្ត្រ ឬមួយតាមរយៈសាខាបក្សនៃរដ្ឋសហព័ន្ធ ហើយក៏បញ្ជូនមកអង្គភាពតាមរដ្ឋ និងស្រុកផងដែរ។

## ទ១៨ កាតព្វកិច្ចរបស់សមាជិក

**(១)** សមាជិកនៃក្រុមអ្នកតំណាងរាស្ត្រ មានកាតព្វកិច្ចចូលរួមក្នុងកិច្ចប្រជុំ និងកិច្ចការសភាសហព័ន្ធអាល្លឺម៉ង់ ក្នុងគណៈកម្មាការជំនាញ និងក្នុងគណៈកម្មាការក្រុមការងារ។

**(២)** កាតព្វកិច្ចរបស់សមាជិកមាន៖

ក. ចុះឈ្មោះក្នុងបញ្ជីវត្តមាន ក្នុងការប្រជុំគណៈកម្មាការ ឬក្រុមអ្នកតំណាងរាស្ត្រ

ខ. សុំច្បាប់ឲ្យបានទាន់ពេលវេលា ប្រសិនបើមិនអាចចូលរួមក្នុងកិច្ចប្រជុំ ហើយត្រូវជម្រាបឲ្យដឹងថាតើគេអាចធ្វើការទាក់ទងបានតាមវិធីណា

គ. សុំច្បាប់ចំពោះប្រធាន ឬអ្នកដឹកនាំកិច្ចការសភា ឲ្យបានទាន់ពេលវេលា ប្រសិនបើមិនអាចចូលរួមក្នុងកិច្ចប្រជុំពេញអង្គរបស់សភាសហព័ន្ធអាល្លឺម៉ង់

ឃ. ជាពិសេស ត្រូវជួយជ្រោមជ្រែងក្នុងកិច្ចប្រជុំក្រុមការងារ និងកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ ក្នុងពេលពិភាក្សានូវប្រធានបទអ្វីដែលជាការផ្តួចផ្តើមរបស់ខ្លួន ហើយត្រូវមានវត្តមានក្នុងកិច្ចប្រជុំពេញអង្គរបស់សភាសហព័ន្ធ នៅពេលណាប្រធានបទនោះ ត្រូវបានលើកយកមកពិភាក្សា។

**(៣)** រាល់កិច្ចប្រជុំពេញអង្គរបស់សភាសហព័ន្ធ ប្រធាន ឬអនុប្រធានមួយរូប

ឬអ្នកដឹកនាំកិច្ចការសភាមួយរូប ដែលទទួលខុសត្រូវកិច្ចការនេះ។ សមាជិកដែលទទួលបន្ទុកជាអ្នកនាំពាក្យរបស់ក្រុមអ្នកតំណាងរាស្ត្រ លើប្រ-ធានបទដែលត្រូវលើកយកមកពិភាក្សាសភាពេញអង្គ ត្រូវជួយជ្រោមជ្រែងដល់សមាជិកក្រុមប្រឹក្សាភិបាល ដែលទទួលបន្ទុកលើប្រធានបទនោះ។ ប្រសិនបើសមាជិកណាម្នាក់ មានបំណងចាកចេញពីកិច្ចប្រជុំមុនពេលកិច្ចប្រជុំពេញអង្គ ត្រូវបានបញ្ចប់សមាជិកនោះមានកាតព្វកិច្ចត្រូវសុំការអនុញ្ញាតពីសមាជិកក្រុមប្រឹក្សាក្នុងតំណែង ហើយត្រូវចុះឈ្មោះក្នុងបញ្ជីអ្នកតំណាងរាស្ត្រដែលត្រូវបានដាក់ឲ្យវិស្សមកាល។

## ទ១៩ ទំនាក់ទំនងជាមួយអង្គភាព និងសតារបស់រដ្ឋសហព័ន្ធ

សមាជិកក្រុមអ្នកតំណាងរាស្ត្រមានកាតព្វកិច្ច ភ្ជាប់ទំនាក់ទំនងជាប្រចាំជាមួយសមាគមនៃរដ្ឋសហព័ន្ធ និងជាមួយក្រុមអ្នកតំណាងរាស្ត្រនៃសភារដ្ឋសហព័ន្ធ។ គេត្រូវតែតែងតាំងបុគ្គលិកបំរើការងារនេះ ដោយមធ្យោបាយខ្លួនឯង។

## ទ២០ ច្រកចេញចូលរបស់ឯកសារ

**(១)** សេចក្តីព្រាងច្បាប់ សេចក្តីស្នើសុំ សំណួរតូច និងធំដែលដាក់ដោយក្រុមអ្នកតំណាងរាស្ត្រ ត្រូវដាក់ជូនថ្នាក់ដឹកនាំសភា ដែលជាអ្នកទទួលខុសត្រូវ។ ហើយកិច្ចការនេះ គេត្រូវទទួលខុសត្រូវចំពោះអ្នកលើកសំណើក្នុងដំណើរការការងារក្រោយៗទៀត៖

ក. បញ្ជូនសំណើនោះដល់ក្រុមប្រឹក្សាភិបាល ហើយក្រុមប្រឹក្សាភិបាលបញ្ជូនសំណើនោះ ទៅក្រុមការងារបន្តទៀតដោយមិនបង្អង់

ខ. បន្ទាប់ពីធ្វើការពិភាក្សាក្នុងក្រុមកាងាររួច សំណើនេះ នឹងត្រូវដាក់បញ្ចូលក្នុងកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ ប្រសិនបើប្រធានមិនមានបំណងចង់យកសំណើនេះ ទៅពិភាក្សាក្នុងក្រុមប្រឹក្សាភិបាលទៀតទេ

គ. ក្នុងករណីសំណើត្រូវបានជំទាស់ដោយក្រុមប្រឹក្សាភិបាល សំណើនោះ ក៏អាចត្រូវបានបញ្ជូនទៅក្នុងកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រដែរ បើមានសំណូមពរពីម្ចាស់សំណើ

ឃ. បញ្ជូនសំណើទៅអគ្គលេខាធិការដ្ឋានសភា។

**(២)** អ្នកតំណាងរាស្ត្រណាដែលចង់ចុះហត្ថលេខា លើសំណើដែលត្រូវបានអនុញ្ញាតដោយកិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រ ត្រូវជំរាបគោលបំណងនេះដល់ថ្នាក់ដឹកនាំកិច្ចការសភា។

**(៣)** ការចូលរួមក្នុងគំនិតផ្តួចផ្តើម ឆ្លងទៅក្រុមអ្នកតំណាងរាស្ត្រផ្សេងទៀត តម្រូវឲ្យធ្វើការកំណត់បង្ហាញដល់ថ្នាក់ដឹកនាំកិច្ចការសភា។ មុនពេលបញ្ជូនទៅសភាសហព័ន្ធអាល្លឺម៉ង់ តម្រូវឲ្យរង់ចាំការបោះឆ្នោតគាំទ្រពីសំណាក់កិច្ចប្រជុំក្រុមអ្នកតំណាងរាស្ត្រសិន។

**(៤)** សំណួរ (សំណួរដែលតម្រូវឲ្យឆ្លើយជាលាយលក្ខណ៍អក្សរ ឬជាចម្លើយផ្ទាល់មាត់) យោងតាមឧបសម្ព័ន្ធ៤ នៃបទបញ្ជាផ្ទៃក្នុងរបស់សភាសហព័ន្ធអាល្លឺម៉ង់ ត្រូវបញ្ជូនទៅការិយាល័យរបស់ថ្នាក់ដឹកនាំកិច្ចការសភា ហើយការិយាល័យនេះបញ្ជូនសំណួរទាំងនោះ ទៅអគ្គលេខាធិការដ្ឋានសភាបន្តឲ្យទាន់ពេលវេលា។

## ឧបសម្ពន្ធ

នីតិវិធី ក្នុងការបោះឆ្នោតរបស់អ្នកតំណាងរាស្ត្រគណបក្សសហព័ន្ធប្រជាធិបតេយ្យគ្រីស្ត តាមមាត្រាទ១៦ នៃបទបញ្ជាផ្ទៃក្នុងនេះ

១. ថ្នាក់ដឹកនាំកិច្ចការសភា និងអ្នកច្បាប់ ត្រូវបោះឆ្នោតជ្រើសរើសតាមសំណើរបស់ប្រធាន។

២. មិនតែប៉ុណ្ណោះក្នុងមាត្រាទ១២ និងទ១៣មានចែងអំពីការប្រើប្រាស់ច្បាប់នេះ។ន

# ADVISORY PAPERS ON POLITICAL PARTY DEVELOPMENT

## Volume III

The Organisation and Work of
Political Groups in Parliaments

Konrad
Adenauer
Stiftung

Freedom, justice and solidarity are the basic principles underlying the work of the Konrad-Adenauer-Stiftung (KAS). KAS is a political foundation, closely associated with the Christian Democratic Union of Germany (CDU). As co-founder of the CDU and the first Chancellor of the Federal Republic of Germany, Konrad Adenauer (1876-1967) united Christian-social, conservative and liberal traditions. His name is synonymous with the democratic reconstruction of Germany, the firm alignment of foreign policy with the trans atlantic community of values, the vision of a unified Europe and an orientation towards the social market economy. In our European and international cooperation with more than 70 offices abroad and projects in over 120 countries, we make a unique contribution to the promotion of democracy, the rule of law and a social market economy.

The office in Cambodia has been established in 1994. KAS in Cambodia is mainly operating in the following fields: Administrative Reform and Decentralization, Strenthening Political Parties and Parliaments, Legal Reform, Media Development, Political Education and Social Market Economy, as well as Foreign Policy Consultancy.

# Content

**Preface** .......... 81

**1. Introduction: Origin and Principles of Political Groups** .......... 83

a. Quick History of Political Groups .......... 83

b. Relevance of Political Groups Today .......... 84

**2. How to Set Up a Political Group? The Fundamental Steps** .......... 86

a. The Political Statement .......... 86

b. Membership .......... 86

c. Internal Organisation of a Political Group .......... 87

d. Rules Of Procedures of Political Groups Meetings .......... 90

e. Political Group Cohesion and Group Discipline .......... 90

f. Funding .......... 92

**3. Work of a Political Group** .......... 94

a. Liaison with the Party .......... 94

b. Organising the Action of the Party within the Legislature .......... 95

c. Developing Detailed Policies .......... 97

d. Controlling the Government .......... 98

e. Representing the Political Party: Communication of the Party .......... 99

**Annexes** .......... 101

Annex I: Extract of Members of the Bundestag Act (Abgeordnetengesetz) .......... 103

Annex II: Extract of Rules of Procedure of the German Bundestag .......... 108

Annex III: Rules of Procedure for the CDU/CSU Parliamentary Group in the German Bundestag .......... 109

## Preface

